# សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ
# UNIVERSITY OF SOUTH-EAST ASIA

## មហាវិទ្យាល័យ វិទ្យាសាស្រ្តសង្គម និងនីតិសាស្រ្ត

## សារណា

សម្រាប់បំពេញលក្ខខណ្ឌថ្នាក់បរិញ្ញាបត្រ មុខជំនាញ នីតិឯកជន

**ប្រធានបទ ៖ ការការពារសិទ្ធិស្រ្តីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ**

**សាស្រ្តាចារ្យដឹកនាំ ៖ លោក ច័ន្ទ ចំរើន**

**ស្រាវជ្រាវដោយ ៖**


**១. និស្សិត ប៊ុន ឈុនណាយ**
**២. និស្សិត ស៊ុយ ច័ន្ទថី**
**៣. និស្សិត ផាន ស៊ាងអំ**
**៤. និស្សិត គាន ស៊ីឡាក់**
**៥. និស្សិត ស៊ា ចាន់នី**


**ពិភពលោក ជំនាញ ឧត្តមភាព និងឥរិយាបថ**

ឆ្នាំសិក្សា ២០១៦-២០២០

# សារណា

សម្រាប់បំពេញលក្ខខណ្ឌថ្នាក់បរិញ្ញាបត្រ ឯកទេស នីតិឯកជន

**ប្រធានបទ** ៖ ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ

ឆ្នាំសិក្សា ២០១៦-២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យ សៅស៍អុីសថ៍អេយសៀ ជំនាន់ទី១១ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ ឯកទេស នីតិឯកជន ដែលមានសមាជិកប្រាំរូបដូចមានរាយនាមដូចតទៅនេះ **ប៊ិន ឈុនណាយ, ស៊ុយ ច័ន្ទថី, ផាន ស៊ាងអំ, គាន ស៊ីឡាក់, ស៊ា ចាន់នី** ។

សូមគោរពប្រណិបត្តិ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគុណូបការៈរបស់លោកអ្នកមានគុណទាំងពីរ មានមាតាបិតាដែលបានផ្តល់កំណើតឱ្យយើងខ្ញុំ និងជួយទំនុកបម្រុងក្នុងការចិញ្ចឹមបីបាច់ថែរក្សា ទូន្មាន ប្រៀនប្រដៅ ព្រមទាំងផ្គត់ផ្គង់គ្រប់បែបយ៉ាងទាំងសម្ភារ ថវិកា និងការអប់រំ ដោយលោកមិនគិតពីការនឿយហត់ដែលលោកបានជួបប្រទះយ៉ាងណាក៏ដោយ ។ ហើយគោលបំណងតែមួយគត់របស់លោកគឺចង់ឃើញអនាគតរបស់យើងខ្ញុំទទួលបានជោគជ័យ និងមានគោលដៅច្បាស់លាស់មួយ ។

ហើយក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការទទួលស្វាគមន៍យ៉ាងយកចិត្តទុកដាក់ និងកក់ក្តៅបំផុត ក្នុងការជួយឧបត្ថម្ភខាងផ្នែកបញ្ញា ស្មារតី និងចំណេះដឹងដល់ក្រុមយើងខ្ញុំ ដែលរួមមាន ៖

លោក **ច័ន្ទ ចំរើន** ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ **សៅស៍អុីសថ៍អេយសៀ** ដែលបានទទួលដឹកនាំក្រុមយើងខ្ញុំ ដោយបានប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងលះបង់ពេលវេលាដ៏មានតម្លៃ ដើម្បីជួយបង្ហាញមាគ៌ា និងផ្តល់មតិល្អៗជាច្រើនដោយមិនខ្លាចនឿយហត់ ក្នុងការបណ្តុះបណ្តាលនូវចំណេះដឹងដល់យើងខ្ញុំ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះដោយទទួលបានជោគជ័យ ។

សូមអរគុណដល់លោកប្រធានសមាគម **ការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា ហៅកាត់ថា (អាដហុក)** ប្រចាំនៅខេត្តសៀមរាប និងបុគ្គលិកតាមផ្នែកនីមួយៗ ដែលបានផ្តល់ឱកាសឱ្យក្រុមយើងខ្ញុំបានចុះកម្មសិក្សាស្រាវជ្រាវ ព្រមទាំងបានផ្តល់នូវព័ត៌មានសំខាន់ៗដែលជួយគាំទ្រដល់ការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់ក្រុមយើងខ្ញុំ ។

លោក លោកស្រី ជាបុគ្គលិកគ្រប់ជាន់ថ្នាក់ និង លោកសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យ **សៅស៍អុីសថ៍អេយសៀ** ដែលបានជួយសម្របសម្រួលដល់ការសិក្សា និងបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងអស់គ្នាឱ្យទទួលបាននូវសមត្ថភាព ចំណេះដឹង សីលធម៌រស់នៅក្នុងសង្គម និងគុណភាពក្នុងការយកទៅអនុវត្តដើម្បីជួយសង្គមឱ្យមានការអភិវឌ្ឍ ។

ជាចុងក្រោយនេះក្រុមនិស្សិតយើងខ្ញុំ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនទៅដល់ មាតាបិតា លោកគ្រូដឹកនាំ នឹងលោកប្រធានសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាប ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យ ឱ្យជួបតែសេចក្តីសុខសេចក្តីចម្រើន ជោគជ័យគ្រប់កិច្ចការងារ មានសុខភាពល្អ និងគោរពជូនពរឱ្យជួបតែពុទ្ធពរទាំង៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មូលន័យសង្ខេប

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា កំពុងស្ថិតនៅលើយន្តការកសាងនីតិរដ្ឋ ដែលប្រកបដោយសុខសន្តិភាព ស្ថេរភាព អព្យាក្រឹត្យ និងមានអធិបតេយ្យភាពពេញលេញបរិបូណ៌ស្របតាមគោលការណ៍ច្បាប់ ប៉ុន្តែទោះបីជាយ៉ាងនេះក្តីប្រជាពលរដ្ឋមួយចំនួន នៅក្នុងព្រះរាជាណាចក្រកម្ពុជានៅមានកម្រិតនៃការយល់ដឹង និងចំណេះដឹងខាងផ្នែកសិទ្ធិមនុស្ស និងការគោរពសិទ្ធិមនុស្សនៅឡើយ ។ យ៉ាងណាមិញ ដើម្បីធានាបាននូវការការពារសិទ្ធិចំពោះស្ត្រីរងគ្រោះដែលបានជួបប្រទះនូវការរំលោភបំពានទៅលើផ្លូវភេទ និងការប្រើអំពើហិង្សាក្នុងគ្រួសារ ដូច្នេះស្ថានប័នរដ្ឋ ដែលមានអាជ្ញាធរមានសម្តកិច្ច និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ បានចូលរួមនៅក្នុងការធានានូវសិទ្ធិទាំងអស់នោះរបស់ស្ត្រី ។ ក្នុងនោះដែរក្នុងនាមអង្គការក្រៅរដ្ឋាភិបាល ក៏បានចូលរួមជាផ្នែកមួយបន្ថែមទៀត ដើម្បីឃ្លាំមើលទៅលើសកម្មភាពរំលោភបំពានដែលបង្កដោយជនសាមញ្ញជម្មតា ក៏ដូចជាការអនុវត្តនូវនីតិវិធីច្បាប់របស់អាជ្ញាធរមានសម្តកិច្ច និងនីតីវិធីតុលាការផងដែរ ។ ហើយម្យ៉ាងវិញទៀត ក៏មានការចូលរួមចំណែកពីអង្គការក្រៅរដ្ឋាភិបាលជាច្រើនស្ថាប័នផ្សេងៗទៀតផងដែរ ដើម្បីធានាដល់ការចាត់នូវវិធានការនៃការអនុវត្តនីតិវិធី ការបង្ការ ការបង្ក្រាប និងជួយកាត់បន្ថយមិនឱ្យមានបទល្មើសថ្មីៗ និងបទល្មើសដដែលៗមិនឱ្យកើតឡើងបន្ថែមទៀត ។

អាស្រ័យហេតុនេះ បានជាយើងខ្ញុំមើលឃើញនូវកង្វះខាតរបស់សិស្ស និស្សិត និងអ្នកអានទៅលើសិទ្ធិរបស់ស្ត្រីនេះហើយ ទើបក្រុមយើងខ្ញុំបាននាំគ្នាផ្តួចផ្តើមគំនិតរៀបចំចងក្រងនូវកម្រងអត្ថបទសារណាស្តីពី "ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ" នេះឡើង ដើម្បីបង្ហាញនូវសិទ្ធិទាំងឡាយជាមូលដ្ឋានរបស់ស្ត្រីដែលមានការការពារដោយច្បាប់ និងត្រូវគោរពប្រតិបត្តិឱ្យបានជាដាច់ខាត ទោះបីជាស្ថិតក្នុងស្ថានភាព ឬកាលៈទេសៈណាក៏ដោយ ។

ដូច្នេះហើយ ដើម្បីរួមចំណែកក្នុងការការពារ និងការលើកស្ទួយការគោរពសិទ្ធិមនុស្ស មិនឱ្យមានការរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានរបស់ស្ត្រី យើងខ្ញុំបានខិតខំប្រមូលឯកសារ និងអត្ថបទច្បាប់ជាច្រើនដើម្បីចងក្រងជាអត្ថបទសារណាឡើង ដើម្បីជាប្រយោជន៍ដល់ប្អូនៗនិស្សិតជំនាន់ក្រោយបានសិក្សារៀនសូត្រ ។ ជាងនេះទៅទៀត កម្រងសារណានេះនឹងជួយជាវិភាគទានដល់ការងារអប់រំ ការផ្សព្វផ្សាយ និងស្វែងយល់ដល់ស្រទាប់ប្រជាជន និងមហាជននៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ជាការពិតណាស់ទៅហើយ សៀវភៅកម្រងសារណាដែលជាស្នាដៃសំណេរដំបូងរបស់យើងខ្ញុំនេះនៅមិនទាន់មានលក្ខណៈត្រឹមត្រូវ ពេញលេញ គ្រប់ជ្រុងជ្រោយល្អឥតខ្ចោះនៅឡើយនោះទេ ពោលគឺនៅមានលក្ខណៈខ្វះខាតដែលជាបញ្ហាមួយដែលមិនអាចជៀសផុតបាន ។ ប៉ុន្តែជាស្នាដៃដែលយើងខ្ញុំខិតខំយ៉ាងលំបាកក្នុងស្ថានភាពដែលប្រទេសយើងកំពុងអភិវឌ្ឍន៍ ជាពិសេសវិស័យធនធានមកនុស្ស ។

សរុបសេចក្តីមក កម្រងអត្ថបទសារណានេះ ជាផ្នែកមួយដល់ការអភិវឌ្ឍសិទ្ធិមនុស្ស សំដៅលុបបំបាត់ការរំលោភសិទ្ធិស្ត្រីទាំងឡាយ ជាពិសេសស្ត្រីដែលត្រូវបានរំលោភសេពសន្ថវៈ និងស្ត្រីដែលរងការប្រើហិង្សាក្នុងគ្រួសារ ដែលមានសិទ្ធិឱ្យមានការគោរពប្រតិបត្តិតាមអំណាចនៃច្បាប់ និងច្បាប់អន្តរជាតិ ។

# សេចក្តីធានាអះអាងស្តីពីការមិនលួចចម្លងកម្មសិទ្ធិបញ្ញា

Declaration of Authenticity

យើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យ **សៅស៍អ៊ីសថ៍អេយសៀ** ជំនាន់ទី.........នៃមហាវិទ្យាល័យ ..............................................................មុខជំនាញ...........................................................។

សូមធានា និងទទួលខុសត្រូវទាំងស្រុងថា ខ្លឹមសារនៃកិច្ចការស្រាវស្រាវនេះពិតជាស្នាដៃផ្ទាល់របស់ក្រុមយើងខ្ញុំពិតប្រាកដមែន ដោយគ្មានពាក់ព័ន្ធជាមួយនឹងកិច្ចការស្រាវជ្រាវរបស់អ្នកផ្សេងឡើយ ។ ទិន្នន័យ និងលទ្ធផល ស្រាវជ្រាវដែលបានលើកឡើងនៅក្នុងសារណានេះពុំទាន់មានជនណាមួយយកទៅប្រើប្រាស់នៅក្នុងសារណារបស់គេឡើយ ។ ក្រុមយើងខ្ញុំសូមឯកភាពទាំងស្រុងថា បើសាកលវិទ្យាល័យពិនិត្យឃើញថាមានលួចចម្លង ឬលួចបន្លំកិច្ចការ របស់អ្នកដទៃ ក្រុមយើងខ្ញុំសូមទទួលទោសតាមការវិនិច្ឆ័យរបស់សាកលវិទ្យាល័យ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ថ្ងៃ...............................ខែ...................ឆ្នាំ.....................ព.ស.២៥៦......
សៀមរាប ថ្ងៃទី.........ខែ...........ឆ្នាំ...................

**១ និស្សិត**.................................. .......................................... **ប្រធាន**

**២ និស្សិត**.................................. .......................................... **សមាជិក**

**៣ និស្សិត**.................................. .......................................... **សមាជិក**

**៤ និស្សិត**.................................. .......................................... **សមាជិក**

**៥ និស្សិត**.................................. .......................................... **សមាជិក**

# មាតិកា


**ទំព័រ**

**សេចក្តីថ្លែងអំណរគុណ** ........ i

**មូលន័យសង្ខេប** ........ ii

**សេចក្តីធានាអះអាងស្តីពីការមិនលួចចម្លងកម្មសិទ្ធិបញ្ញា** ........ iii

**មាតិកា** ........ iv

**បញ្ជីតារាង** ........ vii

**បញ្ជីរូបភាព** ........ viii

**បញ្ជីក្រាហ្វិក** ........ ix

**បញ្ជីអក្សរកាត់** ........ x

**ជំពូកទី ១ ៖ សេចក្តីផ្តើម** ........ **១**

១.១- លំនាំបញ្ហា ........ ១

១.២- ចំណោទបញ្ហា និងសំណួរស្រាវជ្រាវ ........ ២

១.២.១- ចំណោទបញ្ហា ........ ២

១.២.២- សំណួរស្រាវជ្រាវ ........ ២

១.៣- គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤- វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

១.៤.១- វិសាលភាពនៃការស្រាវជ្រាវ ........ ៣

១.៤.២- ដែនកំណត់នៃការស្រាវជ្រាវ ........ ៣

១.៥- សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៥.១- ចំពោះអ្នកស្រាវជ្រាវផ្ទាល់ ........ ៣

១.៥.២- ចំពោះសមាគមអាដហុក សាខាខេត្តសៀមរាប ........ ៤

១.៥.៣- ចំពោះសាធារណជន ក៏ដូចនិស្សិតជំនាន់ក្រោយ ........ ៤

១.៦- រចនាសម្ព័ន្ធសារណា ........ ៤

**ជំពូកទី ២ ៖ រំលឹកទ្រឹស្តី** ........ **៦**

២.១- អត្ថន័យនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី ........ ៦

២.១.១- អត្ថន័យនៃការរំលោភសេពសន្ថវៈទៅលើស្ត្រី ........ ៦

២.១.២- អត្ថន័យនៃអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី ........ ៦

២.១.៣- ប្រភេទនៃការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី........... ៧
២.១.៤- ប្រភពដែលបង្កើតឱ្យមានការការពារទៅលើសិទ្ធិស្ត្រី ............................................ ៩
២.១.៥- ការការពាររបស់សមាគមអាដហុក សាខាខេត្តសៀមរាប ............................ ២០
២.១.៦- មូលហេតុដែលនាំឱ្យមានអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី ........................ ២០
២.១.៧- ទោសបញ្ញត្តិអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារលើស្ត្រី........ ២៧
២.២- បទពិសោធន៍ដែលពាក់ព័ន្ធទៅនឹងការរំលោភបំពាន ............................................ ២៩
២.២.១- មូលហេតុនៃការរំលោភបំពាន ............................................................ ២៩
២.២.២- យន្តការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ............................................... ៣២

**ជំពូកទី ៣ ៖ វិធីសាស្ត្រស្រាវជ្រាវ ............................................................ ៤៤**
៣.១- ទីកន្លែង ឬ អង្គភាព................................................................... ៤៤
៣.២- ប្រភេទនៃការស្រាវជ្រាវ ............................................................. ៤៤
៣.៣- ប្រភេទ និងប្រភពទិន្នន័យ............................................................ ៤៥
៣.៤- ការកំណត់ទំហំ និងការជ្រើសរើសសំណាក ............................................ ៤៥
៣.៤.១- ការកំណត់ទំហំសំណាក .......................................................... ៤៥
៣.៤.២- ការជ្រើសរើសសំណាក............................................................. ៤៥
៣.៥- ឧបករណ៍ និងសម្ភារនៃការស្រាវជ្រាវ.................................................. ៤៦
៣.៥.១- ឧបករណ៍នៃការស្រាវជ្រាវ ....................................................... ៤៦
៣.៥.២- សម្ភារនៃការស្រាវជ្រាវ ........................................................... ៤៦
៣.៦- វិធីសាស្ត្រប្រមូលទិន្នន័យ............................................................. ៤៦
៣.៧- វិធីសាស្ត្រវិភាគ និងបកស្រាយទិន្នន័យ.............................................. ៤៧
៣.៧.១- វិធីសាស្ត្រវិភាគទិន្នន័យ ......................................................... ៤៧
៣.៧.២- វិធីសាស្ត្របកស្រាយទិន្នន័យ ...................................................... ៤៧

**ជំពូកទី ៤ ៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា ............................................ ៤៨**
៤.១- ស្ថានភាពទូទៅរបស់ស្ថាប័ន............................................................ ៤៨
៤.១.១- ប្រវត្តិរបស់សមាគមអាដហុក..................................................... ៤៩
៤.១.២- ទស្សនវិស័យ បេសកកម្ម គោលដៅ និងគុណតម្លៃរបស់សមាគមអាដហុក ...... ៥០
៤.១.៣- រចនាសម្ព័ន្ធ ...................................................................... ៥១
៤.១.៤- តួនាទី និងភារកិច្ច ............................................................... ៥១
៤.១.៥- ដៃគូសហប្រតិបត្តិការរបស់សមាគមអាដហុក សាខាខេត្តសៀមរាប ............... ៥២

៤.២- លទ្ធផលស្រាវជ្រាវ និងការពិភាក្សា ........ ៥៣
៤.២.១- ប្រភេទនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ........ ៥៣
៤.២.២- មូលហេតុដែលនាំឱ្យមានការរំលោភបំពានទៅលើសិទ្ធិស្ត្រី ........ ៥៥
៤.២.៣- ចំណុចស្នើសុំរបស់ជនរងគ្រោះ និងអ្នកតំណាងជនរងគ្រោះ ........ ៥៧
៤.២.៤- លទ្ធផលនៃការអន្តរាគមន៍អំពីការរំលោភបំពានទៅលើសិទ្ធិស្ត្រី ........ ៥៩
៤.៣- នីតិវិធីនៃការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុក ........ ៦២
៤.៣.១- គុណសម្បត្តិ និងគុណវិបត្តិ ........ ៦៧
៤.៣.២- បញ្ហាប្រឈមរបស់សមាគមអាដហុកក្នុងការអនុវត្តនូវការការពារសិទ្ធិស្ត្រី ........ ៦៨

**ជំពូកទី ៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ........ ៧១**
៥.១- សេចក្តីសន្និដ្ឋាន ........ ៧១
៥.២- ការផ្តល់អនុសាសន៍ ........ ៧២

**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

**ចំណងជើង** **ទំព័រ**


តារាងទី ១ ៖ រចនាសម្ព័ន្ធរបស់សមាគមអាដហុក ខេត្តសៀមរាប........................................៥១
តារាងទី ២ ៖ មូលហេតុសំខាន់ៗនៃការរំលោភសេពសន្ថវៈ................................................៥៥
តារាងទី ៣ ៖ មូលហេតុសំខាន់ៗនៃអំពើហិង្សាក្នុងគ្រួសារ.................................................៥៦
តារាងទី ៤ ៖ ការទាមទាររបស់ជនរងគ្រោះនៃបទល្មើសរំលោភសេពសន្ថវៈ ..........................៥៨
តារាងទី ៥ ៖ ការទាមទាររបស់ជនរងគ្រោះនៃបទល្មើសអំពើហិង្សាក្នុងគ្រួសារ.......................៥៨
តារាងទី ៦ ៖ លទ្ធផលនៃការអន្តរាគមន៍អំពីការរំលោភសេពសន្ថវៈ .....................................៦០
តារាងទី ៧ ៖ លទ្ធផលអន្តរាគមន៍នៃអំពើហិង្សាក្នុងគ្រួសារ ...............................................៦១
តារាងទី ៨ ៖ ប្រភពព័ត៌មានដែលទទួលបាន ................................................................ ៦៣

# បញ្ជីរូបភាព

**ចំណងជើង** **ទំព័រ**


រូបភាពទី ១ ៖ ទីកន្លែង ឬអង្គភាពស្រាវជ្រាវ ............ ៥៤
រូបភាពទី ២ ៖ ស្លាកឈ្មោះរបស់សមាគមអាដហុក ខេត្តសៀមរាប ............ ៥៨
រូបភាពទី ៣ ៖ អគាររបស់សមាគមអាដហុក ខេត្តសៀមរាប ............ ៥៨
រូបភាពទី ៤ ៖ និមិត្តសញ្ញារបស់សមាគមអាដហុក ............ ៥៩

# បញ្ជីក្រាហ្វិក

**ចំណងជើង** **ទំព័រ**

ក្រាហ្វិកទី ១ ៖ សំណុំរឿងទាក់ទងនឹងបទល្មើសរំលោភសេពសន្ថវៈ ....................................៥៤
ក្រាហ្វិកទី ២ ៖ សំណុំរឿងទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ ........................................៥៤

# បញ្ជីអក្សរកាត់

## អក្សរកាត់ភាសាខ្មែរ

| | | |
|---|---|---|
| ក.អ.ស.ព.ន | ៖ | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ម.ស.ស.ហ | ៖ | មហាសន្និបាតអង្គការសហប្រជាជាតិ |
| ស.ប.ស.ស | ៖ | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប. | ៖ | អង្គការសហប្រជាជាតិ |

## អក្សរកាត់ភាសាអង់គ្លេស

| | | |
|---|---|---|
| CEDAW | : | The Convention on the Elimination of all Forms of Discrimination against |
| DEVAW | : | Declaration on the Elimination of Violence against Women |
| ICCPR | : | International Covenant on Civil and Political Rights |
| UDHR | : | Universal Declaration of Human Rights |

# ជំពូកទី ១
# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហា

នៅក្នុងសម័យសកលភាវូបនីយកម្មបច្ចុប្បន្ននេះឃើញថា ស្ទើរតែគ្រប់វិស័យ គឺមានការរីកចម្រើនគួរឱ្យកត់សម្គាល់ មានទាំងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ការធានាបាននូវសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។ ជាក់ស្តែងក៏មានទស្សនៈមួយចំនួនយល់ថា ស្ត្រីជាមនុស្សទន់ខ្សោយ និងមិនមានសមត្ថភាពដូចទៅនឹងបុរស ហើយពេលខ្លះ បង្ខំឱ្យស្ត្រីរៀបការជាមួយនឹងមនុស្សដែលខ្លួនមិនដែលស្គាល់ ឬមិនស្រលាញ់ និងមានទស្សនៈមិនល្អមកលើស្ត្រី ។ ហើយនៅក្នុងការអនុវត្តជាក់ស្តែង ក៏មានរំលោភសេពសន្ថវៈ និងអំពើហិង្សាទៅលើស្ត្រីផងដែរ ។

ជាការពិតណាស់ ក្រោយពីប្រទេសកម្ពុជាមានការរួបរួមគ្នាឡើងវិញ ឃើញថាប្រជាពលរដ្ឋខ្មែរគ្រប់រូបទទួលបាននូវសិទ្ធិ និងសេរីភាពរបស់ខ្លួនដែលមានដូចជា សិទ្ធិក្នុងការដើរហើរដោយសេរី សិទ្ធិប្រកបមុខរបរចិញ្ចឹមជីវិត សិទ្ធិមិនត្រូវបានការគាបសង្កត់ពីនរណាម្នាក់ជាដើម ។ នៅក្នុងនោះ សិទ្ធិស្ត្រីក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីជាការលើកកម្ពស់ឱ្យស្ត្រីបានចូលរួមចំណែកនូវក្នុងការអភិវឌ្ឍសង្គមជាតិ និងគេចផុតពីការរំលោភបំពានផ្សេងៗ ដោយមានការចូលរួមចំណែកទាំងរដ្ឋាភិបាលនៅក្នុងប្រទេស ក៏ដូចជាក្រុមអង្គការសង្គមស៊ីវិលជាដើម ។ ការចូលរួមចំណែកពីគ្រប់ស្ថានប័ននេះ គឺជាសារៈសំខាន់ដ៏ខ្លាំងក្លាមួយដើម្បីជួយជំរុញ និងធានាបាននូវការលុបបំបាត់ពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារលើស្ត្រីជាដើម ។ ម្យ៉ាងវិញទៀត ការលុបបំបាត់នូវរំលោភសេពសន្ថវៈ និងអំពើហិង្សាទៅលើស្ត្រីនេះ នឹងក្លាយទៅជាកម្លាំងចលករដ៏សំខាន់មួយទៀតសម្រាប់ប្រទេសជាតិ ក្នុងការឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព ។ ហើយជាក់ស្តែងផងដែរ នៅក្នុងខេត្តសៀមរាបផ្ទាល់ក៏មានអង្គការសង្គមស៊ីវិលមួយចំនួន ក៏ដូចក្រសួង និងមន្ទីរកិច្ចការនារីកំពុងតែនឹងបន្តការគាំទ្រ និងគាំពារទៅលើការការពារសិទ្ធិស្ត្រីដើម្បីកុំឱ្យមានការរំលោភបំពានកើតឡើង ។

ហេតុដូច្នេះហើយ ដើម្បីការពារស្ត្រីអំពីការរំលោភបំពានទៅលើផ្លូវភេទ និងការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ ប្រជាពលរដ្ឋគ្រប់រូបត្រូវយល់ដឹងអំពីច្បាប់ និងយន្តការនៃការការពារសិទ្ធិស្ត្រីជាមុនសិន ។ ដោយហេតុនេះហើយ ទើបក្រុមយើងខ្ញុំសម្រេចជ្រើសយកប្រធានបទ ៖ "**ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ**" ដើម្បីធ្វើការស្រាវជ្រាវបញ្ចប់នូវថ្នាក់បរិញ្ញាបត្រ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ ឯកទេស នីតិឯកជន ។

## ១.២- ចំណោទបញ្ហា និងសំណួរស្រាវជ្រាវ

### ១.២.១- ចំណោទបញ្ហា

ជាទូទៅនៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ បទល្មើសដែលទាក់ទងទៅនឹងស្ត្រី តែងតែកើតមានឡើងជារឿយៗ ក្នុងនោះមានបទល្មើសពីរដែលតែងតែកើតមានឡើង គឺបទល្មើសរំលោភបំពានផ្លូវភេទ និងបទល្មើសអំពើហិង្សាក្នុងគ្រួសារ ដែលភាគច្រើនជនរងគ្រោះជាស្ត្រី ដែលជាបញ្ហាចោទមួយហើយបញ្ហានេះកើតមានឡើងស្ទើរតែទូទាំងប្រទេសកម្ពុជា ។ ដោយបញ្ហាទាំងនេះកំពុងតែធ្វើឱ្យកើតមាននូវអសន្តិសុខសង្គម បាត់បង់សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព សេចក្តីថ្លៃថ្នូរ ជាពិសេសព្រមទាំងបាត់បង់នូវធនធានមនុស្សដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ ។ ដោយហេតុថា បញ្ហានៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ជាបទល្មើសមួយដែលកើតមានឡើងជារឿយៗផងដែរនៅក្នុងសង្គមកម្ពុជា ដូចនេះយើងគួរតែយកចិត្តទុកដាក់ក្នុងការលុបបំបាត់ចោលឱ្យអស់ពីសង្គម ហេតុនេះហើយទើបបានជាយើងចង់ដឹង និងបញ្ជាក់ថា តើសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាប នឹងមាននូវចំណាត់ការ និងយន្តការយ៉ាងដូចម្តេចខ្លះចំពោះបញ្ហាទាំងនេះ ។

### ១.២.២- សំណួរស្រាវជ្រាវ

តើសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ប្រចាំខេត្តសៀមរាប មានវិធានការយ៉ាងដូចម្តេចខ្លះ ដើម្បីធ្វើការការពារទៅលើសិទ្ធិស្ត្រីនៅពេលមានរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ?

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវទៅលើប្រធានបទ "**ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ** " គឺដើម្បីពិនិត្យទៅលើនីតិវិធីនៃការការពារសិទ្ធិស្ត្រីអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ នៅសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាប ដែលផ្តោតសំខាន់ទៅលើ ៖

- ស្វែងយល់អំពីមូលហេតុ និងប្រភេទនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រីនៅក្នុងខេត្តសៀមរាបនាពេលបច្ចុប្បន្ន
- ស្វែងយល់អំពីយន្តការនៃការការពារសិទ្ធិស្ត្រីអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ
- សិក្សាអំពីស្ថានភាពទូទៅនៃការការពារសិទ្ធិស្ត្រីការអំពីរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅនឹងការអនុវត្តជាក់ស្តែង ។

## ១.៤- វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

### ១.៤.១- វិសាលភាពនៃការស្រាវជ្រាវ

ដោយការសិក្សាទៅលើការការពារសិទ្ធិរបស់ស្ត្រីមានលក្ខណៈធំទូលាយ ដូចច្នេះក្រុមរបស់យើងខ្ញុំធ្វើការកំណត់យកការស្រាវជ្រាវដោយផ្តោតតែទៅលើប្រធានបទ "**ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ**" ដែលមានទីតាំងស្ថិតនៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

### ១.៤.២- ដែនកំណត់នៃការស្រាវជ្រាវ

ដោយពេលវេលាក្នុងការចុះកម្មសិក្សាស្រាវជ្រាវមានរយៈពេលខ្លី គឺចាប់ពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩ ក្រុមរបស់យើងខ្ញុំនឹងធ្វើការស្រាវជ្រាវដោយផ្តោតសំខាន់តែទៅលើការការពារសិទ្ធស្ត្រីអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ នៅតែក្នុងវង្វង់នៃខេត្តសៀមរាប ។

## ១.៥- សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំលើប្រធានបទ "**ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ**" អាចផ្តល់សារៈសំខាន់ដូចខាងក្រោម ៖

### ១.៥.១- ចំពោះអ្នកស្រាវជ្រាវផ្ទាល់

- បានបំពេញលក្ខខណ្ឌដើម្បីបញ្ចប់ឆ្នាំសិក្សា និងទទួលបានសញ្ញាបត្របរិញ្ញាបត្រ
- ទទួលបានចំណេះដឹង នៃការការពារសិទ្ធិស្ត្រីដោយផ្តោតទៅលើការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ពីសមាគមអាដហុកសាខាខេត្តសៀមរាប
- បានយល់ដឹងអំពីរបៀប និងនីតិវិធីផ្សេងៗនៃការការពារសិទ្ធិស្ត្រីដោយផ្តោតទៅលើការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ របស់សមាគមអាដហុកសាខាខេត្តសៀមរាប
- បានជួយពង្រឹងនូវចំណេះដឹងមួយកម្រិតបន្ថែមទៀត ដែលពាក់ព័ន្ធនឹងសមាគមអាដហុកសាខាខេត្តសៀមរាប
- ទទួលបានបទពិសោធន៍នៃការការពារសិទ្ធិស្ត្រីដោយផ្តោតទៅលើការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ នៅក្នុងសមាគមចំពោះអ្នកស្រាវជ្រាវផ្ទាល់ ។

### ១.៥.២- ចំពោះសមាគមអាដហុក សាខាខេត្តសៀមរាប

- បានដឹងអំពីចំណុចខ្សោយ ឬចំណុចខ្លាំងរបស់សមាគម
- បង្កើនការយកចិត្តទុកដាក់ចំពោះការងារ
- ធ្វើឱ្យប្រជាពលរដ្ឋមានជំនឿទុកចិត្តទៅលើសមាគមកាន់តែខ្ពស់
- ផ្តល់ជាអនុសាសន៍មួយចំនួនទៅដល់សមាគមអាដហុក សាខាខេត្តសៀមរាប
- ទទួលបានកេរ្តិ៍ឈ្មោះបន្ថែមទៀត ដោយអនុញ្ញាតឱ្យនិស្សិតចុះកម្មសិក្សា ដែលជាកត្តាជួយជំរុញផ្នែកសិក្សាអប់រំស្រាវជ្រាវ ។

### ១.៥.៣- ចំពោះសាធារណជន ក៏ដូចនិស្សិតជំនាន់ក្រោយ

- សម្រាប់អ្នកអានធ្វើឱ្យពួកគេទទួលបាននូវចំណេះដឹងជាច្រើនពីការការពារសិទ្ធិស្ត្រីអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ
- ជាចំណេះដឹងមួយផ្នែកទៀតសម្រាប់ការយល់ដឹងយ៉ាងទូលាយ និងគួរឱ្យកត់សម្គាល់
- ជាអត្ថប្រយោជន៍មួយចំពោះអ្នកស្រាវជ្រាវដែលមានភាពស្រពិចស្រពិលកន្លងមក
- ទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយធ្វើការស្រាវជ្រាវ និងស្វែងយល់បន្តដើម្បីបង្កើននូវចំណេះដឹងមួយកម្រិតទៀត ។

### ១.៦- រចនាសម្ព័ន្ធសារណា

**ជំពូកទី១ ៖ សេចក្តីផ្តើម** ជាចំណុចដំបូងដែលក្រុមយើងខ្ញុំនិយាយអំពីខ្លឹមសារទូទៅសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងបង្ហាញពីគោលបំណងនៃការស្រាវជ្រាវទាំងមូល ដែលក្នុងនោះដែរ ក៏មាននិយាយអំពីលំនាំបញ្ហា ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវជាដើម ។

**ជំពូកទី២ ៖ រំលឹកទ្រឹស្តី** ដំណាក់កាលនេះ យើងបានរំលឹកឡើងវិញនូវទ្រឹស្តីសំខាន់ៗមួយចំនួនដូចជា ការបកស្រាយនូវអត្ថន័យនៃអត្ថបទច្បាប់ជាតិ អន្តរជាតិ និងលទ្ធផលស្រាវជ្រាវមុនៗទាក់ទងនឹងប្រធានបទដូចជា សារណាមុនៗជាដើម ដែលបកស្រាយអំពីការការពារសិទ្ធិស្ត្រីដោយផ្តោតទៅលើការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ។

**ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ** ក្នុងជំពូកនេះ ជាវិធីសាស្ត្រមួយចំនួនដែលក្រុមយើងខ្ញុំបានធ្វើឡើងដើម្បីទទួលនូវទិន្នន័យពីអង្គភាព ដែលពាក់ព័ន្ធនឹងដំណើរការនៃការអនុវត្ត ការការពារសិទ្ធិស្ត្រីអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ។

**ជំពូកទី៤ ៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា** គឺជាការទាញនូវទិន្នន័យនៃការអនុវត្តជាក់ស្តែងនៅក្នុងសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ខេត្តសៀមរាប មកធ្វើការចងក្រងធ្វើជាបណ្តុំមួយដែលនិយាយរួម គឺការឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃការអនុវត្តនីតិវិធីរបស់សមាជិកនៃសមាគមអាដហុក សាខាខេត្តសៀមរាប ទៅលើការការពារសិទ្ធិរបស់ស្ត្រី ។ ក្នុងជំពូកនេះផងដែរ យើងក៏បានលើកឡើងនូវទស្សនៈ

បេសកកម្ម រចនាសម្ព័ន្ធ និងដំណើរការនៃការអនុវត្តនីតិវិធីរបស់សមាជិកនៃសមាគមអាជហុក សាខាខេត្ត សៀមរាប ។

**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** គឺជាការសន្និដ្ឋានសរុបទៅលើស្ថានភាពជាក់ស្តែងរបស់សមាគមអាជហុក សាខាខេត្តសៀមរាប ។ ខ្លឹមសារទាំងមូលនៃការសិក្សាស្រាវជ្រាវ ជាផ្នែកមួយដែលផ្តល់នូវគោលគំនិតបន្ថែមទៅលើចំណុចមួយចំនួនដែលខ្វះខាត ដើម្បីជួយបំពេញបន្ថែមឱ្យមានលក្ខណៈល្អប្រសើរឡើងវិញ ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១- អត្ថន័យនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី

### ២.១.១- អត្ថន័យនៃការរំលោភសេពសន្ថវៈទៅលើស្ត្រី

ជាការប្រព្រឹត្តមួយដែលមនុស្សម្នាក់មិនចង់ឱ្យកើតមានមកលើខ្លួន ឬមិនចង់ជ្រើសរើសយក ។ ការរំលោភសេពសន្ថវៈ ជាអំពើមួយដែលជាការក្បត់សេចក្តីទុកចិត្តទៅលើជនណាម្នាក់ ដោយការបញ្ចូលអង្គជាត ឬឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលជាការបង្ខិតបង្ខំ ការគំរាមគំហែង ឬការឆ្មក់យកឱកាសដើម្បីទទួលបានការស្រណុកសុខស្រួលរបស់ខ្លួន (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៣៩ ទំព័រទី ៧៥) ។

### ២.១.២- អត្ថន័យនៃអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី

អំពើហិង្សាក្នុងគ្រួសារ គឺជាគំរូនៃឥរិយាបទដែលជាប់ពាក់ព័ន្ធនឹងអំពើហិង្សា ឬការរំលោភបំពានផ្សេងទៀត ដោយមនុស្សម្នាក់ប្រឆាំងទៅនឹងមនុស្សផ្សេងទៀតនៅក្នុងការកំណត់ក្នុងគ្រួសារ ដូចជានៅក្នុងអាពាហ៍ពិពាហ៍ ឬដែលមានចរិកលក្ខណៈជាការប្រមាថមាក់ងាយ ការរំលោភ ការបំពាន ការគំរាមគំហែងលើផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច ដល់មនុស្សណាម្នាក់ ក្រុមណាមួយ ហើយដែលបានប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ដើម្បីត្រួតត្រាទៅលើមនុស្សផ្សេងៗទៀតដែលកំពុងរស់នៅក្នុងគ្រួសារនោះ ។ ក្រុមគ្រួសារ ឬបុគ្គលដែលបានជួបប្រទះអំពើហិង្សាក្នុងគ្រួសារមានរបួសពីរ គឺរបួសរាងកាយ និងផ្លូវចិត្ត ដែលអាចមានផលប៉ះពាល់ជាច្រើននៅលើចិត្ត រាងកាយ និងស្មារតី ។ វាគឺជាធម្មជាតិដើម្បីទទួលយកបទពិសោធន៍ទាំងនេះ និងការទទួលស្គាល់ផលប៉ះពាល់អាចជាជំហានដំបូងសំខាន់ក្នុងការផ្តោតលើដំណើរការឆ្ពោះទៅរកការស្តា និងការព្យាបាលមួយ(អង្គការថែទាំសុខភាពគ្រួសារកម្ពុជា «រ៉ាក់» ឆ្នាំ ២០១៧) ។

### ក. និយមន័យនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី

- **និយមន័យនៃការរំលោភសេពសន្ថវៈ**
  - **និយមន័យទី ១** ការរំលោភសេពសន្ថវៈ សំដៅទៅលើអំពើផ្លូវភេទ ឬអារម្មណ៍ផ្លូវភេទដែលបានបញ្ចូលអង្គជាតតាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលបានប្រព្រឹត្តទៅលើអ្នកដទៃ ដែលធ្វើឱ្យមនុស្សម្នាក់នោះ យល់ថាខ្លួនមិនមានអារម្មណ៍ថាសុខស្រួល ដោយទទួលរងការគំរាមកំហែង ឬភ័យខ្លាច ការប្រើហិង្សា និងការបង្ខិតបង្ខំជាដើម (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៣៩ ទំព័រទី ៧៥) ។
  - **និយមន័យទី ២** ការរំលោភសេពសន្ថវៈតាមនិយមន័យជាភាសាអង់គ្លេសទាំងស្រុងថា "Sexual assault is an act in which a person intentionally sexually touches

another person without that person's consent, or coerces or physically forces a person to engage in a sexual act against their will" ។ ដែលមាន អត្ថន័យជាខេមរៈភាសាថា ការរំលោភសេពសន្ថវៈ គឺជាអំពើនៃការរំលោភបំពានទៅលើបុគ្គលណាម្នាក់ដោយចេតនា ដោយពុំមានការយល់ព្រមពីបុគ្គលម្នាក់ទៀត ឬការបង្ខិតបង្ខំបុគ្គលណាម្នាក់ឱ្យរួមមេត្រីប្រឆាំងឆន្ទៈរបស់ខ្លួន (Wikipedia, 2020) ។

- **និយមន័យនៃអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី**
    - **និយមន័យទី ១** អំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី ជាអំពើណាមួយនៃអំពើហិង្សាដែលបង្កឱ្យមានការឈឺចាប់ ឬធ្វើទុកបុកម្នេញទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទដល់ស្ត្រី ដោយរួមមាន ការធ្វើឱ្យប៉ះពាល់ដល់ជីវិត ការធ្វើឱ្យប៉ះពាល់ដល់បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ និងការឈ្លានពានផ្លូវភេទណាមួយនៃការប្រព្រឹត្តអំពើនោះ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ៣ ទំព័រទី ១) ។
    - **និយមន័យទី ២** អំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី ជាអំពើណាមួយនៃអំពើហិង្សាដែលផ្អែកលើយេនឌ័រដែលបង្កឱ្យមាន ឬទំនងជាបង្កឱ្យមាន ការឈឺចាប់ ឬធ្វើទុកបុកម្នេញផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តដល់ស្ត្រី ដោយរួមមានការគំរាមកំហែងនៃការប្រព្រឹត្តអំពើនោះ ការបង្ខំ ឬការដកហូតតាមទំនើងចិត្តនូវសេរីភាព មិនថាកើតមានឡើងក្នុងជីវិតឯកជន ឬសាធារណៈនោះទេ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ១ ទំព័រទី ៣១៦) ។

## ២.១.៣- ប្រភេទនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី

### ក. ការរំលោភសេពសន្ថវៈ

ដោយយោងទៅលើក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញឱ្យឃើញថា ការរំលោភបំពានផ្លូវភេទ គឺត្រូវបានកំណត់ជាប្រភេទផ្សេងៗពីគ្នា ។ អំពើដែលចាត់ទុកជាការរំលោភបំពានផ្លូវភេទរួមមាន ការរំលោភសេពសន្ថវៈ ការប្រទូស្តកេរខ្មាស ការបង្ហាញកេរភេទ និងការរុកកួនខាងផ្លូវភេទ ។

- **ការរំលោភសេពសន្ថវៈ ៖** សំដៅដល់អំពើទាំងឡាយណាដែលបានបញ្ចូលអង្គជាត ឬបញ្ចូលឧបករណ៍អ្វីមួយទៅក្នុងអង្គជាតទៅលើជនណាម្នាក់ ទោះបីជាមានភេទដូចគ្នា ឬផ្ទុយគ្នាក៏ដោយ ដែលអំពើនោះបានប្រព្រឹត្តឡើងដោយការប្រើហិង្សា ការបង្ខិតបង្ខំ និងការគំរាមកំហែង (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៣៩ ទំព័រទី ៧៥) ។
- **ការប្រទូស្តកេរខ្មាស ៖** សំដៅដល់គ្រប់អំពើទាំងឡាយណាដែលបានប្រព្រឹត្តទៅលើជនណាម្នាក់ដែលបានប៉ះពាល់ ការស្ទាបអង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀត ដោយជននោះមិនបានស្ម័គ្រចិត្ត ឬជាការដែលបង្ខិតបង្ខំឱ្យអ្នកដទៃប្រព្រឹត្តអំពើនេះមកលើខ្លួន ឬទៅលើតតិយជនដើម្បីធ្វើឱ្យ

មានអារម្មណ៍ថារំជើបរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៤៦ ទំព័រទី ៧៨) ។

- **ការបង្ហាញកេរភេទ ៖** សំដៅដល់អំពើដែលបានបង្ហាញកេរភេទរបស់ខ្លួន ទៅឱ្យអ្នកដទៃបានមើលឃើញនៅតាមទីសាធារណៈជន (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៤៩ ទំព័រទី ៧៩) ។
- **ការរុកកួនខាងផ្លូវភេទ ៖** សំដៅដល់ការរំលោភបំពានអំណាចរបស់ខ្លួន ទៅលើជនម្នាក់ទៀត ដែលខ្លួនបានប្រគល់មុខងារឱ្យ និងការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ដើម្បីទទួលបានការអនុញ្ញាតឱ្យរំលោភសេពសន្ថវៈ (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៥០ ទំព័រ ទី ៧៩) ។

## ខ. អំពើហិង្សាក្នុងគ្រួសារនៅលើស្ត្រី

កាលណាមានអំពើហិង្សាបម្រុងនឹងកើតមានឡើង ឬកើតមានឡើង បុគ្គលគ្រប់រូបត្រូវតែមានទំនួលខុសត្រូវចំពោះអារម្មណ៍ ឬការចេះគ្រប់គ្រងអារម្មណ៍ និងសកម្មភាពរបស់ខ្លួនដែលទាក់ទងទៅនឹងអំពើហិង្សា និងការដឹងពីវិធីសាស្ត្រគ្រប់គ្រងអារម្មណ៍ ដើម្បីបញ្ចៀសការប្រើអំពើហិង្សានៅពេលមានកំហឹង គឺអាចជ្រើសរើសបានដូចជា ការអានសៀវភៅ ស្តាប់ចម្រៀង លេងកីឡា ពុះអុស ងូតទឹកត្រជាក់ ស្រែកខ្លាំងៗនៅទីវាល ។ ហើយអំពើហិង្សាក្នុងគ្រួសារមានបួនប្រភេទគឺ អំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវចិត្ត អំពើហិង្សាផ្នែកសេដ្ឋកិច្ច (អង្គការថែទាំសុខភាពគ្រួសារកម្ពុជា «រ៉ាក់» ឆ្នាំ ២០១៧) ។

- **អំពើហិង្សាផ្លូវកាយ ៖** ជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយ ទោះបីមានស្នាម ឬអត់មានស្នាមក៏ដោយ ដែលមានដូចជាការវាយនឹងដំបង ទាត់ធាត់ ដោយប្រើដៃជើង ឬជាវត្ថុណាមួយដែលអាចធ្វើឱ្យមានការឈឺចាប់បាន (អង្គការថែទាំសុខភាពគ្រួសារកម្ពុជា «រ៉ាក់» ឆ្នាំ ២០១៧) ។
- **អំពើហិង្សាផ្លូវចិត្ត ៖** ជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់គេ ហើយមិនអាចទទួលយកបាន ដូចជាការប្រើពាក្យសម្តីជេរប្រមាថ គំរាមគំហែង បំបិទសិទ្ធិសេរីភាព (អង្គការថែទាំសុខភាពគ្រួសារកម្ពុជា «រ៉ាក់» ឆ្នាំ ២០១៧) ។
- **អំពើហិង្សាផ្លូវភេទ ៖** ជាសកម្មភាពដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវភេទ តាមរយៈការប្រព្រឹត្តរឿងអាស្រូវ អាសអាភាស ការបៀតបៀនកេរខ្មាស ការលូកច្របាច់ទៅលើកេរភេទដោយការបង្ខិតបង្ខំទៅលើសហព័ទ្ធ និងការបង្ហាញរូបភាពអាសអាភាសជាដើម (អង្គការថែទាំសុខភាពគ្រួសារកម្ពុជា «រ៉ាក់» ឆ្នាំ ២០១៧) ។
- **អំពើហិង្សាផ្នែកសេដ្ឋកិច្ច ៖** ជាសកម្មភាពបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ការបិទសិទ្ធិក្នុងការរកប្រាក់ចំណូល និងចូលរួមចាត់ចែងលក់ទ្រព្យសម្បត្តិ ដែលមានដូចជា ការបោកចានឆ្នាំង ការលួចលក់ម៉ូតូ និងការមិនឱ្យទៅធ្វើការរកប្រាក់ចំណូលជាដើម (អង្គការថែទាំសុខភាពគ្រួសារកម្ពុជា «រ៉ាក់» ឆ្នាំ ២០១៧) ។

## ២.១.៤- ប្រភពដែលបង្កើតឱ្យមានការការពារនៅលើសិទ្ធិស្ត្រី

### ក. ប្រពៃណី

កម្ពុជាជាសង្គមមួយដែលមានឋានានុក្រមយូរណាស់មកហើយ និងមានវប្បធម៌ទំនៀមទំលាប់ដោយក្ដីសង្ឃឹមលើបុគ្គលដែលបានប្រព្រឹត្តសមរម្យទៅតាមតួនាទីរបស់ខ្លួនក្នុងសង្គម ។

ចំពោះស្ត្រីត្រូវបានគេគិតថាគួរតែគោរពតាមប្រពៃណី ហើយពួកគេគ្មានឱកាសច្រើនទេនៅក្នុងការអប់រំ ឬការងារនៅក្នុងសង្គម ។ ជាងនេះទៅទៀត ថែមទាំងមានសុភាសិតមួយបានលើកឡើងថា «ស្ត្រីបង្វិលចង្ក្រានមិនជុំ» ។ ដូច្នេះហើយ ស្ត្រីនៅតែក្នុងផ្ទះ និងធ្វើជាមេផ្ទះតែប៉ុណ្ណោះ ដោយពឹងផ្អែកទៅលើចំណូលរបស់ស្វាមីទាំងស្រុង ។

ទាំងនេះជាផ្នែកមួយនៃលទ្ធិតាមបែបជំនឿប្រពៃណី ដែលនៅតែចាក់ឫសយ៉ាងជ្រៅនៅក្នុងគ្រួសារជាច្រើននៅកម្ពុជា ដែលបង្ហាញពីអំណាចដ៏រឹងមាំ និងតួនាទីរបស់បុរសនៅក្នុងគ្រួសាររបស់ពួកគេ ។ ហេតុដូច្នេះហើយ បុរសភាគច្រើនមានជំនឿថា ស្ត្រីគួរតែស្ដាប់បង្គាប់ពួកគេ ហើយបែងចែកកាតព្វកិច្ចក្នុងគ្រួសារតាមវិធីជាក់លាក់មួយ ។ លើសពីនេះទៅទៀត នៅក្នុងប្រទេសកម្ពុជា អំពើហិង្សាក្នុងគ្រួសារមិនមែនជារឿងចម្លែកនោះទេសម្រាប់គ្រួសារមួយចំនួនដែលយល់ថា បុរសពិតប្រាកដគួរតែកោងកាច និងស្ត្រីពិតប្រាកដគួរតែស្ដាប់បង្គាប់ ។ កត្តានេះបង្កើតបានជាមូលដ្ឋានទំនៀមទំលាប់មួយសម្រាប់ជម្លោះប្ដីប្រពន្ធក្លាយជាអំពើហិង្សា និងការរំលោភបំពានទាំងនេះ ។

### ខ. ច្បាប់អន្តរជាតិ

– **សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)**

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (ស.ប.ស.ស) ត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិ (ម.ស.ស.ហ) អនុម័តនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ ដែលជាសរសេរគោលនៃរបបសិទ្ធិមនុស្សអន្តរជាតិនាពេលបច្ចុប្បន្ននេះ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ ទំព័រទី ៣) ។ នៅក្នុង ស.ប.ស.ស នេះ បញ្ញត្តិពីរដែលសំខាន់ជាងគេ គឺមាត្រា ២ និងមាត្រា ២១ ។

ចំពោះមាត្រា ២ បានបញ្ជាក់ពីសិទ្ធិស្មើគ្នារបស់មនុស្សទាំងអស់ដោយមិនគិតយេនឌ័រផងដែរ ហើយមនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។ លើសពីនេះទៅទៀត មិនត្រូវធ្វើការប្រកាន់បែងចែកណាមួយដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងដែនសមត្ថកិច្ច ឬខាងអន្តរជាតិរបស់ប្រទេស ឬដែនដីដែលបុគ្គលណាម្នាក់រស់នៅទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យក្តី ស្ថិតក្រោមអាណាព្យាបាលក្តី ឬគ្មានស្វ័យគ្រប់គ្រងក្តី ឬស្ថិតក្រោមការដាក់កម្រិតផ្សេងទៀតណាមួយដល់អធិបតេយ្យភាពក្តី (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ២ ទំព័រទី ៤) ។

ម្យ៉ាងវិញទៀត មាត្រា ២១ ក៏បានលើកឡើងអំពីសិទ្ធិនយោបាយជាមូលដ្ឋានរបស់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីចូលរួមក្នុងដំណើរការនៃការសម្រេចចិត្តទៅលើសេចក្ដីសម្រេច និងបោះឆ្នោតសម្រាប់ជោគវាសនារបស់ប្រទេសជាតិខ្លួនឯង (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ២១ ទំព័រទី ៧) ។

ទោះបីជាមិនត្រូវបានច្បាប់ចងជាកាតព្វកិច្ចជាបែបផែនសីលធម៌ ស.ប.ស.ស ក៏ប្ដេជ្ញាឱ្យរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិគោរពយ៉ាងពេញលេញ និងធានានូវសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋដែលបានចែងនៅក្នុងមាត្រា ៣០ នៃ ស.ប.ស.ស នេះ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ៣០ ទំព័រទី ៩) ។

– **កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)**

កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ និងចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ ទំព័រទី ៣៣) ។ ភាគីរដ្ឋនៃ ក.អ.ស.ព.ន មានកាតព្វកិច្ចគោរព និងការពារសេរីភាពពលរដ្ឋ និងការទទួលបានសិទ្ធិអំណាចនយោបាយរបស់ប្រជាពលរដ្ឋ ដោយជៀសពីការរំលោភសិទ្ធិមនុស្សលើប្រជាពលរដ្ឋ និងការពារភាគីទី ៣ ពីការបំពានលើច្បាប់សិទ្ធិមនុស្ស ហើយកម្ពុជាក៏បានផ្ដល់សច្ចាប័នលើ ក.អ.ស.ព.ន នេះនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ ទំព័រទី ៣៣) ។

មាត្រា ២ នៃ ក.អ.ស.ព.ន បានបញ្ជាក់ថា សិទ្ធិដែលមានក្នុងកតិកាសញ្ញានេះ គឺការទទួលបានសិទ្ធិអំណាចរបស់បុគ្គលម្នាក់ៗ ដោយភាគីនីមួយៗនៃកតិកាសញ្ញានេះ ត្រូវគោរព និងធានាជូនប្រជាពលរដ្ឋគ្រប់ៗរូបដែលនៅក្រោមអំណាចច្បាប់គេគ្រប់គ្រង នូវសិទ្ធិទាំងឡាយដែលគេទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ ដោយឥតប្រកាន់ភាពខុសគ្នារវាង ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិក្នុងវិស័យផ្សេងទៀតៗ ជាតិកំណើត វណ្ណៈ ឬឋានៈឡើយ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ២ ទំព័រទី ៣៤) ។

នៅក្នុងនោះដែរ មាត្រា ៣ បានធ្វើការផ្ដោតសំខាន់ទៅលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមនុស្សទាំងពីរភេទ ដោយរដ្ឋជាសមាជិកទាំងអស់ត្រូវធានាឱ្យមានសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងការអាស្រ័យផលនៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដូចដែលបានចែងក្នុងកតិកាសញ្ញានេះ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ៣ ទំព័រទី ៣៥) ។

ចំពោះមាត្រា ២៥ នៃកតិកាសញ្ញានេះ ក៏បានដាក់ចេញនូវសិទ្ធិជាមូលដ្ឋានគ្រឹះក្នុងការចូលរួមក្នុងនយោបាយ រួមទាំងការបោះឆ្នោត និងសិទ្ធិឈរឈ្មោះក្នុងការបោះឆ្នោត ដោយគ្មានការបែងចែកដូចដែលបានចែងក្នុងមាត្រា ២ និងដោយគ្មានការរឹតត្បិតដែលមិនសមហេតុផល ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ

និងមានឱកាសក្នុងការងារ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ២៥ ទំព័រទី ៤៣) ។

**– អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)**

កិច្ចព្រមព្រៀងអន្តរជាតិដែលសំខាន់ជាងគេលើសិទ្ធិស្ត្រី គឺអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ឬអាចហៅម្យ៉ាងទៀតថា ច្បាប់អន្តរជាតិស្តីពីសិទ្ធិសម្រាប់ស្ត្រី ។

អនុសញ្ញានេះត្រូវអនុម័តឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៧៩ និងចូលជាធរមានពីរឆ្នាំបន្ទាប់ គឺនៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៨១ ។ ថ្វីបើមានឯកសារដែលមានលក្ខណៈអន្តរជាតិដែលអះអាងនូវសិទ្ធិស្ត្រីនៅក្នុងខ្លឹមសាររបស់សិទ្ធិមនុស្សក៏ដោយ ក៏សន្ធិសញ្ញាដោយឡែកមួយនេះ ត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងការរើសអើងនឹងស្ត្រីភេទនៅទូទាំងពិភពលោក ។ លើសពីការសង្កត់ទៅលើកិច្ចការនេះ អនុសញ្ញាបានកំណត់ផងដែរអំពីចំនួនតំបន់ពិសេសៗ ដែលការរើសអើងប្រឆាំងនឹងស្ត្រីមានការស្តែងឡើង ជាពិសេសទាក់ទិនទៅនឹងការចូលរួមក្នុងជីវិតសាធារណៈ ការរៀបអាពាហ៍ពិពាហ៍ ជីវិតគ្រួសារ និងការកេងប្រវ័ញ្ចផ្លូវភេទ (ច័ន្ទ ចំរើន ឆ្នាំ ២០១៨ ទំព័រទី ២៩) ។

គោលបំណងនៃអនុសញ្ញានេះ គឺធ្វើឱ្យលូតលាស់នូវឋានៈរបស់ស្ត្រីដោយប្រើប្រាស់នូវវិធីទ្វេ ។ វាតម្រូវឱ្យរដ្ឋជាភាគីផ្តល់នូវសេរីភាព និងសិទ្ធិទៅដល់ស្ត្រីនៅលើមូលដ្ឋានស្មើគ្នាទៅនឹងបុរស លែងដាក់ទៅលើស្ត្រីនូវវិន័យតឹងរឹងបែបប្រពៃណី ។ វាអំពាវនាវដល់រដ្ឋជាភាគីទាំងឡាយឱ្យលុបចោលនូវគំរូសង្គម និងវប្បធម៌ ជាបឋមតាមរយៈការអប់រំជាមូលដ្ឋានដែលបង្កើតបែបផែនចាស់នៃតួនាទីនៅក្នុងផ្ទះ សាលារៀន និងទីកន្លែងធ្វើការងារ ។ វាពឹងផ្អែកទៅលើគំនិតជាមូលដ្ឋានដែលរដ្ឋទាំងឡាយត្រូវតែប្រកាន់នូវជំហានយ៉ាងសកម្ម ដើម្បីលើកតម្កើងនូវការលូតលាស់របស់ស្ត្រី ជាមធ្យោបាយធានានូវការទទួលបានយ៉ាងពេញលេញនូវសិទ្ធិមនុស្ស ។ វាបានលើកទឹកចិត្តរដ្ឋជាភាគីឱ្យប្រើប្រាស់នូវរាល់វិធានការ រួមមានទាំងទង្វើដែលចូលចិត្តបំផុតដើម្បីឱ្យខ្ពង់ខ្ពស់ដល់ឋានៈស្ត្រី និងសមត្ថភាពរបស់ពួកគេ ដើម្បីចូលរួមក្នុងការសម្រេចចិត្តរាល់គ្រប់វិស័យដែលជាអាយុជីវិត ដូចជាសេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល និងនយោបាយ ។

រដ្ឋជាភាគីទាំងឡាយរបស់អនុសញ្ញាយល់ព្រមផ្តល់សច្ចាប័ន ដើម្បីដាក់បញ្ចូលនូវសមភាពរវាងបុរស និងស្ត្រីទៅក្នុងច្បាប់ជាតិ ដើម្បីអនុម័តនីតិបញ្ញត្តិ និងវិធានការផ្សេងៗទៀត ច្បាប់ដែលសមស្របដែលរារាំងដល់ការរើសអើងប្រឆាំងនឹងស្ត្រី ដើម្បីធានាតាមរយៈតុលាការជាតិ និងស្ថាប័នសាធារណៈផ្សេងទៀតនូវការការពារស្ត្រីដ៏មានប្រសិទ្ធិភាពប្រឆាំងនឹងការរើសអើង ហើយដើម្បីបន្ទុចបង្អាក់ពីការចូលរួមនៅក្នុងសកម្មភាព ឬការអនុវត្តដែលជាការរើសអើងនានាប្រឆាំងនឹងស្ត្រីផ្នែកឯកជន ។

ដោយយោងទៅលើការវិភាគស្រាវជ្រាវរបស់សាស្ត្រាចារ្យនីតិសាស្ត្រ នៃសាកលវិទ្យាល័យ យូស៊ី ខេត្តសៀមរាប យល់ឃើញថា មាត្រា ១៧ របស់អនុសញ្ញានេះ បានបង្កើតនូវគណៈកម្មាធិការសម្រាប់លុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ដើម្បីឱ្យត្រួតពិនិត្យមើលការអនុវត្តនូវលក្ខខណ្ឌនានា ។ ដោយនៅក្នុងខែ កញ្ញា ឆ្នាំ ២០១៣ មានប្រទេសចំនួន ១៨៩ បានក្លាយជាភាគីនៃអនុសញ្ញាស្តីពីការលុបបំបាត់

រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទនេះ ។ ហើយប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញានេះនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ១៩៨០ និងបានផ្តល់សច្ចាប័ន នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ (ច័ន្ទ ចំរើន ឆ្នាំ ២០១៨ ទំព័រទី ៣០) ។

**– សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (DEVAW)**

សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ជាសេចក្តីប្រកាសដែលប្រកាសដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ ទំព័រទី ៣១៥) ។ ក្នុងគោលបំណងនៃសេចក្តីប្រកាសនេះ ពាក្យថា « អំពើហិង្សាលើស្ត្រី » មានន័យថាជាអំពើណាមួយនៃអំពើហិង្សាដែលផ្អែកលើយេនឌ័រដែលបង្កឱ្យមាន ឬទំនងជាបង្កឱ្យមាន ការឈឺចាប់ ឬធ្វើទុកបុកម្នេញផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តដល់ស្ត្រីដោយរួមមានការគំរាមគំហែងនៃការប្រព្រឹត្តអំពើនោះ ការបង្ខំ ឬការដកហូតតាមទំនើងចិត្តនូវសេរីភាពមិនថាកើតមានឡើងក្នុងជីវិតឯកជន ឬសាធារណៈនោះទេ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ១ ទំព័រទី ៣១៦) ។

ស្ត្រីមានសិទ្ធិក្នុងការទទួលបាន និងមានការងារដោយស្មើភាពនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល ឬវិស័យដទៃទៀត ។ សិទ្ធិទាំងនេះរួមមានក្នុងចំនោមនោះជាអាទិ៍ ៖

- សិទ្ធិរស់រៀនមានជីវិត
- សិទ្ធិស្មើភាព
- សិទ្ធិក្នុងការទទួលបានសេរីភាព និងសន្តិសុខបុគ្គល
- សិទ្ធិក្នុងការទទួលបានការការពារស្មើភាពដោយច្បាប់
- សិទ្ធិក្នុងការរួចផុតពីគ្រប់ទម្រង់នៃការរើសអើង
- សិទ្ធិក្នុងការទទួលបានបទដ្ឋានខ្ពស់បំផុតនៃសុខភាពផ្លូលកាយ និងផ្លូវចិត្ត
- សិទ្ធិក្នុងការទទួលបានលក្ខខណ្ឌការងារស្មើភាព និងមានអំណោយផល
- សិទ្ធិក្នុងការមិនមែនជាកម្មវត្ថុនៃទារុណកម្ម ឬការប្រព្រឹត្តមកលើ ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ៣ ទំព័រទី ៣១៧) ។

រដ្ឋត្រូវថ្កូលទោសអំពីអំពើហិង្សាលើស្ត្រី និងមិនត្រូវលើកហេតុផលទំនៀមទំលាប់ ប្រពៃណី ឬសាសនាណាមួយ ក្នុងការគេចវេសនូវកាតព្វកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹងការលុបបំបាត់អំពើហិង្សាទាំងនោះទេ ។ រដ្ឋត្រូវអនុវត្តរាល់វិធានការសមស្របទាំងអស់ និងដោយគ្មានការពន្យាពេលក្នុងការដាក់ចេញនូវគោលនយោបាយក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី និងដើម្បីធ្វើដូចនេះត្រូវ ៖

- ធ្វើការពិចារណានៅពេលណាដែលមិនទាន់បានធ្វើ ក្នុងការឱ្យសច្ចាប័ន ឬទទួលយកនូវអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងលើស្ត្រី ឬដកចេញនូវលក្ខខណ្ឌចេញពីអនុសញ្ញានេះ
- ហាមចូលរួមក្នុងអំពើហិង្សាលើស្ត្រី
- អនុវត្តការត្រួតពិនិត្យផ្លូវច្បាប់ក្នុងការបង្ការ ធ្វើការស៊ើបអង្កេត និងដោយអនុលោមតាមច្បាប់ជាតិដាក់ទណ្ឌកម្មសកម្មភាពនៃអំពើហិង្សាលើស្ត្រី មិនថាសកម្មភាពទាំងនោះត្រូវបានប្រព្រឹត្តដោយរដ្ឋ ឬបុគ្គលឯកជននោះទេ
- ដាក់ចេញនូវទណ្ឌកម្មព្រហ្មទណ្ឌ រដ្ឋប្បវេណី ការងារ និងរដ្ឋបាលក្នុងច្បាប់ជាតិដើម្បីដាក់ទណ្ឌកម្ម និងឧបាស្រ័យនូវកំហុសឆ្គងដែលបង្កដល់ស្ត្រីដែលជាកម្មវត្ថុនៃអំពើហិង្សាហើយស្ត្រីដែលជាកម្មវត្ថុនៃអំពើហិង្សាគួរតែត្រូវបានផ្តល់នូវលទ្ធភាពនៃយន្តការទទួលបានយុត្តិធម៌ និងដូចដែលបានចែងដោយច្បាប់ជាតិ ទទួលបាននូវឧបាស្រ័យសមស្រប និងប្រកបដោយប្រសិទ្ធិភាពចំពោះការឈឺចាប់ដែលខ្លួនទទួលរង ហើយរដ្ឋគួរតែជូនដំណឹងដល់ស្ត្រីផងដែរនូវសិទ្ធិរបស់ពួកគេក្នុងការទាមទារនូវឧបាស្រ័យតាមរយៈយន្តការនេះ
- ពិចារណាពីការអភិវឌ្ឍផែនការសកម្មភាពជាតិក្នុងការលើកកម្ពស់ការការពារស្ត្រី ប្រឆាំងនឹងទម្រង់ណាមួយនៃអំពើហិង្សា ឬក្នុងការបញ្ចូលបញ្ញត្តិសម្រាប់គោលបំណងនេះក្នុងផែនការដែលមានស្រាប់ ធ្វើការពិចារណាដូចដែលសមស្របនូវកិច្ចសហប្រតិបត្តិការដែលអាចត្រូវបានផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសអង្គការទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាអំពើហិង្សាលើស្ត្រី
- អភិវឌ្ឍន៍តាមមធ្យោបាយដែលគ្រប់ជ្រុងជ្រោយមួយនូវវិធីសាស្ត្របង្ការ និងវិធានការទាំងឡាយនៃចរិតលក្ខណៈច្បាប់ នយោបាយ រដ្ឋបាល និងវប្បធម៌ដែលលើកកម្ពស់ការការពារស្ត្រីប្រឆាំងនឹងអំពើហិង្សាណាមួយ និងធានាថាការដាក់ឱ្យស្ត្រីក្នុងស្ថានភាពជនរងគ្រោះសារជាថ្មីមិនត្រូវបានកើតឡើងដោយសារមានច្បាប់ដែលបានរួមបញ្ចូលនូវបញ្ហាយេនឌ័រ មានការអនុវត្តនូវការចាប់បង្ខំអនុវត្តច្បាប់ ឬអន្តរាគមន៍ដទៃទៀត
- បំពេញការងារក្នុងការធានានូវកម្រិតអតិបរមា ដូចដែលអាចធ្វើទៅបាននូវធនធានដែលមានរបស់ខ្លួន និងនៅពេលដែលទាមទារ ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិដែលថាស្ត្រីដែលជាកម្មវត្ថុនៃអំពើហិង្សា និងពេលដែលសមស្រប ហើយកូនរបស់ពួកគេមានបានទទួលជំនួនពិសេស ដូចជាការស្តារសម្បទា ជំនួយក្នុងការថែទាំកុមារ និងការថែរក្សា ការព្យាបាល ការប្រឹក្សា និងសេវាសង្គម និងសុខភាព សម្ភារ និងកម្មវិធីផ្សេងៗព្រមទាំងរចនាសម្ព័ន្ធគាំទ្រ និងត្រូវចាត់រាល់វិធានការសមស្របទាំងអស់ក្នុងការលើកកម្ពស់នូវសុវត្ថិភាព និងការស្តារសម្បទា ផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ

- រួមបញ្ចូលក្នុងថវិកាជាតិនូវធនធានដែលគ្រប់គ្រាន់សម្រាប់សកម្មភាពរបស់ខ្លួន ពាក់ព័ន្ធនឹងការលុបបំបាត់អំពើហិង្សាលើស្ត្រី
- ចាត់វិធានការក្នុងការធានាថាមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីសាធារណៈដែលទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយដើម្បីបង្ការ ស៊ើបអង្កេត និងដាក់ទណ្ឌកម្មចំពោះអំពើហិង្សាលើស្ត្រី ទទួលបាននូវការបណ្តុះបណ្តាលដើម្បីឱ្យពួកគាត់ឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី
- អនុម័តរាល់វិធានការសមស្រប ជាពិសេសក្នុងវិស័យអប់រំ ក្នុងការកែតម្រូវគំរូសង្គម និងវប្បធម៌របស់បុរស និងស្ត្រី និងដើម្បីលុបបំបាត់ការរើសអើង ការអនុវត្តជាទំនៀមទំលាប់ និងការអនុវត្តដទៃទាំងឡាយដែលផ្អែកលើទស្សនៈនៃឋានៈខ្ពស់ជាង ឬទាបជាងនៃភេទណាមួយ និងលើតួនាទីតាមផ្នត់គំនិតចាស់គំរិលរបស់បុរស និងស្ត្រី
- លើកកម្ពស់ការស្រាវជ្រាវ ការប្រមូលទិន្នន័យ និងចងក្រងស្ថិតិ ជាពិសេសពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ ពាក់ព័ន្ធនឹងភាពលេចធ្លោនៃទម្រង់ផ្សេងៗនៃអំពើហិង្សាលើស្ត្រី និងជំរុញការស្រាវជ្រាវលើកត្តាបង្ក ចរិតលក្ខណៈ ភាពធ្ងន់ធ្ងរ និងលទ្ធផលនៃអំពើហិង្សាលើស្ត្រី និងស្តីពីប្រសិទ្ធិភាពនៃវិធានការដែលបានអនុវត្តក្នុងការបង្ការ និងឧបាស្រ័យអំពើហិង្សា ស្ថិតិ និងរបក គំហើញនៃការស្រាវជ្រាវទាំងនេះនឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ
- អនុម័តវិធានការដែលឆ្ពោះទៅកាន់ការលុបបំបាត់អំពើហិង្សាលើស្ត្រី ដែលជាពិសេសងាយរងគ្រោះនៃអំពើហិង្សា
- បញ្ចូលក្នុងការបញ្ជូនរបាយការណ៍តាមការតម្រូវនៃលិខិតុបករណ៍សិទ្ធិមនុស្សដែលពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ នូវព័ត៌មានពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងវិធានការដែលបានអនុវត្តក្នុងការអនុវត្តសេក្តីប្រកាសនេះ
- ជំរុញការអភិវឌ្ឍនៃគោលការណ៍ណែនាំសមស្រប ក្នុងការផ្តល់ជាជំនួយក្នុងការអនុវត្តគោលការណ៍ដែលបានកំណត់ក្នុងសេចក្តីប្រកាសនេះ
- ទទួលស្គាល់តួនាទីសំខាន់នៃចលនាស្ត្រី និងអង្គការក្រៅរដ្ឋាភិបាលទូទៅជាសកលលោកក្នុងការលើកកម្ពស់ការយល់ដឹង និងការបញ្ចៀសនូវបញ្ហានៃការប្រើអំពើហិង្សាលើស្ត្រី
- សម្របសម្រួល និងសម្រេចឱ្យបាននូវកិច្ចការនៃចលនាស្ត្រី និងអង្គការមិនមែនរដ្ឋាភិបាល និងសហការជាមួយពួកគេនៅថ្នាក់មូលដ្ឋាន ជាតិ និងតំបន់
- ជំរុញឱ្យអង្គការមិនមែនរដ្ឋាភិបាលថ្នាក់តំបន់ដែលពួកគេជាសមាជិក ក្នុងការរួមបញ្ចូលនូវការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងកម្មវិធីរបស់ពួកគេតាមការសមស្រប (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ៤ ទំព័រទី ៣១៨) ។

ក្នុងវិស័យដែនសមត្ថកិច្ច ស្ថាប័ន និងភ្នាក់ងារពិសេសរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ ត្រូវរួមចំណែកទទួលស្គាល់ និងសម្រេចបាននូវសិទ្ធិ និងគោលការណ៍ដែលបានកំណត់ក្នុងសេចក្តីប្រកាសនេះ និងដើម្បីធ្វើដូចនេះត្រូវ ៖

- ជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ និងថ្នាក់តំបន់ជាមួយទស្សនៈមួយក្នុងការកំណត់យុទ្ធសាស្ត្រថ្នាក់តំបន់ក្នុងការប្រយុទ្ធប្រឆាំងអំពើហិង្សា ធ្វើការផ្លាស់ប្តូរបទពិសោធន៍ និងផ្តល់ហិរញ្ញប្បទានកម្មវិធីពាក់ព័ន្ធនឹងការលុបបំបាត់អំពើហិង្សាលើស្ត្រី
- លើកកម្ពស់កិច្ចប្រជុំ និងសិក្ខាសាលាក្នុងគោលបំណងបង្កើត និងលើកកម្ពស់ការយល់ដឹងក្នុងចំណោមបុគ្គលពីបញ្ហានៃការលុបបំបាត់អំពើហិង្សាលើស្ត្រី
- ជំរុញកិច្ចសហការ និងការផ្លាស់ប្តូរក្នុងប្រព័ន្ធអង្គការសហប្រជាជាតិរវាងស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ក្នុងការដោះស្រាយបញ្ហានៃការលុបបំបាត់អំពើហិង្សាលើស្ត្រីប្រកបដោយប្រសិទ្ធិភាព
- បញ្ចូលក្នុងការវិភាគដែលបានរៀបចំដោយអង្គការ និងស្ថាប័នរបស់ប្រព័ន្ធអង្គការសហប្រជាជាតិនៃនិន្នាការ និងបញ្ហាដូចជាក្នុងរបាយការណ៍តាមកាលកំណត់ស្តីពីស្ថានភាពសង្គមពិភពលោក ការត្រួតពិនិត្យនិន្នាការក្នុងអំពើហិង្សាលើស្ត្រី
- ជំរុញសហប្រតិបត្តិការរវាងអង្គការ និងស្ថាប័នរបស់ប្រព័ន្ធអង្គការសហប្រជាជាតិក្នុងការបញ្ចូលបញ្ហាអំពើហិង្សាលើស្ត្រីក្នុងកម្មវិធីដែលកំពុងមានដំណើរការ ជាពិសេសដោយយោងលើក្រុមស្ត្រីដែលងាយរងទទួលអំពើហិង្សា
- លើកកម្ពស់ការបង្កើតគោលការណ៍ណែនាំ ឬសៀវភៅមគ្គុទេសន៍ពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីដោយធ្វើការពិចារណានូវវិធានការដែលបានចែងក្នុងសេចក្តីប្រកាសនេះ
- ពិចារណាលើបញ្ហានៃការលុបបំបាត់អំពើហិង្សាលើស្ត្រីតាមការសមស្រប ក្នុងការបំពេញអាណត្តិរបស់ពួកគេពាក់ព័ន្ធនឹងការអនុវត្តលិខិតុបករណ៍សិទ្ធិមនុស្ស
- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ៥ ទំព័រទី ៣២០) ។

គ្មានអ្វីក្នុងសេចក្តីប្រកាសនេះ ត្រូវប៉ះពាល់ដល់បញ្ញត្តិណាមួយដែលមានប្រសិទ្ធិភាពជាង ក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី ដែលអាចមានចែងក្នុងច្បាប់របស់រដ្ឋមួយ ឬក្នុងអនុសញ្ញា សន្ធិសញ្ញា ឬអន្តរជាតិណាមួយ ឬលិខិតុបករណ៍ណាមួយជាធរមានក្នុងរដ្ឋមួយនោះទេ (Goran, Gudmundur និង Leif កែសម្រួល និងបោះពុម្ពលើកទី ៣ ឆ្នាំ ២០១២ មាត្រា ៦ ទំព័រទី ៣២០) ។

– **កិច្ចព្រមព្រៀងទីក្រុងប៉ារីស**

មនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា និងជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងនៅកម្ពុជាទាំងអស់ត្រូវមានសិទ្ធិ និងសេរីភាព ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងក្នុងបណ្តា

កិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ។ ហើយដើម្បីសម្រេចទិសដៅនេះ ប្រទេសកម្ពុជាបានសន្យាថានឹង ៖

- ធានាគោរព និងប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅកម្ពុជា
- គាំទ្រសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ក្នុងការធ្វើសកម្មភាពដែលជំរុញ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន
- ចាត់បណ្តាវិធានការដ៏មានប្រសិទ្ធិភាព ដើម្បីធានាថានយោបាយ និងអំពើប្រព្រឹត្តក្នុងអតីតកាល មិនត្រូវបានអនុញ្ញាតឱ្យវិលត្រលប់មកវិញជាច់ខាត
- ចូលរួមកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធដល់សិទ្ធិមនុស្ស ។

ហើយហត្ថលេខីផ្សេងៗទៀតនៃកិច្ចព្រមព្រៀងនេះ សន្យាថាជួយជំរុញ និងលើកទឹកចិត្តដល់ការគោរព និងប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅកម្ពុជា ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយ និងសេចក្តីសម្រេចទាំងឡាយរបស់មហាសន្និបាត អ.ស.ប ដែលទាក់ទងនឹងបញ្ហានេះ ដើម្បីជាពិសេសការពារទប់ទល់នឹងការកកើតឡើងវិញ ការរំលោភសិទ្ធិមនុស្សជាថ្មីទៀត (កិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសអំពីបញ្ហាកម្ពុជា ឆ្នាំ ១៩៩១ មាត្រា ១៥ ទំព័រទី ១១) ។

ក្រោយពីរយៈពេលអន្តរកាលបានបញ្ចប់ គណៈកម្មការ អ.ស.ប ស្តីពីសិទ្ធិមនុស្ស គប្បីបន្តឱ្យបានដិតដល់ពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយបើចាំបាច់មានរួមទាំងការតែងតាំងអ្នកធ្វើកំណត់ហេតុពិសេសម្នាក់ ដែលត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផលនៃការរកឃើញរបស់ខ្លួនទៅជូនគណៈកម្មការ និងមហាសន្និបាត (កិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសអំពីបញ្ហាកម្ពុជា ឆ្នាំ ១៩៩១ មាត្រា ១៧ ទំព័រទី ១២) ។

## គ. ច្បាប់ជាតិ

### – រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ រាល់ច្បាប់ និងឯកសារគតិយុត្តទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញ បើពុំនោះសោត ច្បាប់ និងឯកសារគតិយុត្តទាំងនោះនឹងអធម្មនុញ្ញភាព ។ ហើយរដ្ឋធម្មនុញ្ញបានបង្កើតជាក្របខណ្ឌមូលដ្ឋានរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិស្ត្រីដើម្បីចូលរួមក្នុងជីវិតនយោបាយ និងសាធារណៈក្នុងប្រទេសរបស់ខ្លួន ។

ក្នុងនោះដែរ យើងសង្កេតឃើញមានអំពីការទទួលស្គាល់ ការធានាអំពីសិទ្ធិ ការផ្តល់តម្លៃរវាងបុរស និងស្ត្រី និងការហាមឃាត់អំពីការរើសមួយចំនួន ដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចដែលមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។ ហើយប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ហើយការប្រើប្រាស់នូវ

សិទ្ធិសេរីភាពរបស់ខ្លួននេះ គឺមិនត្រូវឱ្យមានការប៉ះពាល់ទៅលើសិទ្ធិរបស់អ្នកដទៃទេឡើយ គឺត្រូវប្រើប្រាស់ឱ្យបានត្រឹមត្រូវទៅតាមច្បាប់ដែលបានកំណត់ (រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ មាត្រា ៣១ ទំព័រទី ៧) ។

ការធានានូវសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួនរបស់ជនគ្រប់រូប ដែលមិនអាចត្រូវបានចាប់ខ្លួន ឃុំខ្លួន បើជននោះពុំបានប្រព្រឹត្តអំពើដែលខុសច្បាប់ និងធានានូវការមិនឱ្យមានទោសប្រហារជីវិតនោះទេ (រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ មាត្រា ៣២ ទំព័រទី ៧) ។

ប្រជាពលរដ្ឋទាំងពីរភេទ គឺមានសិទ្ធិដូចគ្នា ក្នុងការជ្រើសរើសមុខរបរ ការងារ ដែលសមស្របទៅតាមសមត្ថភាពដែលខ្លួនមាន ទៅតាមតម្រូវការរបស់សង្គម និងមានសិទ្ធិទទួលបាននូវប្រាក់បំណាច់ស្មើគ្នាចំពោះការងារដែលដូចគ្នា ។ រីឯការងាររបស់ស្ត្រីមេផ្ទះ គឺមានតម្លៃស្មើទៅនឹងការងារដែលធ្វើនៅក្រៅផ្ទះផងដែរ ។ មួយវិញទៀត ប្រជាពលរដ្ឋទាំងពីរភេទ មានសិទ្ធិទទួលបាននូវការធានារ៉ាប់រងសង្គម អត្ថប្រយោជន៍ខាងសង្គមកិច្ច សិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពជាដើម (រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ មាត្រា ៣៦ ទំព័រទី ៨) ។

ការពារមិនឱ្យមានការរំលោភបំពានទៅលើរូបរាងកាយរបស់បុគ្គលណាមួយនោះឡើយ ។ ហើយក៏បានការពារ អំពីជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ អំពីការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅបានលុះត្រាតែ អនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។ ការហាមមិនឱ្យមានការធ្វើទារុណកម្ម កាបង្ខិតបង្ខំ ការធ្វើបាបទៅលើរូបរាងកាយ ចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារនោះទេ ។ រីឯភស្តុតាង គឺមិនអាចយកជាការបានទេ កាលណាភស្តុតាងនោះ បានមកពីការទទួលសារភាពដោយការបង្ខិតបង្ខំ តាមផ្លូវកាយ និងតាមផ្លូវចិត្ត ។ កាលណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ជនជាប់ចោទគឺពុំទាន់ចាត់ទុកថាមានទោសនោះទេ និងមានសិទ្ធិការពារខ្លួនទៅតាមផ្លូវតុលាការ (រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ មាត្រា ៣៨ ទំព័រទី ៨) ។

ការមិនឱ្យមានការរើសអើងគ្រប់ប្រភេទដែលប្រឆាំងនឹងស្ត្រី និងការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ។ រីឯបុរស និងស្ត្រី ត្រូវមានសិទ្ធិស្មើៗគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសនោះគឺក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលអាពាហ៍ពិពាហ៍ ត្រូវធ្វើទៅតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមការស្ម័គ្រចិត្តដោយគ្មានការបង្ខិតបង្ខំ ហើយបុរស និងស្ត្រីអាចមានសិទ្ធិជ្រើសរើសយកគូស្វាមី-ភរិយា ត្រឹមតែម្នាក់មួយប៉ុណ្ណោះ (រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ មាត្រា ៤៥ ទំព័រទី ១០) ។

ហាមដាច់ខាតមិនឱ្យមានរាល់ការលក់ដូរមនុស្ស ការធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី និងចំពោះនារីដែលមានគភ៌ មិនអាចត្រូវបានបញ្ឈប់ពីការងារនោះទេ ។ មួយវិញទៀត នៅពេលដែលសំរាលកូន នារីមានសិទ្ធិទទួលបាននូវការឈប់សម្រាក ដោយទទួលបានប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត (រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ មាត្រា ៤៦ ទំព័រទី ១០) ។

**– ក្រមព្រហ្មទណ្ឌ**

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងផងដែរអំពីរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី ។ ក្នុងនោះដែរ ទាក់ទងទៅនឹងការរំលោភសេពសន្ថវៈ ក្រមព្រហ្មទណ្ឌក៏មានចែងនៅចន្លោះពីមាត្រា ២៣៩ រហូតដល់ ២៤៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងបានចែងពីទោសបញ្ញត្តិផងដែរ ។ ជាមួយគ្នានោះដែរ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏មានចែងពីបញ្ញត្តិដែលពាក់ព័ន្ធទៅនឹងការប្រើអំពើហិង្សាក្នុងគ្រួសារ និងជាពិសេសនោះគឺ អំពើហិង្សាក្នុងគ្រួសារដែលទាក់ទងទៅនឹងស្ត្រី ក៏ដូចជាទោសបញ្ញត្តិផងដែរ ដែលមាននៅចន្លោះពីមាត្រា ២១៧ រហូតដល់ ២៣០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**– ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ**

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ជាច្បាប់ដោយឡែកមួយដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ។

នៅក្នុងច្បាប់នេះ គឺបង្កើតឡើងក្នុងគោលបំណងដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។ មួយវិញទៀត ច្បាប់នេះក៏មានទិសដៅបង្កើតយន្តការ នីត្យានុកូល ដើម្បីទប់ស្កាត់នូវអំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាភាពសុខដុមរមនានៅក្នុងគ្រួសារតាមទំនៀមទំលាប់ និងប្រពៃណីល្អរបស់ជាតិ ដែលស្របទៅតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមទៅលើបទដ្ឋានគតិយុត្តជាធរមាន (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១ ទំព័រទី ១) ។

ចំពោះពាក្យថាអំពើហិង្សាក្នុងគ្រួសារ គឺជាអំពើមួយដែលសំដៅដល់ហិង្សាដែលកើតមាន និងអាចកើតមានទៅលើ ប្តី ឬប្រពន្ធ កូនក្នុងបន្ទុក និងជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ២ ទំព័រទី ១) ។

ដើម្បីជៀសវាងនូវការកើតមានឡើងនៃអំពើហិង្សាក្នុងគ្រួសារ ដូច្នេះត្រូវតែធ្វើការទប់ស្កាត់ឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាព ហើយក៏តម្រូវឱ្យមានការចាត់វិធានការដ៏សមស្របមួយ ដើម្បីការពារជនរងគ្រោះ ឬជនដែលនឹងរងគ្រោះ ។ អំពើហិង្សាទាំងនោះរួមមាន ការប៉ះពាល់ដល់ជីវិត ការប៉ះពាល់ដល់បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោឃៅ និងការឈ្លានពានខាងផ្លូវភេទ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ៣ ទំព័រទី ១) ។

អំពើហិង្សាដែលអាចប៉ះពាល់ដល់ជីវិតរួមមាន មនុស្សឃាតគិតទុកជាមុន មនុស្សឃាតដោយចេតនា មនុស្សឃាតដោយអចេតនា និងមនុស្សឃាតដោយអចេតនា បណ្តាលមកពីអំពើចេតនាផ្សេង

ទៀតនៃជនល្មើស (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ៤ ទំព័រទី ២) ។

រីឯអំពើហិង្សាដែលប៉ះពាល់ដល់បូរណភាពរូបកាយមានដូចជា ការបំពារបំពានលើរូបកាយដោយប្រើអាវុធ ឬឥតអាវុធមានរបួស ឬគ្មានរបួស និងការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ៥ ទំព័រទី ២) ។

មួយវិញទៀត អំពើហិង្សាដែលជាការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅមានដូចជា ការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ និងការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្ត និងលើរូបរាងកាយដែលប្រព្រឹត្តហួសពីសិលធម៌ និងច្បាប់កំណត់ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ៦ ទំព័រទី ២) ។

និងអំពើហិង្សាដែលជាការឈ្លានពានខាងផ្លូវភេទរួមមាន ការប្រើហិង្សាសេពសន្ថវៈ ការបៀតបៀនកេរខ្មាស និងការធ្វើអាស្រូវភាស (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ៧ ទំព័រទី ២) ។

– **ច្បាប់ស្តីពីការងារ**

ច្បាប់ស្តីពីការងារ គឺជាច្បាប់ដោយឡែកមួយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី ០៧ នីតិកាលទី ០១ ដែលមានគោលបំណងគ្រប់គ្រងទៅលើទំនាក់ទំនងដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិត ដើម្បីយកមកអនុវត្តលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយ ស្នាក់នៅទីណាក៏ដោយ និងទោះបីភាគីទាំងនោះមានសញ្ជាតិអ្វីក៏ដោយ (ធនាគារពិភពលោក ឆ្នាំ ២០១៨ មាត្រា ១ ទំព័រទី ១) ។

នៅក្នុងនោះដែរ ច្បាប់នេះក៏បានកំណត់អំពីសិទ្ធិជាច្រើនរបស់ស្ត្រី ចំពោះការទទួលបាននូវការឈប់សម្រាកនៅពេលដែលត្រូវឆ្លងទន្លេ ដែលចំពោះស្ត្រីមានគត៌ នៅពេលត្រូវសម្រាលកូន នឹងត្រូវទទួលបានសិទ្ធិឈប់សម្រាកចំនួន កៅសិបថ្ងៃ និងបន្ទាប់ពីការឈប់សម្រាកសម្រាលកូនរួចមកក្នុងរយៈពេលពីរខែនៃការចូលធ្វើការ មិនត្រូវឱ្យស្ត្រីនោះធ្វើការងារណាមួយដែលធ្ងន់ៗនោះទេ គឺត្រូវឱ្យធ្វើតែការងារណាដែលស្រាលៗប៉ុណ្ណោះ ។ នៅក្នុងពេលដែលត្រូវឆ្លងទន្លេ ឬនៅថ្ងៃណាមួយក្នុងពេលឈប់សម្រាលកូននេះ ទោះបីដោយវិធីឱ្យដំណឹងមុនក៏ដោយ ក៏និយោជកមិនអាចបញ្ឈប់ស្ត្រីនោះពីការងារបានដែរ (ធនាគារពិភពលោក ឆ្នាំ ២០១៨ មាត្រា ១៨២ ទំព័រទី ៨៥) ។

នៅក្នុងអំឡុងពេលដែលឈប់សម្រាកនេះដែរ ស្ត្រីក៏នៅតែមានសិទ្ធិត្រូវទទួលបាននូវប្រាក់ឈ្នួលពាក់កណ្តាល ដោយគិតទាំងប្រាក់ឈ្នួលបន្ទាប់បន្សំផងដែរ ។ ហើយមានសិទ្ធិអាចនឹងទទួលបាននូវវត្ថុអំណោយផ្សេងទៀតប្រសិនបើមាន ប៉ុន្តែការទទួលបានប្រាក់ឈ្នួលនេះ គឺសម្រាប់តែស្ត្រីដែលមានអតីតភាពការងារយ៉ាងតិចមួយឆ្នាំតែប៉ុណ្ណោះ (ធនាគារពិភពលោក ឆ្នាំ ២០១៨ មាត្រា ១៨៣ ទំព័រទី ៨៥) ។

នៅក្នុងម៉ោងធ្វើការ ចំពោះស្ត្រីដែលបានសម្រាលកូនក្នុងរយៈពេលមួយឆ្នាំរួចមក ស្ត្រីនោះអាចបំបៅដោះកូនរបស់ខ្លួនបានរយៈពេលមួយម៉ោងក្នុងមួយថ្ងៃ ដោយរយៈពេលមួយម៉ោងនេះ អាចត្រូវបានបែង

ចែកជាពីរពេល ដែលមួយពេលៗស្មើនឹងសាមសិបនាទីម្តង គឺនៅពេលព្រឹកម្តង និងពេលថ្ងៃម្តង ដែលអាស្រ័យទៅលើការព្រមព្រៀងរវាងកម្មករនិយោជិតនោះ ជាមួយនិងនិយោជក ។ ក៏ប៉ុន្តែ ប្រសិនបើក្នុងករណីដែលគ្មានការព្រមព្រៀងគ្នានោះទេ គឺត្រូវយកម៉ោងដែលជាពាក់កណ្តាលពេលនៃរយៈពេលធ្វើការនីមួយៗ ដើម្បីធ្វើការបំបៅដោះកូន (ធនាគារពិភពលោក ឆ្នាំ ២០១៨ មាត្រា ១៨៤ ទំព័រទី ៨៥) ។

ចំពោះការដែលឈប់សម្រាកដើម្បីបំបៅដោះកូននេះដែរ គឺមិនត្រូវបានគិតបញ្ចូលជាមួយថ្ងៃដែលឈប់សម្រាកធម្មតាដែលមានចែងនៅក្នុងច្បាប់ស្តីពីការងារ ក្នុងបទបញ្ជាផ្ទៃក្នុងនៃសហគ្រាសណាមួយ ក្នុងអនុសញ្ញារួមនៃការងារ ឬកាឈប់សម្រាករបស់កម្មករឯទៀតទៅតាមទម្លាប់ក្នុងស្រុកនោះទេ (ធនាគារពិភពលោក ឆ្នាំ ២០១៨ មាត្រា ១៨៥ ទំព័រទី ៨៦) ។

ចំពោះសហគ្រាសដែលមានកម្មករនិយោជិតជាស្ត្រី ចាប់ពីចំនួនមួយរយនាក់ឡើងទៅ ទោះចាស់ក្តី ក្មេងក្តី នាយកនៃសហគ្រាសនោះ ត្រូវរៀបចំជាបន្ទប់សម្រាប់បំបៅដោះកូនមួយនៅក្នុងគ្រឹះស្ថាន ឬក៏នៅជិតនោះ ហើយនិងបន្ទប់សម្រាក់ដាក់ក្មេងនោះផងដែរ ។ តែបើសិនជាសហគ្រាសនោះ ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំបន្ទប់សម្រាប់ដាក់ក្មេងដែលមានអាយុលើសពីដប់ប្រាំបីខែដោយផ្ទាល់បាននោះទេ នារីដែលជាកម្មករនិយោជិតនោះ អាចរកដាក់ផ្ញើកូនរបស់ខ្លួននៅទារកដ្ឋានណាមួយក៏បាន ដោយការចេញសោហ៊ុយនៃការថែរក្សាកូននោះ គឺនិយោជកជាអ្នកចេញឱ្យ (ធនាគារពិភពលោក ឆ្នាំ ២០១៨ មាត្រា ១៨៦ ទំព័រទី ៨៦) ។

## ២.១.៥- ការការពាររបស់សមាគមអាដហុក

សមាគមអាដហុក បានធ្វើការទៅលើការការពារសិទ្ធិមនុស្សនៅកម្ពុជាតាមរយៈច្បាប់ និងសិទ្ធិសញ្ញាផ្សេងៗខាងលើនេះ ។

## ២.១.៦- មូលហេតុដែលនាំឱ្យមានអំពើហិង្សាក្នុងគ្រួសារនៅលើស្ត្រី

អំពើហិង្សាក្នុងគ្រួសារតែងតែកើតមានឡើងពីបញ្ហាជាច្រើន ដូចជាកើតឡើងដោយសារបុរសជាស្វាមីអាងអំណាច និងប្រើសិទ្ធិអំណាចរបស់ខ្លួនជាមេគ្រួសារគាបសង្កត់ទៅលើភរិយា ។ មានមូលហេតុផ្សេងទៀត កើតឡើងដោយសារការផឹកស្រា និងលេងល្បែងស៊ីសង ។ កត្តាខ្លះទៀតកើតឡើងដោយសារបុរសមានភាពមិនស្មោះត្រង់ កត្តាជីវភាពក្រីក្រពេក លុយកាក់បែងចែកមិនត្រឹមត្រូវក្នុងគ្រួសារ ឬភាពអវិជ្ជា ។ គ្រួសារមានជីវភាពធូរធារតែមិនមានភាពស្មោះត្រង់ មិនគោរពគ្នា និងមិនយល់ចិត្តគ្នា ករណីបុរសជាស្វាមីមានភរិយាថ្មីទៀតក៏ជាដើមហេតុនៃអំពើហិង្សាផងដែរ ។ គ្រួសារខ្លះទៀតដោយសារឃើញប្រពន្ធក្រមិនចេះអក្សរ ឬមិនបានរកលុយចូលក្នុងគ្រួសារ បុរសជាស្វាមីចេះតែរករឿងវាយធ្វើបាបប្រពន្ធជារឿយៗ ។ ហើយអំពើហិង្សាក្នុងគ្រួសារតែងតែកើតមានដោយសារមូលហេតុមួយចំនួនដូចខាងក្រោម ៖

- ចង់បានអំណាច និងការត្រួតត្រាលើសមាជិកគ្រួសារ
- ចង់ឱ្យគេគោរពកោតខ្លាចធ្វើតាមតម្រូវការរបស់ខ្លួនឯង

- ចង់ឱ្យគេស្តាប់តាមការបង្គាប់បញ្ជារបស់ខ្លួនឯង
- ចង់បង្ហាញថាខ្លួនជាមនុស្សខ្លាំងពូកែ
- ខ្វះវិធីគ្រប់គ្រងកំហឹងរបស់ខ្លួន
- ខ្វះការពិចារណា និងការអធ្យាស្រ័យឱ្យអ្នកដទៃ
- ការប្រកាន់យកនូវការអនុវត្តទម្លាប់ខុសឆ្គងមួយចំនួនដូចជា ៖
  - ស្ត្រីមិនស្មើនឹងបុរស ឬឯងមិនស្មើអញ
  - ខ្លួនមានសិទ្ធិប្រើអំណាចទៅលើអ្នកក្រោមបង្គាប់ ឬសមាជិកគ្រួសារ
  - ចង់បង្ហាញនូវភាពជាបុរស និងជឿថាស្ត្រីជាកម្មសិទ្ធិរបស់ខ្លួន ហើយអំពើហិង្សាជាវិធីមួយដែលធ្វើឱ្យនាងស្តាប់បង្គាប់ខ្លួន
  - ធ្វើត្រាប់តាមមនុស្សដែលបានអនុវត្តនៅក្នុងគ្រួសារ
  - យល់ថាជាវិធីល្អក្នុងការដោះស្រាយបញ្ហា និងការត្រួតត្រាអ្នកដទៃ (អង្គការថៃទាំសុខភាពគ្រួសារកម្ពុជា «រ៉ាក់» ឆ្នាំ ២០១៧) ។

**គ. ផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី**

- **ចំពោះជនរងគ្រោះ ៖**
  - ទទួលរងរបួសស្នាមលើរាងកាយ អាចពិការរយៈខ្លី ឬវែង ឬស្លាប់
  - ទទួលរងគ្រោះផ្លូវចិត្តដោយផ្ទាល់ និងប្រយោល
  - អាចរត់ចេញពីផ្ទះងាយគេអូសទាញ
  - មានការធ្លាក់ទឹកចិត្ត ឬជំងឺផ្លូវចិត្ត ឬវិកលចារិក ឬធ្វើអត្តឃាត
  - រៀនសូត្រមិបាន ខ្លាចគេ បាត់ភាពក្លាហាន
  - បាត់បង់នូវភាពកក់ក្តៅពីគ្រួសារ ។
- **ចំពោះជនប្រព្រឹត្ត ៖**
  - ទទួលបាននូវភាពអាម៉ាស់ ការមើលងាយ និងឯកោ
  - បាត់បង់ក្តីស្រលាញ់ពីប្រពន្ធ កូន បងប្អូន សាច់ញាតិ និងមិត្តភក្តិ
  - សង្គមមិនចូលចិត្ត
  - ទទួលទោសតាមផ្លូវច្បាប់ជាធរមាន ។
- **ចំពោះសហគមន៍ ៖**
  - បង្កើតអពមង្គល[1] នៅក្នុងសហគមន៍
  - រំខានដល់អាជ្ញាធរមានសមត្ថកិច្ច បងប្អូន អ្នកជិតខាង គ្រូពេទ្យ
  - ជាគំរូមិនល្អដល់កុមារ ហើយពួកគេអាចចំលងទង្វើនេះ
  - ប៉ះពាល់កិត្តិយសសហគមន៍ (អង្គការថៃទាំសុខភាពគ្រួសារកម្ពុជា«រ៉ាក់» ឆ្នាំ ២០១៧) ។

[1] អពមង្គល គឺជាសេចក្តីមិនចម្រើន ហេតុដែលនាំឲ្យវិនាស ឬអាប់ឱន

## ខ. សមត្ថកិច្ច និងនីតិវិធីការការពារជនរងគ្រោះ នៃអំពើហិង្សាក្នុងគ្រួសារ

ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតមានឡើង ឬបម្រុងនឹងកើតមានឡើងក៏ដោយ អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត មានកាតព្វកិច្ចធ្វើអន្តរាគមន៍ជាបន្ទាន់ ឬទប់ស្កាត់ និងការពារជនរងគ្រោះភ្លាម ។ ប្រសិនបើករណីដែលអំពើហិង្សាក្នុងគ្រួសារកើតមានឡើង អាជ្ញាធរមានសម្ថកិច្ចត្រូវធ្វើអន្តរាគមន៍ ហើយត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច ដើម្បីអាចឱ្យព្រះរាជអាជ្ញាមានចំណាត់ការទៅលើរឿងនោះ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ៩ ទំព័រទី ២) ។

ដើម្បីទប់ស្កាប់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ មន្ត្រីនៃក្រសួងកិច្ចការនារី ដែលបានបម្រើការងារក្នុងវិស័យដែលបញ្ញត្តិដោយច្បាប់នេះ ហើយមន្ត្រីនៃក្រសួងកិច្ចនារីត្រូវបានទទួលនីតិសម្បទាក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ដែលអាចធ្វើជាដើមបណ្តឹងជំនួសឱ្យជនរងគ្រោះបាន ស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១០ ទំព័រទី ៤) ។

ដើម្បីធ្វើកំណត់ហេតុជូនទៅតុលាការបាន ក្នុងករណីអវត្តមានមន្ត្រីដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌រួចហើយនោះ មន្ត្រីសមត្ថកិច្ចដែលពាក់ព័ន្ធដទៃទៀតរួមមាន មន្ត្រីនគរបាល ភ្នាក់ងារនគរបាល កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋានឃុំ/សង្កាត់ មន្ត្រីរបស់ក្រសួងកិច្ចការនារី រួមទាំងមេឃុំដែលបានចូលរួមធ្វើអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ ដែលត្រូវបានទទួលអំណាចពីច្បាប់នេះ ដើម្បីធ្វើកំណត់ហេតុបញ្ជូលទៅតុលាការបានផងដែរ ។ ម្យ៉ាងវិញទៀត កំណត់ហេតុនេះ គឺមានតម្លៃស្មើគ្នាដូចកំណត់ហេតុដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ផងដែរ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១១ ទំព័រទី ៤) ។

អាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវគោរពតាមនីតិវិធីដែលបានកំណត់ក្នុងបញ្ញត្តិនៃច្បាប់ដែលបានរៀបរាប់ខាងលើនេះ និងនីតិវិធីព្រហ្មទណ្ឌជាធរមាន ដើម្បីឱ្យការធ្វើអន្តរាគមន៍បានទាន់ពេលវេលានៅពេលមានអំពើហិង្សាកើតឡើង ឬទប់ស្កាត់ និងការពារដល់ជនរងគ្រោះបានទាន់ពេលវេលា (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១២ ទំព័ទី ៤) ។

## គ. វិធានការទប់ស្កាត់ និងការការពារជនរងគ្រោះ នៃអំពើហិង្សាក្នុងគ្រួសារ

ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើត ឬជឿជាក់ថានឹងកើតឡើង អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ដោយ ៖

– ឃាត់ទុកអាវុធ ឬវត្ថុជាក់ស្តែងដែលជនមុខសញ្ញា[2] បានប្រើប្រាស់ ឬអាចប្រើប្រាស់

[2] ជនមុខសញ្ញា សំដៅដល់អ្នកដែលបានប្រព្រឹត្ត កំពុងប្រព្រឹត្ត និងត្រៀមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ

- បង្វែរយកចេញជនមុខសញ្ញាពីកន្លែងកើតហេតុ ឬបង្វែរជនរងគ្រោះ បើមានការស្នើសុំពីជនរងគ្រោះ ហើយក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ
- ផ្ដល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្ដល់កន្លែងជម្រកបណ្ដោះអាសន្នដែលអាចជានាសុវត្ថិភាព និងផ្ដល់នូវជំនួយសុខាភិបាលជាបន្ទាន់
- ពន្យល់អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឱ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សា ដែលមានចែងនៅក្នុងមាត្រា ២០ និងមាត្រា ២៦ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១៣ ទំព័រទី ៤) ។

ដើម្បីការពារសន្តិសុខដល់ជនរងគ្រោះ អាជ្ញាធរមានសមត្ថកិច្ចអាចចេញសេចក្ដីសម្រេចរដ្ឋបាលដែលស្របតាមមាត្រា ៤៣ មាត្រា ៤៨ និងមាត្រា ៤៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ និងវិធានការបណ្ដោះអាសន្នស្របច្បាប់ ដែលមានជាអាទិ៍ ៖

- ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង
- ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬរបស់ញាតិសាលោហិតរបស់ជនរងគ្រោះ
- ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច
- ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសមាជិកក្នុងគ្រួសារ ឬជនដែលពាក់ព័ន្ធ (ច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១៤ ទំព័រទី ៥) ។

អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិអំណាចដើម្បីចូលទៅក្នុងទីកន្លែងកើតហេតុបាន ប្រសិនបើមានសំណើសុំធ្វើអន្តរាគមន៍ និងករណីមានបទល្មើសជាក់ស្ដែងកើតឡើងហើយ ។ មួយវិញទៀត ប្រសិនបើមន្ត្រី និងភ្នាក់ងារមានសមត្ថកិច្ចយល់ឃើញថា មានអំពើហិង្សាក្នុងគ្រួសារបានកើតឡើងក្នុងអំឡុងពេល ៤៨ ម៉ោងកន្លងផុត ឬនឹងអាចកើតឡើងក្នុងអំឡុងពេល ២៤ ម៉ោង ខាងមុខនោះ ភ្នាក់ងារមានសមត្ថកិច្ចអាចចូលទៅកន្លែងកើតហេតុបាន ទោះបីជាពុំមានដីកាតុលាការអនុញ្ញាតឱ្យចូលក៏ដោយ ។ ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច (ច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១៥ ទំព័រទី ៦) ។

អំឡុងពេលដែលអាជ្ញាធរមានសមត្ថកិច្ចធ្វើអន្តរាគមន៍ ជនរងគ្រោះអាចធ្វើបណ្ដឹងទៅតុលាការខេត្ត/ក្រុង ដើម្បីសុំឱ្យចេញដីកាការពារខ្លួន ។ ហើយចៅក្រមដែលទទួលការចាត់ការលើរឿងក្ដី ត្រូវចេញ

ដីកាការពារដល់ជនរងគ្រោះផងដែរ ទោះបីជាមាន ឬគ្មានវត្តមាននៃជនមុខសញ្ញាក៏ដោយ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១៦ ទំព័រទី ៦) ។

នៅក្នុងការអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ការសម្របសម្រួលរវាងភាគីទំនាស់ គឺជាវិធានការចម្បង ដើម្បីឱ្យភាគីឈានទៅដល់ការដោះស្រាយជម្លោះដោយសន្តិវិធី ដោយមិនចាំបាច់ឆ្លងកាត់ប្រព័ន្ធតុលាការ (បទលហុ) ។ ផ្ទុយទៅវិញអាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីផ្សះផ្សា ឬសម្រុះសម្រួលរវាងភាគីជម្លោះបានទេ ប្រសិនបើការប្រព្រឹត្តនោះមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិម (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១៧ ទំព័រទី ៦) ។

ជនទាំងឡាយណាដែលកំពុងប្រព្រឹត្តអំពើហិង្សាជាក់ស្តែង ឬជនមុខសញ្ញាណាដែលកំពុងតែរំលោភលើដីកាការពាររបស់តុលាការ អាជ្ញាធរមានសមត្ថកិច្ចអាចឃាត់ខ្លួនជននោះ ដោយពុំចាំបាច់មានដីកាពីតុលាការនោះទេ ។ ប៉ុន្តែក្រៅពីករណីទាំងពីរនេះ អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើការឃាត់ខ្លួនជនណាម្នាក់ដោយគ្មានដីកាអនុញ្ញាតពីតុលាការបាននោះទេ ។ ផ្ទុយទៅវិញ អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការឃាត់ខ្លួនបាន តែអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុច្បាស់លាស់ កសាងសំណុំរឿង និងបញ្ជូនជនមុខសញ្ញាដែលត្រូវឃាត់ខ្លួនទៅតុលាការជាបន្ទាន់ ក្នុងអំឡុងពេលអតិបរិមាដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ  ដើម្បីចាត់វិធានការបន្ថែមឱ្យស្របច្បាប់ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១៨ ទំព័ទី ៦) ។

ជាមួយគ្នានោះដែរ រាល់អំពើហិង្សាណាដែលមានចរិតជាបទល្មើសព្រហ្មទណ្ឌ(បទឧក្រិដ្ឋ ឬបទមជ្ឈិម) ធ្ងន់ធ្ងរ ត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញា ទោះអំពើហិង្សានេះបានកន្លងផុតទៅហើយក៏ដោយ ក៏បណ្តឹងអាជ្ញាត្រូវតែធ្វើឡើងតាមបែបបទដែលមានចែងក្នុងច្បាប់ដែលពាក់ព័ន្ធ និងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ១៩ ទំព័រទី ៧) ។

## ឃ. សិទ្ធិអំណាចតុលាការនៃអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី

ការចេញដីកាការពារដោយតុលាការមានសមត្ថកិច្ច គឺមានអានុភាពដើម្បីបង្គាប់បញ្ជាទៅលើជនមុខសញ្ញា លើអាជ្ញាធរមានសមត្ថកិច្ច និងលើជនដែលពាក់ព័ន្ធនឹងរឿងក្តីនេះ ហើយដីកាការពារនេះ វាគឺជាវិធានការសម្រាប់តែផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះ ។ ចំពោះដីកានេះដែរ គឺមានកម្មវត្ថុដើម្បីចង្អុលបង្ហាញអំពីស្ថានភាព សកម្មភាព ឬអាកប្បកិរិយាទាំងអស់ដែលជាការបង្គាប់ឱ្យធ្វើ ឬការបញ្ជាហាមឃាត់នូវទង្វើដែលទាក់ទិនទៅនឹងតម្រូវការការពារជនរងគ្រោះ ឬបុគ្គលណាដែលទទួលការគំរាមគំហែងពីអំពើហិង្សាក្នុងគ្រួសារ ។ ដីកាការពារមានពីរគឺ ឥទ្ធិពលសម្រាប់មួយរយៈ និងឥទ្ធិពលសម្រាប់បណ្តោះអាសន្ន ។ មួយវិញទៀត ចៅក្រមមានសមត្ថកិច្ចក៏មានសិទ្ធិចេញដីកាការពារសារជាថ្មីបានដែរ ដោយស្របតាមស្ថានភាពជាក់ស្តែង ឬបទបញ្ជាណាមួយក្នុងលក្ខណៈសមស្របណាមួយ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ២០ ទំព័រទី ៧) ។

ការចេញដីកាការពារដែលជាប្រយោជន៍ដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ លើគ្រប់ករណីទាំងអស់ ទោះជាអំពើហិង្សាក្នុងគ្រួសារនោះកើតឡើងផ្ទួនគ្នាជាផ្នែកស៊ីវិល ឬជាផ្នែករដ្ឋបាល ឬក៏ជាផ្នែកព្រហ្មទណ្ឌក្តី គឺត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់តុលាការខេត្ត/ក្រុង (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ២១ ទំព័រទី ៨) ។

ការធ្វើពាក្យបណ្តឹងដើម្បីសុំដីកាការពារពីតុលាការ គឺអាចធ្វើឡើងតាមរយៈ ៖

- ជនរងគ្រោះ ឬតំណាងជនរងគ្រោះ ឬអាជ្ញាធរមានសមត្ថកិច្ចនៃលំនៅឋានជនរងគ្រោះ ឬមន្ត្រីភ្នាក់ងារដែលបំពេញការងារនៅកន្លែងកើតហេតុ
- ជនណាម្នាក់ដែលបានដឹងពីឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើជនរងគ្រោះជាកុមារ ជាជនវិកលចរិក ឬជាជនដែលតុលាការយល់ថាគ្មានលទ្ធភាពធ្វើពាក្យបណ្តឹងដោយខ្លួនឯងបាន (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ២២ ទំព័រទី ៨) ។

ដីកាការពារត្រូវបានបែងចែកជាពីរដំណាក់កាលផ្សេងៗពីគ្នាគឺ ៖

- ដំណាក់កាលទី ១ ជាដីកាការពារបណ្តោះអាសន្ន ដែលអាចត្រូវបានចេញនៅក្នុងអំឡុងពេលដែលមានអាសន្នអំពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ ដែលមានរយៈពេល ២ (ពីរ) ខែ
- រីឯដំណាក់កាលទី ២ ជាដីកាការពារដែលអាចត្រូវបានចេញនៅក្នុងអំឡុងពេលដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់បានជំនុំជម្រះ ឬមុនពេលដែលមានសាលក្រមជាស្ថាពរ ដែលវាមានរយៈពេល ៦ (ប្រាំមួយ) ខែ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ២៣ ទំព័រទី ៨) ។

នៅពេលដែលទទួលបាននូវបណ្តឹងការពារ តុលាការមានសិទ្ធិអាចចេញដីកាការពារបណ្តោះអាសន្នបាន ដោយពុំចាំបាច់ធ្វើការសាកសួរជនមុខសញ្ញានោះទេ ប្រសិនបើវិធានការបណ្តោះអាសន្ននោះមានភាពចាំបាច់សម្រាប់រក្សាការពារសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ឬសម្រាប់ជាការរក្សាទុកជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិជនរងគ្រោះមុនមានសាលក្រមស្ថាពរ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ២៤ ទំព័រទី ៨) ។

ដើម្បីការពារជនរងគ្រោះ នៅពេលចេញដីកាការពារ តុលាការក៏មានសិទ្ធិនៅក្នុងការកំណត់បញ្ជាទៅលើសកម្មភាពរបស់ជនមុខសញ្ញាផងដែរ ដែលការកំណត់ទាំងនោះមានដូចតទៅ ៖

- ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង
- ហាមចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច
- ហាមមិនឱ្យជនមុខសញ្ញាទាក់ទងជាមួយជនរងគ្រោះតាមផ្លូវណាមួយ
- ហាមមិនឱ្យធ្វើការបំផ្លិតបំផ្លាញទ្រព្យសម្បត្តិ ឬធ្វើការចាត់ចែងលក់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ឬញាតិសាលោហិតរបស់ជនរងគ្រោះ

- បំបែកជនមុខសញ្ញាពីលំនៅឋានរួម ឬបំបែកជនរងគ្រោះបើមានការស្នើសុំ ហើយបើនៅក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ ។

មួយវិញទៀត បើសិនជាយល់ថាជាការចាំបាច់សម្រាប់ការការពារ ឬរៀបចំសុវត្ថិភាព សុខភាព និងសុខុមាលភាពជនរងគ្រោះ តុលាការអាចបង្គាប់ដោយចាត់វិធានការបន្ថែមទៀតដូចជា ៖

- បញ្ជាឱ្យភ្នាក់ងារនគរបាល ឬកងរាជអាវុធហត្ថណាម្នាក់ការពារបេតិកភណ្ឌផ្ទាល់ខ្លួនរបស់ជនរងគ្រោះ
- ត្រូវធ្វើការសម្រេចអំពីការថែរក្សាកូន និងអំពីសិទ្ធិទៅសួរសុខទុក្ខកូន ដោយត្រូវគិតអំពីសិទ្ធិ និងផលប្រយោជន៍នៃកុមារនោះជាធំ
- បញ្ចប់កាតព្វកិច្ចហិរញ្ញវត្ថុនៃជនរងគ្រោះ ចំពោះជនមុខសញ្ញា
- កំហិតឱ្យជនមុខសញ្ញាផ្តល់ជំនួយហិរញ្ញវត្ថុឱ្យជនរងគ្រោះ ដោយផ្អែកតាមលទ្ធភាពធនធាននៃជនមុខសញ្ញា (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ២៥ ទំព័រទី ៩) ។

អាជ្ញាធរមានសមត្ថកិច្ច ក៏អាចធ្វើការការផ្សះផ្សា ឬធ្វើការសម្រុះសម្រួលបានផងដែរ ប្រសិនបើមានការយល់ព្រមពីភាគីទាំងសងខាង ចំពោះបទល្មើសដែលជាអំពីហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬជាបទលហុ ។ នៅក្នុងការផ្សះផ្សានេះដែរ សមាជិកនៅក្នុងគ្រួសារអាចជ្រើសរើសតាមវិធីណាមួយក៏បាន ដោយវិធីទាំងនោះគឺ ការស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃចាស់ព្រឹទ្ធាចារ្យ មេភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីមកធ្វើជាអ្នកអាជ្ញាកណ្តាលដើម្បីជួយដោះស្រាយបញ្ហា និងថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារ ទៅតាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ២៦ ទំព័រទី ១០) ។

តុលាការត្រូវព្យាយាមធ្វើការផ្សះផ្សាភាគីមានវិបត្តិអំពើហិង្សា ក្នុងលក្ខខណ្ឌឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់សមាជិកនៃគ្រួសារនោះ ។ មួយវិញទៀត តុលាការក៏មិនអាចធ្វើការផ្សះផ្សាដោយការធ្វើការបង្ខិតបង្ខំភាគីណាមួយឱ្យចូលមកផ្សះផ្សា ឬបង្ខិតបង្ខំឱ្យចុះកិច្ចព្រមព្រៀង ដោយគ្មានការព្រមព្រៀងពីភាគីទាំងពីរបានឡើយ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ២៧ ទំព័រទី ១០) ។

មិនថាតែជនរងគ្រោះ ឬជនមុខសញ្ញានោះទេ ពួកគេមានសិទ្ធិដើម្បីទទួលបានអ្នកការពារតាមផ្លូវច្បាប់ ឬមានសិទ្ធិជ្រើសរើសអ្នកតំណាងដែលខ្លួនទុកចិត្ត នៅគ្រប់ដំណាក់កាលនៃនីតិវិធី (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ មាត្រា ៣១ ទំព័រទី ១១) ។

## ២.១.៧- ទោសបញ្ញត្តិអំពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារលើស្ត្រី

### ក. ការរំលោភសេពសន្ថវៈ

- **បទរំលោភសេពសន្ថវៈ(បទឧក្រិដ្ឋ)**
  - **បទរំលោភសេពសន្ថវៈធម្មតា** ៖ ជាបទរំលោភសេពសន្ថវៈដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ទៅ១០ (ដប់)ឆ្នាំ (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៣៩ ទំព័រទី ៧៥) ។
  - **បទរំលោភដែលមានស្ថានទម្ងន់**
    - ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស ៖ ជាបទរំលោភសេពសន្ថវៈដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តឡើងដោយការប្រើប្រាស់អាវុធ ឬគំរាមកំហែងនឹងអាវុធ ដោយប្រើប្រាស់គ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់ ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ដោយបុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ និងដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៤០ ទំព័រទី ៧៦) ។
    - ស្ថានទម្ងន់ទោសទៅនឹងជនរងគ្រោះ ៖ ជាបទល្មើសរំលោភសេពសន្ថវៈដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ និងនារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ហើយនិងបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពនៃបុគ្គលនេះ ត្រូវបានគេមើលឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៤១ ទំព័រទី ៧៦) ។
    - ស្ថានទម្ងន់ទោសដោយសារការកាត់អវៈយវៈ ឬពិការភាព ៖ ជាបទល្មើសរំលោភសេពសន្ថវៈដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវៈយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៤២ ទំព័រទី ៧៦) ។
    - ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ ៖ ជាបទល្មើសរំលោភសេពសន្ថវៈដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៤៣ ទំព័រទី ៧៦) ។

- ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ៖ គឺជាបទល្មើសរំលោភសេពសន្ថវៈដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់ (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៤៤ ទំព័រទី ៧៧) ។

○ **ទោសបន្ថែម** ៖ ចំពោះបទឧក្រិដ្ឋនៃបទល្មើសរំលោភសេពសន្ថវៈ ទោសបន្ថែមមានដូចតទៅ ៖

- ការដកសិទ្ធិជាពលរដ្ឋជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន
- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន
- ការហាមឃាត់ចំពោះការស្នាក់នៅសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន
- ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន
- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២៤៥ ទំព័រទី ៧៧) ។

## ខ. អំពើហិង្សាក្នុងគ្រួសារនៅលើស្ត្រី

រាល់ការកើតមានឡើងនូវអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានរាប់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោសដោយផ្អែកទៅលើច្បាប់ព្រហ្មទណ្ឌជាធរមាន ។

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលានរៀល) ទៅ ១០.០០០.០០០ (ដប់លានរៀល) កាលបើអំពើហិង្សានេះ ត្រូវបានប្រព្រឹត្តដោយសហព័ទ្ធ ឬដោយអនីតិសង្វាសជនរបស់ជនរងគ្រោះ (ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ មាត្រា ២២២ ទំព័រទី ៦៨) ។

## ២.២- បទពិសោធន៍ដែលពាក់ព័ន្ធទៅនឹងការរំលោភបំពាន

### ២.២.១- មូលហេតុនៃការរំលោភបំពាន

### ក. ការរំលោភសេពសន្ថវៈ

– **កត្តាផ្ទាល់នៃបុគ្គលល្មើស**

○ **ហ្សែន (Gene) របស់ជនល្មើស**

ដោយយោងទៅតាមការសិក្សាស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រទាក់ទងទៅនឹង ហ្សែន របស់មនុស្ស បានបង្ហាញឱ្យយើងដឹងកាន់តែច្បាស់តាមរយៈសៀវភៅ ជីវៈវិទ្យា ថ្នាក់ទី ១១ និងទី ១២ (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៤៦) ។ នៅក្នុងសៀវភៅទាំងពីរនោះបានលើកឡើងថា **កូនដែលកើតមកពីឪពុកម្តាយត្រូវទទួលនូវ ហ្សែន ដែលកំណត់លើ រូបរាងកាយ មុខមាត់ សម្បុរ ព្រមទាំង អាកប្បកិរិយា និងចិត្តគំនិត** ។ ដោយយោងទៅលើ Adler Mueller និងLauffer បានលើកឡើងថា ប្រសិនបើឪពុកម្តាយ ជាមនុស្សប្រភេទដូចជា **ជនបោកប្រាស់ ចោរកម្ម ជនល្មោភកាម ឬចូលចិត្តប៉ះពាល់កេរខ្មាសរបស់អ្នកដទៃ** នោះកូនចៅរបស់ពួកគេដែលមានកំណើតមកដោយមានជាប់មកជាមួយនឹង ហ្សែន មិនល្អទាំងនេះមកផងដែរ ។ នៅពេលពួកគេធំឡើងពួកគេនឹងអាចមានអាកប្បកិរិយា ឬកាយវិការផ្សេងៗឆ្លើយតបទៅនឹងមជ្ឈដ្ឋានជុំវិញខ្លួនរបស់ពួកគេ ដែលជាហេតុអាចធ្វើឱ្យពួកគេនឹងប្រព្រឹត្តរឿងមិនល្អទាក់ទងទៅនឹងរំលោភសេពសន្ថវៈជាដើម (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៤៧)។

○ **កត្តាអាយុ (Age) របស់បុគ្គលល្មើស**

តាមរយៈការស្រាវជ្រាវនៃ មាស សោភា និងលី មួយទៀង បានបង្ហាញឱ្យឃើញថា អាយុក៏ជាកត្តាមួយដែលអាចបង្កើតឱ្យមានការរំលោភបំពានផងដែរ ដោយហេតុនៅក្នុងដំណាក់កាលដែលពួកគេមានអាយុវ័យក្មេង ពួកគេឆាប់ទទួលយកនូវអ្វីៗទាំងឡាយណាដែលកើតឡើងចំពោះគេខ្លាំង ។ «ឧទាហរណ៍ ៖ ការមើលវីដេអូអាសអាភាស ធ្វើឱ្យអារម្មណ៍ផ្លូវភេទរបស់ពួកគេមានភាពពុះកញ្ជ្រោលជាងមនុស្សចាស់ ហើយអាចឈានទៅដល់ការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ» ។ម្យ៉ាងវិញទៀត យុវវ័យក្មេងៗ ពួកគេតែងតែមានភាពផុយស្រួយខាងផ្នែកខួរក្បាល និងមានទំនោរទៅរកការធ្វើអ្វីដូចគេក្នុងការប្រព្រឹត្តបទល្មើស «ធ្វើអាកប្បកិរិយារួមភេទដូចទៅនឹងវីដេអូអាសអាភាសដែលគេបានមើល» ក៏ដូចជាអាកប្បកិរិយាជាទូទៅ (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៤៧) ។

– **កត្តាសង្គម**

○ **ការអប់រំ**

នៅក្នុងពេលបច្ចុប្បន្ននេះ ស្ត្រីកំពុងស្ថិតក្នុងអន្តរភាពមួយចំនួននៅឡើយដោយសារតែទស្សនៈរបស់ប្រជាជនខ្មែរមួយចំនួននៅប្រកាន់ភ្ជាប់នូវទស្សនៈ ស្ត្រីមិនគួទៅណាឆ្ងាយពីផ្ទះសម្លៀងឡើយ (ស្ត្រីបង្វិលចង្រ្កានមិនជុំ) ហើយពួកគេក៏ពុំចាំបាច់រៀនសូត្រច្រើនពេកដែរ ឯបុគ្គលខ្លះទៀតយល់ឃើញថា ការសិក្សានឹងពុំបានផ្តល់ផលប្រយោជន៍ជាក់ស្តែងមកឱ្យពួកគេឡើយ ដោយទស្សនៈបែបនេះហើយដែលបណ្តាល

ឱ្យពួកគេងាយនឹងក្លាយខ្លួនជាជនរងគ្រោះក្នុងអំពើរំលោភសេពសន្ថវៈ (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៤៨) ។

○ **ភាពក្រីក្រ**

កត្តាភាពក្រីក្រក៏ជាប្រភពមួយដែលបង្កើតនូវបញ្ហាអវិជ្ជមានជាច្រើននៅក្នុងសង្គមថែមទៀតផង ។ ជាក់ស្តែង ដើម្បីបញ្ចៀសខ្លួនពីភាពក្រីក្រ និងដោះស្រាយនូវបញ្ហាភាពអត់ឃ្លាន ក្នុងនោះយើងសង្កេតឃើញថា មានអាណាព្យាបាលមួយចំនួនបានសម្រេចចិត្តទាំងបង្ខំក្នុងការបញ្ជូនកូនរបស់ខ្លួនឱ្យទៅធ្វើការនៅតាមភោជនីយដ្ឋាន សណ្ឋាគារ ក្លឹបរាត្រី ឬហាងខារ៉ាអូខេ ដែលជាកន្លែងមួយងាយនឹងទទួលរងនូវការរំលោភបំពានខ្ពស់ជាងគេ ហើយពេលខ្លះពួកគេអាចឈានទៅដល់ការលក់កូនស្រីទៅឱ្យធ្វើជាស្រីពេស្យាថែមទៀតផង (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៤៩) ។

○ **គ្រឿងញៀន ឬគ្រឿងស្រវឹង**

ចំពោះបញ្ហាគ្រឿងញៀន និងគ្រឿងស្រវឹងក៏ជាមូលហេតុដ៏សំខាន់មួយក្នុងការជំរុញឱ្យបុគ្គលមួយចំនួនដែលបានធ្លាក់ខ្លួនប្រើប្រាស់ អាចនឹងប្រព្រឹត្តិអំពើមិនគប្បីបានផងដែរ ហើយអាចនឹងឈានដល់ការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ ។ តាមការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្របានឱ្យដឹងថា កាលណាមនុស្សបានសេពគ្រឿងញៀន ឬគ្រឿងស្រវឹងចូលក្នុងខ្លួនរបស់គេហើយ ឥទ្ធិពលនៃសារធាតុញៀន ឬសារធាតុស្រវឹង នឹងជំរុញបង្កើនចំណង់ផ្លូវភេទដែលមានលក្ខណៈខុសពីប្រក្រតី ។ ម្យ៉ាងវិញទៀត កាលណាដែលស្ត្រីបានសេពនូវគ្រឿងញៀន ពួកគេអាចធ្វើឱ្យខ្លួនពួកគេធ្លាក់ចូលទៅក្នុងការរំលោភផ្លូវភេទតាមរយៈការដោះដូរជាថ្នូរទៅនឹងការបានគ្រឿងញៀន ដើម្បីមករំងាប់អារម្មណ៍របស់ពួកគេ (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៤៩) ។

○ **លំហូរចូលនៃវប្បធម៌បរទេស**

ដោយសារតែប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ហេតុនេះហើយទើបមានការហូរចូលនៃវប្បធម៌បរទេសជាច្រើន ដោយក្នុងនោះមានទាំងវប្បធម៌មិនសូវសមរម្យមកលាយឡំជាមួយផងដែរ ។ បើយើងនិយាយឱ្យខ្លីមក គឺស្ត្រីខ្មែរយើងមួយចំនួនបានចាប់ផ្តើមងាកមករកការស្លៀកពាក់បែបស៊ិចស៊ីបញ្ចេញសាច់ខ្លី ដែលនេះអាចរុញច្រានឱ្យជនដែលប្រព្រឹត្តសម្រេចចិត្តប្រព្រឹត្តអំពើបំពានខាងផ្លូវភេទ (រំលោភសេពសន្ថវៈ ឬប្រទូស្តកេរខ្មាស) ទៅលើជនដែលជាស្ត្រីនោះផងដែរ (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៥០) ។

○ **ប្រព័ន្ធផ្សព្វផ្សាយ**

ដូចដែលមនុស្សទូទាំងពិភពលោកបានដឹងហើយថា បច្ចុប្បន្ននេះការអភិវឌ្ឍលើបច្ចេកវិទ្យាទំនើបៗបានធ្វើឱ្យប្រព័ន្ធនៃការផ្សព្វផ្សាយ (វិទ្យុ ការសែត ទស្សនាវដ្តី ទូរទស្សន៍ និង ប្រព័ន្ធអ៊ិនធឺណេត "Internet") មានលក្ខណៈធំទូលាយ និងរហ័សជាងមុន វាបានបន្ថែមនូវភាពងាយស្រួលក្នុងការចែករំលែកនូវព័ត៌មាន និងឯកសារផ្សេងៗដ៏សម្បូរបែប ។ ក្នុងនោះដែរ មានឯកសារជារូបភាព ឬវីដេអូអាសអាភាសមួយចំនួនត្រូវបានបង្ហាញនៅតាមប្រព័ន្ធផ្សព្វផ្សាយទាំងនោះផងដែរ ។ កត្តានេះ ធ្វើឱ្យអ្នក

ដែលបានឃើញហើយមានអារម្មណ៍ពុះកញ្ជ្រោលបង្កើតអារម្មណ៍ផ្លូវភេទ ។ ពេលខ្លះដោយហេតុថាមិនអាចទប់អារម្មណ៍បាន ជនមួយចំនួនបានសម្រេចចិត្តធ្វើអំពើមិនគប្បីជាច្រើនដូចជា រំលោភសេពសន្ថវៈ ប្រទូស្តកេរខ្មាស ឬអំពើរុកគួនផ្លូវភេទជាដើម (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៥១) ។

◦ **និកម្មភាព**[3]

ជាការពិតណាស់ ដោយសារតែប្រទេសកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍន៍ ជាហេតុធ្វើឱ្យកម្ពុជានៅមានភាពទន់ខ្សោយខាងវិស័យមួយចំនួនដូចជា វិស័យឧស្សាហកម្ម ពាណិជ្ជកម្ម ជាពិសេសវិស័យសេដ្ឋកិច្ច ដូច្នេះហើយរដ្ឋាភិបាលពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ដើម្បីបង្កើតការងារឱ្យប្រជាជនខ្លួនធ្វើបានគ្រប់គ្រាន់នៅឡើយទេ ។ ជាងនេះទៅទៀត បញ្ហាទាំងអស់នេះហើយដែលនាំឱ្យប្រជាជនជួបប្រទះនឹងបញ្ហាគ្មានការងារធ្វើ គ្មានប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ បណ្តាលឱ្យជីវភាពរស់នៅត្រូវខ្វះខាត និងជួបផលវិបាកផ្សេងៗ រហូតក្លាយជាកត្តាជំរុញឱ្យជនមួយចំនួនប្រព្រឹត្តអំពើជួញដូរមនុស្សក្នុងគោលដៅកេងប្រវ័ញ្ចលើផ្លូវភេទ (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៥២) ។

◦ **អំពើពុករលួយ**

ការចងគ្នាជាបក្សពួកនៅតាមស្ថាប័នផ្សេងៗ ពិសេសស្ថាប័នដែលអនុវត្តច្បាប់ គឺជាកង្វល់មួយដ៏ធំរបស់ប្រជាពលរដ្ឋ ហើយក៏ជាបន្ទុកមួយដ៏សំខាន់ដែលត្រូវតែដោះស្រាយដោយរដ្ឋាភិបាលផងដែរ ។ ដោយឡែកការបន្តនិទណ្ឌភាព[4] ដូចជាការទទួលយកនូវលុយដែលជាការស៊ីសំណូករបស់ជនល្មើស ការឃោគយល់ចំពោះសាច់ញាតិខ្លួនឯងដែលជាជនល្មើស ការមិនអើពើចំពោះជនរងគ្រោះក្នុងករណីដែលខ្លួនពុំទទួលបាននូវផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ គឺជាមូលហេតុមួយដែលនាំឱ្យមានការកើនឡើងនៃបទល្មើសរំលោភបំពានទៅលើស្ត្រីភេទ (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៥២) ។

◦ **សម្ភារនិយម**

កត្តានេះនឹងជំរុញឱ្យជនមួយចំនួនមានចិត្តចង់បាននូវអ្វីដែលទំនើបអស្ចារ្យដូចជា ម៉ូតូថ្មី រថយន្តទំនើប ឬសម្ភារប្រើប្រាស់ល្អៗផ្សេងទៀត ព្រោះគេយល់ថា បើគេបានវត្ថុទាំងអស់នេះដើម្បីទទួលបានការកោតសរសើរពីអ្នកដទៃ ដែលទាំងអស់នេះត្រូវបានគេហៅថា ភាពលោភលន់ (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៥៣) ។ ពិតណាស់បុគ្គលមួយចំនួនដោយហេតុថាចង់បាននូវសម្ភារទាំងអស់នោះ ពេលខ្លះពួកគេបានស្ម័គ្រចិត្តឱ្យជនល្មើសធ្វើរំលោភសេពសន្ថវៈលើខ្លួន ។

◦ **ការខ្វះខាតចំណេះដឹងលើវិស័យច្បាប់**

ជានិច្ចកាល ច្បាប់រមែងតែងតែដាក់ទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្ត ផ្ទុយទៅវិញ ដោយសារខ្វះខាតនូវចំណេះដឹងច្បាប់ បានធ្វើឱ្យជនរងគ្រោះស្ទើរតែពាក់កណ្តាលបានជ្រើសរើសយកកម្មវិធីស្ងៀមស្ងាត់ ឬភ័យខ្លាច ហើយព្យាយាមលាក់កំបាំងហេតុការណ៍ដែលបានកើតឡើងចំពោះខ្លួន មិនហ៊ានប្រាប់

---

[3] និកម្មភាព មានន័យថា ភាពគ្មានការងារធ្វើ

[4] និទណ្ឌភាព គឺជាការដែលអាជ្ញាធរដោះលែងនរណាម្នាក់អោយរួចផុតពីទោស

ឪពុកម្ដាយ និងអ្នកជទៃ ឬវាយការណ៍ទៅសមត្ថកិច្ចឱ្យចុះជួយអន្តរាគមន៍នៅពេលដែលជនល្មើសបានរំលោភសេពសន្ថវៈមកលើខ្លួន (មាស សោភា និង លី មួយទៀង ឆ្នាំ ២០១២ ទំព័រទី ៥៣) ។

### ខ. អំពើហិង្សាក្នុងគ្រួសារលើស្ត្រី

អំពើហិង្សាក្នុងគ្រួសារ តែងតែកើតមានឡើងគ្រប់ប្រទេសទាំងអស់នៅក្នុងពិភពលោកយើងនេះ ហើយវាកើតឡើងគ្រប់ជាតិសាសន៍ និងពណ៌សម្បុរ ហើយមានរូបភាពគ្រប់ប្រភេទដូចជា អំពើហិង្សាលើរូបរាងកាយ អំពើហិង្សាលើផ្លូវចិត្ត អំពើហិង្សាផ្នែកផ្លូវភេទ និងអំពើហិង្សាផ្នែកសេដ្ឋកិច្ច ដែលកើតមានឡើង ។ ប៉ុន្តែប្រទេសខ្លះមានការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារមានកម្រិតទាប (សាន និមល ផុន សុនឡាន់ ស្រីអន និង ប៊ុត កីឡា ឆ្នាំ ២០១៨ ទំព័រទី ២៦-២៧ និង រិន ឆ្លាម មួន ម៉ារី ម៉ៅ ស្រីវួត និង មិច សុភា ឆ្នាំ ២០១៧ ទំព័រទី ២៦-២៧) ។

ជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជាយើង អត្រានៃការប្រព្រឹត្តអំពើហិង្សាគឺមានអត្រាខ្ពស់បើធៀបជាមួយប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ ដែលការកើតឡើងនៃអំពើហិង្សាក្នុងគ្រួសារ គឺមានមូលហេតុមួយចំនួនដូចជា ៖

- ការមិនចេះអធ្យាស្រ័យអត់ឱនឱ្យគ្នាទៅវិញទៅមកក្នុងគ្រួសារ ជាពិសេសបុរសជាប្ដី
- បុរសជាប្ដីដើរតួនាទីជាបុរសខ្លាំងនៅក្នុងគ្រួសារ ហើយវាយបង្ក្រាបប្រពន្ធកូនប្រសិនបើប្រពន្ធកូនធ្វើអ្វីមួយមិនដូចការបញ្ជារបស់ខ្លួន
- ការគុំគួន ការប្រចណ្ឌរបស់ប្ដី ហើយរករឿងវាយតប់ប្រពន្ធកូន
- ការសេពសុរាស្រវឹង ហើយយកលេសដើម្បីរករឿង និងវាយប្រពន្ធកូន ដែលពេលខ្លះអាចពិការឬបាត់បង់ជីវិត ។ មូលហេតុផ្សេងទៀត គឺមកពីភាពក្រីក្រខ្វះខាត និងការអប់រំរបស់ពួកគាត់នៅមានកម្រិតទាប រួមទាំងការអប់រំផ្សព្វផ្សាយពីច្បាប់នៅមានកម្រិត ។ លើសពីនេះទៅទៀត អំពើហិង្សាអាចកើតឡើងដោយសារការទាក់ទាញលុយកាក់ សម្ភារទំនើប អំពើបៀតបៀនពីសមាជិកគ្រួសារ តំបន់ស្ងាត់ងាយស្រួលក្នុងការរំលោភបំពាន (សាន និមល ផុន សុន ឡាន់ ស្រីអន និង ប៊ុត កីឡា ឆ្នាំ ២០១៨ ទំព័រទី ២៦-២៧ និង រិន ឆ្លាម មួន ម៉ារី ម៉ៅ ស្រីវួត និង មិច សុភា ឆ្នាំ ២០១៧ ទំព័រទី ២៦-២៧) ។

## ២.២.២- យន្តការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

### ក. ដំណោះស្រាយជម្លោះនៅក្នុងគ្រួសារ

- **ពាហិរនៃប្រព័ន្ធច្បាប់**

ពាហិរនៃប្រព័ន្ធច្បាប់ គឺជាដំណោះស្រាយអំពើហិង្សាក្នុងគ្រួសារ ដោយការសម្រុះសម្រួលពីសាច់ញាតិទាំងសងខាង ឬសាច់ញាតិខាងប្ដី ឬសាច់ញាតិខាងប្រពន្ធក្នុងពេលដែលអវត្តមានក្រុមញាតិខាងណាមួយ ឬតាមរយៈមេភូមិ និងរដ្ឋអំណាចមូលដ្ឋាន ក្នុងនោះមានជាអាទិ៍ ក្រុមប្រឹក្សាឃុំ/សង្កាត់ ។ ដំណោះស្រាយបែបនេះ គឺជាយន្តការក្រៅប្រព័ន្ធតុលាការ ។ អារម្មណ៍របស់មនុស្សបានដក់ជាប់នៅក្នុង

គ្រួសារ ហើយគ្រួសារគឺជាឯកតាមូលដ្ឋាននៅក្នុងសង្គម ។ តម្រូវការជីវសាស្ត្រ និងចិត្តសាស្ត្រជាច្រើនដែលវិទ្យាសាស្ត្រពុំអាចបំពេញដោយគ្រួសារបានទេ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១១៦) ។

ឪពុកម្តាយ សាច់ញាតិ និងអ្នកជិតខាងគឺជាអ្នកមានឥទ្ធិពលលើប្តី ឬប្រពន្ធ ដែលភាគីទាំងពីរទទួលយកបាន មានតួនាទីសំខាន់ក្នុងការផ្សះផ្សាជម្លោះក្នុងគ្រួសារ ប៉ុន្តែពេលខ្លះគេបានមើលរំលងនៃតួអង្គនេះ ។ ការបំភ្លេចតួនាទីនេះបណ្តាលឱ្យខ្វះទិន្នន័យនៃចំនួនជំណោះស្រាយតាមរយៈញាតិសណ្តាន និងអ្នកជិតខាង ពីព្រោះទម្លាប់គ្រួសារខ្មែរមិនចង់ឱ្យអ្នកក្រៅដឹងរឿងផ្ទៃក្នុងគ្រួសាររបស់ខ្លួនឡើយ ។ មនុស្សជាច្រើនដែលពាក់ព័ន្ធ និងអំពើហិង្សាក្នុងគ្រួសារគិតថា នេះជាបញ្ហាឯកជន ហើយព្យាយាមដោះស្រាយដោយខ្លួនឯង ឬតាមរយៈមធ្យោបាយនៅតាមមូលដ្ឋាន និងតាមរបៀបក្រៅផ្លូវការ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១១៧) ។

អំពើហិង្សាក្នុងគ្រួសារ បើយើងឆ្លុះបញ្ចាំងតាមរយៈឧក្រិដ្ឋវិទ្យាបានបង្ហាញប្រាប់យើងថា សង្គមគ្រួសារមានលក្ខណៈជាប្រព័ន្ធប្រទាក់ក្រឡាចាក់ស្រេះស្មុគស្មាញយ៉ាងជ្រាលជ្រៅ ។ ដោយឡែកគ្រួសារខ្មែរតាំងពីបុរាណរហូតដល់បច្ចុប្បន្ន ប្រពៃណី ទំនៀមទម្លាប់ វិន័យក្នុងគ្រួសារ មានច្បាប់ប្រុស និងច្បាប់ស្រី ដែលជាសំណេររបស់កវីនិពន្ធខ្មែរបានដាក់ទម្ងន់ទៅលើស្ត្រី និងអ្នកក្នុងបន្ទុក ។ ក្បួនខ្នាតខ្លះបាននិយាយថា គុណឪពុកមាន ២១ គុណម្តាយមានត្រឹមតែ ១២ ។ មនុស្សប្រុសមានដើមទ្រូងប្រាំហត្ថធំជាងស្ត្រី ។ នៅក្នុងពិធីអាពាហ៍ពិពាហ៍ របៀបរបបពិធីការមានលក្ខណៈស្មុគស្មាញ ដឹកនាំដោយលោកអាចារ្យ និងចៅមហាជាបុរស ។ តាមទស្សនៈរបស់យើង ស្ត្រីខ្មែរហាក់ដូចជាស្រឡាញ់ប្រពៃណីនេះបណ្តោយខ្លួនតាមប្រុសៗ ។ ប៉ុន្តែចំណុចខ្លះហាក់ដូចជាឱ្យតម្លៃដល់ស្ត្រីខ្មែរខ្លាំងណាស់ដែរ ដូចជាការបង្គាប់ថ្លៃទឹកដោះ គឺពេលចូលស្តីដណ្តឹងមុនពេលរៀបអាពាហ៍ពិពាហ៍ ។ ពាក្យសួ្បថស្បែរមុនពេលរៀបអាពាហ៍ពិពាហ៍ ឬមុនចងសម្ព័ន្ធមេត្រីរវាងកូនកំលោះ និងកូនក្រមុំថា "ស្មោះត្រង់ជាមួយគ្នាគ្មានប្រែចិត្តងាករេទៅស្រឡាញ់ស្រីដទៃទៀតឡើយ" ។ តាមពិត សម្បថនេះប្រែប្រួលទៅតាមរយៈពេលមួយដែលពុំបានស្មានដល់ ដោយសារតែចិត្តមានការប្រែប្រួល(អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១១៧) ។

ព្រះពុទ្ធជាអម្ចាស់បានចង្អុលប្រាប់យើងថា ចិត្តជាដើមហេតុ ជាឫសគល់នៃលោភៈ ទោសៈ មោហៈ ។ អ្នកដែលខ្លាំងពូកែធ្វើសង្គ្រាម ច្បាំងឈ្នះសត្រូវរាប់ម៉ឺនរាប់សែនសមរភូមិរហូតដល់គ្រប់គ្រងពិភពលោកបានទៀតផង ប៉ុន្តែគេពុំប្រាកដថាជាអ្នកខ្លាំងក្លា អស្ចារ្យនោះដែរ ។ ផ្ទុយទៅវិញ "អ្នកខ្លាំងពិតគឺអ្នកដែលគ្រប់គ្រងចិត្តខ្លួនឯងបាន ទើបជាអ្នកខ្លាំងពិត" ។ ក្រៅពីនេះមនុស្សម្នាក់ៗគួរចាកចេញឱ្យឆ្ងាយពីធម៌អគតិ ៤ យ៉ាងគឺ ១.លំអៀងព្រោះស្រឡាញ់ ២.លំអៀងព្រោះស្អប់ ៣.លំអៀងព្រោះអាណិត ៤.លំអៀងព្រោះខ្លាច ។ បើបុគ្គលណាប្រាសចាកបាននូវធម៌ ៤ យ៉ាងនេះ ប្រាស់ចាកនូវទំនាស់ហើយទទួលនូវសេចក្តីសុខ ។ បើយើងបានសុខហើយគប្បីផ្តល់សេចក្តីសុខនោះដល់អ្នកដទៃផង នោះលោកបានសុខរហូតប្រៀបបានលោកអ្នកលើកដៃសំពះគេ គេសំពះអ្នកវិញ ឬបើអ្នកលើកដៃសំពះកញ្ចក់ នោះប្រាកដជាកញ្ចក់សំពះលោកអ្នកវិញជានិច្ច (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១១៨) ។

ទន្ទឹមនេះ ព្រះពុទ្ធជាអម្ចាស់បានទូន្មានឱ្យយើងប្រកាន់យកនូវមជ្ឈិមាបដិទា គឺជាអព្យាកតាធម៌មានន័យថា កុំស្រឡាញ់ពេក កុំហួងហែងពេក កុំប្រចណ្ឌពេក កុំអាណិតពេក កុំស្អប់ពេក កុំរំភើបពេក កុំហ៊ានពេក កុំខ្លាចពេក កុំសប្បាយពេក កុំព្រួយកើតទុក្ខពេក កុំឃ្លានពេក កុំល្មោភពេក កុំឆ្ងាញ់ពេក កុំកាចពេក កុំស្លូតពេក ។ ធម៌ទាំងឡាយនេះច្រើនតែនាំមកនូវសេចក្តីវិនាសព្រាត់ប្រាស់ ។ ជាមួយនេះ លោកក៏បានអប់រំឱ្យតាំងចិត្តឱ្យស្ងប់នោះទើបបានសេចក្តីសុខ ។ "នត្ថ សន្តិ បរំ សុខំ" "គ្មានសេចក្តីសុខណាប្រសើរជាងសេចក្តីស្ងប់ឡើយ" (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១១៨) ។

ជាងនេះទៅទៀត សង្គមវិទ្យាវិទូបានឱ្យនិយមន័យថា "មនុស្សគឺជាសត្វដែលមានបញ្ញាឆ្លាតជាងសត្វទាំងពួង ខួរក្បាលរបស់មនុស្សអភិវឌ្ឍន៍មិនឈប់ឈរមានតណ្ហាមិនចេះចប់" ។ មនុស្សខុសស្រឡះពីសត្វទាំងពួងត្រង់មនុស្សមានតម្រូវការមិនចេះស្កប់ស្កល់នូវចំណីអាហារឆ្ងាញ់ប្លែកមាត់ មានជម្រកលំនៅឋានស្អាត ក្លិនឈ្ងុយ សម្ផស្ស ឬសោភណ្ឌភាព ព្រមទាំងសម្ភារប្រណិតផ្សេងៗទៀត ។ មនុស្សចង់បាន និងចង់មានសិទ្ធិសេរីភាពដោយគ្មានព្រំដែន មនុស្សចង់បានអ្វីៗលើពិភពលោកធ្វើជាកម្មសិទ្ធិរបស់គេ រហូតចង់ត្រួតត្រាពិភពលោកទាំងមូលទៀតផង ។ នេះជាមហិច្ឆតារបស់មនុស្សគេមានមោទនភាពចំពោះខ្លួនគេណាស់ ។ ចំពោះប្តីប្រពន្ធរស់នៅក្រោមអាពាហ៍ពិពាហ៍ស្របច្បាប់ បើមិនទុកចិត្តគ្នាមិនស្មោះត្រង់ចំពោះគ្នា ពិសេសកុហកគ្នា ដោយឡែកបញ្ហាលុយកាក់លាក់លាមគ្នាមានក្នុងមានក្រៅ បណ្តាលឱ្យម្នាក់ៗកើតសង្ស័យគ្នាដកសេចក្តីស្រឡាញ់ពីគ្នាធ្វើឱ្យភាគីម្ខាងៗឈឺចិត្ត ហ៊ានធ្វើអត្តឃាត ឬហ៊ានសម្លាប់ដៃគូ ។ គំនុំសងសឹករវាងប្តី និងប្រពន្ធ ការស្តីបន្ទោស ការវាយដំ ការមិនគោរពគ្នា មិនស្តាប់គ្នា ចាំតែចាប់កំហុស ការប្រចណ្ឌ ភាពអវិជ្ជមាន ភាពក្រីក្រ ភាពគ្មានការងារធ្វើ ការលេងល្បែងស៊ីសង ការសេពគ្រឿងស្រវឹង ការប្រើប្រាស់គ្រឿងញៀន ការផិតក្បត់ ខ្វះវិធីគ្រប់គ្រងកំហឹងរបស់ខ្លួន មិនចេះទប់កំហឹងខ្វះមេត្តា ឬអធ្យាស្រ័យដល់គ្នា គ្មានការយោគយល់ គ្មានការអត់ឱនឱ្យគ្នា ខ្វះការពិចារណា ខ្វះការអប់រំ គ្មានសីលធម៌ គ្មានសុជីវធម៌ គ្មានសេចក្តីថ្លៃថ្នូរ ម្នាក់ៗចង់ឈ្នះគ្នា កឹបកេងទ្រព្យសម្បត្តិរួម មិនស្តាប់ហេតុផល មិនចេះជួយគ្នាទៅវិញទៅមកក្នុងគ្រួសារ មានចំណង់ផ្លូវភេទ មិចចេះសម្របសម្រួលខ្លួន យកហិង្សាដោះស្រាយទំនាស់ ចង់បានអំណាច និងត្រួតត្រាលើសមាជិកក្នុងគ្រួសារ ចង់ឱ្យគេគោរពកោតខ្លាច និងធ្វើតាមតម្រូវការរបស់ខ្លួន ចង់បង្ហាញថាខ្លួនជាមនុស្សខ្លាំងពូកែគ្មាននរណាអាចគ្រប់គ្រងខ្លួនបានឡើយ និងឱ្យគេស្តាប់តាមការបង្គាប់បញ្ជារបស់ខ្លួន ។ គ្រួសារទាំងឡាយណាដែលមានចំណុចទាំងនេះ គ្រួសារនោះគ្មានសេចក្តីសុខទេ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១១៩) ។

ដូចនេះ ដើម្បីគ្រប់គ្រងខ្លួនឯងបាន មនុស្សត្រូវអនុវត្តនូវធម៌ ៤ យ៉ាង គឺប្រើបញ្ញា ខិតខំធ្វើសមាធិដោយប្រកាន់ខ្ជាប់នូវវិរិយៈ និងខន្តីធម៌ ដែលជាធម៌ដ៏ប្រសើររបស់ព្រះពុទ្ធជាអម្ចាស់ ។ ព្រះពុទ្ធប្រៀនប្រដៅទៀតថា "មនុស្សម្នាក់ៗត្រូវស្គាល់ខ្លួនឯងឱ្យបានច្បាស់ ពិសេសស្គាល់ និងក្តាប់ឱ្យបាននូវតួនាទីរបស់ខ្លួន"(អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១១៩) ។

មនុស្សខ្លះ អ្វីក៏ហ៊ានធ្វើដែរ ដើម្បីបានទទួលពាក្យថាឈ្នះ តាមពិតពាក្យចាស់ពោលថា "ចាញ់បានជាព្រះ ឈ្នះបានជាមារ" "ក្ដៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ" ។ ពុទ្ធឱវាទ និងពាក្យចាស់ទាំងនេះបានចូលរួមក្នុងការកាត់បន្ថយ អំពើហិង្សាក្នុងគ្រួសារ ។ ព្រះពុទ្ធប្រៀនប្រដៅឱ្យប្រកាន់ខ្ជាប់នូវសីលប្រាំ ៖

- បាណា ៖ មិនឱ្យសម្លាប់សត្វ ឬមនុស្ស
- សុរា ៖ មិនឱ្យផឹកទឹកស្រវឹង និងថ្នាំញៀនជាដើម
- មុសា ៖ មិនឱ្យកុហក កុហក់ ត្រូវស្មោះត្រង់នឹងគ្នា
- កាមេ ៖ មិនឱ្យលួចប្ដី ប្រពន្ធ និងកូនរបស់គេ
- អទនាទាន ៖ កុំចង់បានទ្រព្យសម្បត្តិគេ ដែលម្ចាស់គេពុំបានយល់ព្រមឱ្យយើង បើយើងម្នាក់ៗអនុវត្តបានជាប្រចាំតាមសីលប្រាំនេះប្រាកដជាបានសេចក្ដីសុខក្នុងគ្រួសារ និងក្នុងសហគមន៍ ហើយវាស្របតាមអត្ថន័យរបស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងចម្រៀងជាតិ (នគររាជ) ផងដែរ ។

ជាការពិត សេចក្ដីសុខក្នុងគ្រួសារជាតម្រូវការចាំបាច់ បើគ្រួសារមានសេចក្ដីសុខ សហគមន៍សុខសាន្ត ហើយពិភពលោកក៏មានសន្តិភាពតាមនោះដែរ ។ កត្តាសន្តិភាពជាកត្តាសំខាន់ និងចាំបាច់សម្រាប់ការអភិវឌ្ឍពិភពលោក ។ ការកសាងគ្រួសាររឹងមាំ ជួយពិភពលោកឱ្យរឹងមាំ ។ ទស្សនៈវិទូជាច្រើនបានយកចិត្តទុកដាក់ក្នុងការកសាងគ្រួសារ ដោយចាត់ទុកគ្រួសារជាកោសិការចម្បងរបស់សង្គម ។ តាមរយៈគំនិតមួយនេះបុព្វបុរសបង្កើតនូវចំណងរវាងបុរស និងស្ត្រីដែលប្រាថ្នារួមរស់ជាមួយគ្នាតាមវិធីអាពាហ៍ពិពាហ៍ ។ អាពាហ៍ពិពាហ៍នៅក្នុងប្រទេសជាច្រើនគេចាត់ទុកថាវាមានទំនាក់ទំនងអចិន្ត្រៃយ៍យូរ ឬឆាប់យោងតាមប្រពៃណីរបស់ពួកគេ ប៉ុន្តែកម្រិតទំនាក់ទំនងនេះ បន្ទាប់ពីពិធីរៀបអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីមានការប្រែប្រួលអាស្រ័យដោយវប្បធម៌នៃតំបន់នីមួយៗ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២០) ។

ជាមួយគ្នានេះ បុព្វបុរសយើងបានណែនាំអប់រំកូនចៅមិនឱ្យធ្លាក់ចូលក្នុងប្រភេទមនុស្ស ធ្លួតបីយ៉ាងគឺ ១. ធ្លួតនឹងស្រា ២.ធ្លួតនឹងស្រី ៣. ធ្លួតនឹងល្បែងពាលា ដែលមានចែងក្នុងច្បាប់កូនចៅ "លោកថាធ្លួតបី ធ្លួតមួយនឹងស្រី ធ្លួតមួយនឹងស្រា ធ្លួតមួយនឹងល្បែងអំពើពាលា ធ្លួតនេះហៅថា មហាធ្លួតក្រៃកន្លង" (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២២) ។

គន្លឹះដោះស្រាយនេះអ្នកទី ៣ បានយកមកប្រើប្រាស់សម្រាប់អប់រំភាគីទំនាស់ណាមួយដែលពាក់ព័ន្ធខាងលើ ដើម្បីឱ្យភាគីបោះបង់ ឬកែប្រែជាមនុស្សល្អ ដូចជា កាត់បន្ថយការផឹកស្រា មិនប្រើប្រាស់គ្រឿងញៀន ឬទំនាក់ទំនងស្រីញីផ្ដេសផ្ដាស់ ការខ្វះការអធ្យាស្រ័យគ្នា នឹងអំពើផ្សេងៗទៀតដែលបានពោលខាងលើ ហើយភាគី ឬសមាជិកផ្សេងទៀតក្នុងគ្រួសារទទួលយកបានដោយសុខចិត្តតាមការណែនាំដោយអ្នកទី ៣ ដែលមានជាអាទិ៍ ឪពុកម្ដាយ ក្រុមញាតិ មេភូមិ ឬអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ ។ តាមការស្រាវជ្រាវរបស់លោក អ៊ុក គង់ បានចង្អុលបង្ហាញប្រាប់ថា អ្នកទី ៣ ដូចជា អ្នកជិតខាង មេភូមិ ឬក្រុមប្រឹក្សាឃុំ/សង្កាត់ បានយកមកប្រើប្រាស់ជាឧបករណ៍សម្រាប់ការផ្សះផ្សាអំពើហិង្សាក្នុងគ្រួសារ ដែលជនល្មើសធ្វើសកម្មភាពប៉ះពាល់ចំពោះច្បាប់សង្គមដែលជាច្បាប់របស់ជាតិ និងច្បាប់អន្តរជាតិ ពិសេស

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងជំពូកទី ៣ ត្រង់មាត្រា ៣១ មាត្រា ៣២ មាត្រា ៣៤ មាត្រា ៣៥ មាត្រា៣៦ មាត្រា ៣៨ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ មាត្រា ៤៧ មាត្រា ៤៨ មាត្រា ៤៩ និងមាត្រា ៥០ ដែលស្តីអំពីសិទ្ធិមនុស្ស ។ បើនៅក្នុងគ្រួសារ ប្តី ប្រពន្ធ កូន ឬសមាជិកណាម្នាក់រំលោភសិទ្ធិដូចពោលក្នុងមាត្រាខាងលើ ចំពោះមនុស្សក្នុងគ្រួសារ ជនល្មើសត្រូវទទួលទោសនូវចំពោះមុខច្បាប់ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២២) ។ ក្រមព្រហ្មទណ្ឌត្រង់មាត្រា ២១៧ មាត្រា ២១៨ មាត្រា ២១៩ មាត្រា ២២៦ មាត្រា ២២៧ មាត្រា ២២៨ ដែលបានចែងអំពីទោសព្រហ្មទណ្ឌនៃអំពើហិង្សា ជនល្មើសត្រូវទទួលទោសដោយជាប់ពន្ធនាគារ ដោយផ្អែកទៅលើកម្រិតនៃបទល្មើស ។ រីឯច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដែលមាន ៧ ជំពូក និង ៣៦ មាត្រា ជនល្មើសត្រូវតែចូលពន្ធនាគារ ។ ចំណែកឯច្បាប់ស្តីអំពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលមាន ៦ ផ្នែក ១២២ មាត្រា ជនល្មើសត្រូវតែទទួលទោស និងមានវិប្បដិសារីអស់មួយជីវិត((អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២៣) ។

អ្នកចូលរួមដោះស្រាយច្រើនតែយកច្បាប់ប្រុស ច្បាប់ស្រី ឬក្បួនច្បាប់ផ្សេងៗទៀត ពិសេសក្នុងក្បួនច្បាប់អាពាហ៍ពិពាហ៍ក្នុងគ្រួសារខ្មែរ មានការអប់រំតាមបែបថៅមហាមកដាស់តឿនដល់ស្វាមីភរិយាដែលមានទំនាស់ ឬម្យ៉ាងទៀត ក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៤៧ បានចែងថា មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។ ឯកូនចៅមានកាតព្វកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ ។ មាត្រានេះ មានអត្ថន័យជ្រាលជ្រៅណាស់ដែលបានឱ្យតម្លៃខ្ពស់ដល់ទំនៀមទម្លាប់ ប្រពៃណី នៃប្រជាជនខ្មែរ ដូចមានបុព្វបុរសខ្លះបានសរសេរអំពីតួនាទីស្វាមី ភរិយា មាតាបិតា និងបុត្រធីតាដែលជាសមាជិកគ្រួសារ ធ្វើជាទឹកអន្សារសម្រាប់ផ្សះផ្សាសមាជិកទាំងអស់ឱ្យចេះអត់ឱនឱ្យគ្នា និងជៀសវាងទំនាស់ គឺអំពើហិង្សាក្នុងគ្រួសារ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២៤) ។

ស្ត្រីជាភរិយាមិនគប្បីឱ្យគេខ្ចីរបស់ប្រើប្រាស់ ឬប្រាក់កាសតែម្នាក់ឯងមិនឱ្យស្វាមីដឹងឡើយ ។ ចង់ទិញដូររបស់អ្វីៗមិនត្រូវលួចលាក់ ទិញតាមអំពើចិត្ត ទិញថ្លៃប៉ុណ្ណោះ កុហក់ស្វាមីថាទិញថ្លៃប៉ុណ្ណោះ ឱ្យថោក ដើម្បីកុំឱ្យស្វាមីបន្ទោស ឬក៏ឱ្យលើសថ្លៃដើម្បីចំណេញពីស្វាមី ។ គ្រឿងអលង្ការ និងគ្រឿងស្លៀកពាក់ក៏ត្រូវប្រើប្រាស់ឱ្យចេះប្រុងប្រយ័ត្ន ចេះថែទាំ កុំចេះតែផ្លាស់ប្តូរ ស្រូតតាមអំពើចិត្តមិនគិតពីការខាតបង់ព្រោះតែចង់បានបែបម៉ូតថ្មី លក់អាម៉ូតចាស់ថោកៗចោលទាំងថ្មី បណ្តាលឱ្យមានការចំណាយហួសកម្រិតក្នុងគ្រួសារ នាំឱ្យស្វាមីហ៊ានប្រព្រឹត្តអំពើពុករលួយ លួចប្លន់កេងកិបស៊ីសំណូកជាដើម (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២៧) ។

ស្ត្រីជាភរិយាមិនត្រូវប្រព្រឹត្តកន្លងចិត្តស្វាមី បែកចិត្តគំនិតទៅសាហាយស្មន់ និងបុរសដទៃទៀត ព្រោះតែស្វាមីចាស់ជរា ឬមានរូបអាក្រក់ ឬក៏ទីទាល់ក្រគ្មានទ្រព្យសម្បត្តិ ។ ធម្មតាស្ត្រីល្អប្រកបដោយសុជីវធម៌ តែទទួលបុរសណាជាស្វាមីហើយ ទោះបុរសនោះធ្លាក់ខ្លួនជាមនុស្សទីទាល់ក្រលំបាកតោកយ៉ាក

ខូចបុណ្យសក្តិយ៉ាងណាក៏ដោយ ក៏មិនដែលផ្លាស់ប្តូរបោចលនោះទេ រឹតតែមានសេចក្តីស្រឡាញ់ស្មោះត្រង់អាណិតអាសូរស៊ូប្តូរជីវិតលើសដើម (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២៧) ។

ស្ត្រីជាភរិយាមិនត្រូវខ្ជិលទំរន់ឱ្យគាំងសតិប្រាជ្ញា គប្បីប្រឹងប្រែងឱ្យឈ្លាសវៃ ប៉ិនប្រសប់ក្នុងកិច្ចការទាំងពួង មានចេះផ្សែផ្សំ ដេរប៉ាក់ ជួសជុលរបស់ដែលចាស់ ដែលខូច ដែលតិច ឱ្យទៅជារបស់ប្រើការកើតជារបស់ច្រើន ។ ចំណុចខាងលើ គ្រួសារខ្មែរភាគច្រើននៅសម័យដើម បានឱ្យតម្លៃខ្ពស់នាពេលបច្ចុប្បន្ននៅមានប្រើប្រាស់វិធីនេះសម្រាប់សម្រុះសម្រួលអំពើហិង្សាក្នុងគ្រួសារ ហាក់ដូចជាបានលទ្ធផលល្អបង្គួរនៅក្នុងកាលៈទេសៈដែលយើងស្ថិតក្នុងភាពក្រីក្រក្រោយសង្គ្រាមជាង ៣០ ឆ្នាំ ហើយយើងពុំទាន់មានយន្តការទំនើបដូចប្រទេសជឿនលឿន រារាំងផលវិបាកដែលកើតមានដោយសារការលែងលះគ្នា ។ នៅក្នុងមាត្រានេះដដែលបានចែងអំពីតួនាទីបុត្រ បុត្រធីតាចំពោះមាតាបិតាដូចជា ៖

- កូនដែលមានបែបបទល្អដោយតាមពាក្យប្រៀនប្រដៅទាំងអស់នេះបាន លុះតែមាតាបិតាបានទម្លាប់វាតាំងពីតូចៗមក គឺបើមានចំណីអាហារ ឬវត្ថុអ្វីដែលវាចង់បាន ត្រូវតែលៃលកឱ្យវាខ្លះហើយបើមិនគួរឱ្យវាទេ កុំលាក់ទុកឱ្យស្គាល់ទីកន្លែងល្មមវាលួចបាន កាលបើមាតាបិតាបង្អត់ឱ្យវាឃ្លានជ្រុល ឱ្យវាចង់បានខ្លាំងហើយ វាស្គាល់ទីកន្លែងដែលលាក់ទុកនោះ វាមុខតែប្រឋុយលួចជាមិនខាន ហើយបើលួចបានម្តងហើយ ពេលក្រោយលួចទៀត ដល់ជំថ្នឹកក្នុងការលួច ហ៊ានលួចប្លន់អ្នកដទៃរហូតដល់លួចប្លន់ទ្រព្យសម្បត្តិជាតិ
- ជាពិសេសចំពោះមាតាខ្លះច្រើនតែស៊ុមគ្រលំនឹងកូន លួចលាក់លុយកាក់ឱ្យទៅកូនចាយមិនឱ្យស្វាមីដឹង ដោយស្រឡាញ់កូនជ្រុលក្រែងកូនចាយមិនគ្រប់គ្រាន់ ហើយនេះជាលក្ខណៈអាក្រក់មួយដែលនាំឱ្យកូនចេះចាយធំផង មានចិត្តមិនស្មោះត្រង់ចេះលាក់ការកំបាំងចំពោះជននៅក្នុងគ្រួសារផង
- កាលបើយ៉ាងនេះយូរៗទៅ ពេលខ្វះចាយវាយហ៊ានខ្ចីលុយកាក់គេដោយអាងទារពីម្តាយបានដល់ពេលក្រោយមកទៀតម្តាយលួចលាក់ឱ្យចាយមិនទាន់ចិត្ត វាក៏ហ៊ានលួចម៉ែឪឯង នឹងអ្នកដទៃ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២៨) ។

ទោះបីយ៉ាងណា សង្គមកម្ពុជា ស្ត្រីខ្មែរពុំមែនគ្មានអំណាចឡើយ ស្ត្រីអាចទទួលទ្រព្យសម្បត្តិកេរមរតកដូចជាបុរសដែរ ។ ជាញឹកញាប់ស្ត្រីដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ ធ្វើការសម្រេចចិត្តលើការចំណាយ និងការដាក់ទុនរកស៊ីផ្សេងៗ ។ ប៉ុន្តែផ្លូវដើរពិតប្រាកដរបស់ស្ត្រីទៅរកអំណាចនៅក្នុងឋានានុក្រមសង្គម គឺត្រូវដើរតាមគន្លងក្រមនៃ (ច្បាប់ស្រី) ដែលតម្រូវឱ្យស្ត្រីត្រូវបម្រើ និងគោរពប្តី និងគោរពប្រណិប័តន៍ឪពុកម្តាយ ថែរក្សាកូនចៅ និងត្រូវមានឥរិយាបថសុភាពរាបសារសម្តីទន់ភ្លន់គ្រប់ពេលវេលា ។ មានមតិមួយចំនួនយល់ថា តួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងគ្រួសារ គឺត្រូវបានគេមើលឃើញថា ជាផ្នែកមួយនៃវប្បធម៌របស់មនុស្សជំនាន់ក្រោយហើយ ដែលមានការព្រួយបារម្ភនៅក្នុងសង្គមថាអាចមានការបាត់បង់នូវវប្បធម៌នេះ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២៨) ។

គំរូដ៏មានអំណាចរបស់នារីខ្មែរ ត្រូវបានរៀបរាប់នៅក្នុងព្រេងនិទានស្ដីពីស្ត្រីគ្រប់ល័ក្ខណ៍ ។ នៅក្នុងរឿងព្រេងនិទានស្ត្រីគ្រប់ល័ក្ខណ៍ គឺជាគន្លឹះសម្រាប់សម្រេចរាល់ជោគជ័យរបស់ប្ដី ។ តួនាទីរបស់ស្ត្រីត្រូវបានគេចាត់ទុកជាអ្នកគាំទ្រ ដូចដែលចែងនៅក្នុងពាក្យស្លោកខ្មែរថា"សំណាបយោងដី ស្ត្រីយោងបុរស" ។ ស្ត្រីត្រូវបានគេសង្ឃឹមថា ត្រូវបាននឹងគោរព និងជួយជ្រោមជ្រែងប្ដីក្នុងគ្រប់កាលៈទេសៈដោយមិនគិតពីកំហុស និងភាពខ្វះខាតរបស់ប្ដី ឬការប្រតិបត្តិរបស់ប្ដីមកលើប្រពន្ធរបស់ខ្លួននោះឡើយ ។ ពាក្យស្លោកមួយទៀតបានពាលថា ប្ដីជា"ម្ចាស់" និងណែនាំនារីឱ្យចេះ"គាំទ្រ និងខ្លបខ្លាចប្ដី ព្រោះនាងជាស្ត្រី" នឹងត្រូវប្រុងប្រយ័ត្ន "រាល់ការនិយាយស្ដីដោយជៀសវាងការចង់បានស្មើជាមួយប្ដី" (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២៨) ។

ឥរិយាបថរឿងភេទសម្រាប់ស្ត្រី មានលក្ខណៈខុសគ្នាខ្លាំងពីឥរិយាបថចំពោះរឿងភេទរបស់បុរស ។ ប្រជាពលរដ្ឋខ្មែរបានឱ្យតម្លៃខ្ពស់លើភាពបរិសុទ្ធ ដែលជាលក្ខខណ្ឌពិសេសសម្រាប់អាពាហ៍ពិពាហ៍ ។ នារីដែលបាត់បង់ភាពបរិសុទ្ធមុនពេលរៀបការនឹងនាំមកនូវភាពអាម៉ាស់ដល់កិត្តិយស និងស្ថានភាពគ្រួសារ ។ ដូចដែលមានពាក្យចាស់ពោលថា"បុរសគឺជាមាស ឯនារីគឺជាក្រណាត់" ។ ពាក្យចាស់នេះមានន័យផ្សេងទៀតថា មាសគឺមិនខ្លាចភ្លើង និងមិនបាត់បង់តម្លៃ ប៉ុន្តែក្រណាត់នឹងគ្មានតម្លៃនៅពេលហែក ឬប្រឡាក់ភក់ ។ ពាក្យចាស់នេះបានបង្ហាញឱ្យកាន់តែច្បាស់ថា នារីខ្មែរត្រូវតែប្រុងប្រយ័ត្នក្នុងការថែរក្សានូវភាពបរិសុទ្ធ និងត្រូវប្រតិបត្តិតាមច្បាប់ទូន្មាន ។ ពាក្យស្លោកជាច្រើនបានទូន្មានស្ត្រីឱ្យប្រយ័ត្នក្នុងការនិយាយស្ដីទៅអ្នកខាងក្រៅ "កុំឱ្យនាំភ្លើងខាងក្រៅចូលផ្ទះ ហើយនឹងកុំនាំភ្លើងក្នុងផ្ទះចេញមកក្រៅ" ។ ស្ត្រីត្រូវបានប្រៀនប្រដៅថា ការជជែកលេងជាមួយអ្នកជទៃនាំឱ្យកើតមានជម្លោះ អ្នកនឹងយកបញ្ហាជម្លោះខាងក្នុងគ្រួសារទៅរាលដាលដល់អ្នកខាងក្រៅ ហើយប្រសិនបើមិនមានការប្រុងប្រយ័ត្ន (ក្នុងករណីនេះ) យើងនឹងកក្កូរកកាយធ្វើឱ្យមានការចងកំហឹងដល់អ្នកទាំងពួងរួមទាំងកូនចៅ ហើយនេះជាការមិនល្អមួយ និងគួរឱ្យស្អប់ ។ បុរសត្រូវបានគេចាត់ទុកថា ជាអ្នកធ្វើសេចក្ដីសម្រេចចុងក្រោយបង្អស់បង្គាប់ ។ ពាក្យស្លោកខ្មែរបានពោលថា បុរសមិនគួរជា "អ្នកដែលនៅក្រោមសំពត់របស់ស្ត្រី" បើមិនដូចនេះ បុរសនឹងក្លាយជាអ្នកនៅក្រោមបង្គាប់របស់ស្ត្រី ។ ចរិតលក្ខណៈបែបនេះ គឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរបំផុតទៅលើបុរសខ្មែរ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២៨-១២៩) ។

ជាការពិតណាស់ មានពេលខ្លះបុរសបានប្រាប់ឱ្យដឹងថា ក្រុមមិត្តភក្តិវ័យស្រករគ្នារបស់ពួកគេជាអ្នកនាំឱ្យគេទៅរកការសប្បាយផ្លូវភេទ ។ ការមានដៃគូជាច្រើនត្រូវបានគេមើលឃើញថា លក្ខណៈល្អរបស់បុរសក៏ដូចជាលក្ខណៈខ្លាំងផ្នែករាងកាយ និងសុខភាពផ្លូវចិត្ត ។ លទ្ធផលនៃចំណុចនេះ គឺការបណ្ដាលឱ្យមានការធ្វើអាជីវកម្មផ្លូវភេទគួរឱ្យកត់សម្គាល់នៅកម្ពុជា និងអំពើហិង្សាក្នុងគ្រួសារស្របតាមពាក្យចាស់ប្រដៅអប់រំថា កុំបណ្ដោយខ្លួនឱ្យធ្លាក់ក្នុងពាក្យថា "ឆ្កួតបីយ៉ាង នោះគឺមួយឆ្កួតនឹងស្រា ពីរឆ្កួតនឹងស្រី បីឆ្កួតនឹងល្បែង" ការពិត ទោះបីយើងខិតខំប្រឹងប្រែងរកគ្រប់វិធីដើម្បីលុបបំបាត់អំពើហិង្សាក្នុងគ្រួសារយើងមិនប្រាកដអាចធ្វើបានទេ ប៉ុន្តែយើងអាចកាត់បន្ថយ និងទប់ស្កាត់បានមួយកម្រិតប៉ុណ្ណោះ ពុំអាច

បានទាំងស្រុងទេ ទោះបីមានច្បាប់ និងមានវិធានការម៉ឺងម៉ាត់ក៏ដោយ មិនខុសពីពាក្យចាស់ពោលថា "ចានក្នុងរាវលែងអីនិងរណ្តំគ្នា" (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១២៩) ។

ម្យ៉ាងទៀតក្នុងសម័យសកលភាវូបនីយកម្មនេះ មាតាបិតាមិនសម្រេចដាច់ខាតម្នាក់ឯងទេ ត្រូវសួរចិត្តកូនប្រុស ស្រី សាមីខ្លួនសិន បើគេមានស្រឡាញ់ទាក់ទងគ្នាជាគូប្រចាំជីវិតចំពោះរូបណា ហើយមាតាបិតាគ្រាន់តែជួយសម្របសម្រួលសួរបញ្ជាក់ស្ដីដណ្ដឹងឱ្យចាស់ទុំបានដឹងឮ ហើយកំណត់ពេលរៀបអាពាហ៍ពិពាហ៍តែម្ដង ។ មុនពេលរៀបពិធីអាពាហ៍ពិពាហ៍ នោះម៉ែឪទាំងពីរខាងបានអនុញ្ញាតឱ្យកូនប្រុសស្រីទាក់ទងបណ្ដើរគ្នាលេងឱ្យបានស្គាល់ចិត្តគំនិត ។ បែបនេះក៏ល្អម្យ៉ាងដែរ បើថ្ងៃក្រោយទៅមានកំហុសមិនធ្លាក់ទាំងស្រុងមកលើម៉ែឪទេ ។ ត្រូវសង្គ្រោះចែកទ្រព្យសម្បត្តិឱ្យកូនចាយធ្វើសោហ៊ុយរៀនសូត្រ និងធ្វើបុណ្យទាន់តាមកាលសម័យ ដល់កូនមានគូស្វាមីភរិយាហើយ គប្បីចែកមរតកមានស្រែចម្ការ ផ្ទះសម្បែងមាសប្រាក់ជាដើមតាមសមត្ថភាពខ្លួនឱ្យកូនធ្វើដើមទុនទៀត ។ ប៉ុន្តែមាតាបិតាមិនគួរចែកឱ្យកូនទាល់តែអស់រលីងទេ ហើយទៅផ្សងសំណាងជាមួយកូនឱ្យគេចិញ្ចឹមវិញនោះទេ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៣០) ។

ចំណុចខ្លះនៃសុជីវធម៌ខាងលើនាសម័យវិទ្យាសាស្ត្រទំនើបនេះ យុវជនហាក់ដូចជាទទួលយកដោយលំបាក ពីព្រោះរបបប្រល័យពូជសាសន៍ "ប៉ុល ពត" បានបំផ្លាញទាំងខ្លឹមសារ ទាំងឥរិយាបថរបស់ប្រជាជនខ្មែរដែលរួចពីការស្លាប់នៃរបបនោះ ហើយក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ សង្គ្រាមនៅតែបន្តជាមួយគ្នានេះ ក្រោយពេលដែលខ្មែរយើងគ្រប់ភាគីស្រុះស្រួលគ្នាឆ្នាំ ១៩៩៣ បោះឆ្នោតជាសកលជ្រើសរើសសភា អណត្តិទី ១ ក៏ពិតមែន ប៉ុន្តែសង្គ្រាមនៅបន្តដោយសារពួក ប៉ុល ពត ពុំព្រមចូលរួម ហើយប្រឆាំងតបចំពោះរដ្ឋាភិបាលស្របច្បាប់ប្រសូតចេញពីការបោះឆ្នោត ។ ខាងលើជាហេតុបណ្ដាលឱ្យសុជីវធម៌ សីលធម៌ដ៏ល្អរបស់ខ្មែរពីដើម ហាក់ដូចពុំសូវបានចាប់អារម្មណ៍ចំពោះគ្រួសារវ័យក្មេង ។ ម្យ៉ាងរាល់ពេលដែលខ្លួនលាចេញពីទីណានឹងពេលចូលមកផ្ទះវិញ ។ គប្បីគក់ប្រាប់ថៃទាំរកថ្នាំសង្កូវពេទ្យជាដើម ក្នុងពេលដែលមាតាបិតាមិនស្រួលខ្លួនគប្បីផ្ចួតទឹកជុះលាងមន្ទិលក្អែលខ្លួននូវប្រាណមាតាបិតាដូចកាលមាតាបិតាថែរក្សាខ្លួនកាលនៅពីតូច ។ កូនប្រុសស្រីកាលបើម៉ែឪមានកិច្ចរវល់ គប្បីបញ្ឈប់ការងារខ្លួនជួយធ្វើការងារមាតាបិតាដោយស្មោះស្ម័គ្រ កុំទារថ្លៃឈ្នួល ឬយករង្វាន់អ្វី ដូចជាអ្នកក្រៅដទៃ ។ ទោះជាកូនប្រសារក្ដី កូនបង្កើតក្ដី កុំមើលតែនឹងភ្នែក បើឃើញម៉ែឪធ្វើការអ្វីត្រូវជួយធ្វើកុំចាំឱ្យលោកប្រើ ។ បើមានការត្រូវទៅដើរលេង ឬទៅទីណាដែលមិនមែនជាការចាំបាច់ គប្បីខកខានជួយធ្វើលោកសិន (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៣១) ។

កូនប្រុសស្រី ត្រូវស្ដាបនាវង្សត្រកូលនៃមាតាបិតាឱ្យមានវឌ្ឍនភាពខ្ពង់ខ្ពស់ឡើង បើមិនអាចឱ្យខ្ពស់ឡើងទៀតបានទេ មិនត្រូវញុំាងវង្សត្រកូលនោះឱ្យថោកទាបឡើយ យ៉ាងហោចណាស់ក៏ឱ្យបាននៅតាំងដូចដើម គឺមិនត្រូវបំផ្លាញទ្រព្យសម្បត្តិកេរ្ដិ៍មរតកឱ្យវិនាសឥតប្រយោជន៍ និងមិនត្រូវបណ្ដោយខ្លួនឱ្យជាមនុស្សមានចរិតថោកទាបជាងមាតាបិតាខ្លួន កិច្ចការអ្វីដែលលោកបានធ្វើមកត្រឹមត្រូវតាមគតិបណ្ឌិត

ហើយដូចជាគោរពសាសនា និងបរិច្ចាកទានជាដើមមិនត្រូវលះបង់កិច្ចការដ៏ល្អប្រពៃណីនោះចោលទេ ទោះលោកធ្វើមរណកាលបាត់បង់ទៅហើយក៏ដោយ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៣២) ។

កូនប្រុសស្រីត្រូវផ្ចិតផ្ចង់ចរិយាមាយាទឱ្យត្រឹមត្រូវល្អ កុំប្រព្រឹត្តអំពើអាក្រក់តាមចំណង់ មានប្រព្រឹត្តអំពើអបាយមុខ លេងល្បែងភ្នាល់គ្នា បៀអាប៉ោងជាដើម ដែលនាំឱ្យមាតាបិតាទាស់អធ្យាស្រ័យកើតសេចក្តីទុក្ខព្រួយអស់សង្ឃឹមទៅអនាគតថា នឹងបានទៅជាមនុស្សល្អល្មមទទួលថែរក្សាមរតករបស់វង្សត្រកូលបាន ហើយត្រូវចៀសវាងអាការៈបោកបញ្ឆោតដោយចរិយាចំពោះម៉ែឪ ព្រោះមានកូនខ្លះចង់បានមរតកទ្រព្យសម្បត្តិពីម៉ែឪ ចង់ឱ្យលោកប្រគល់ឱ្យឆាប់ៗ ក៏តាំងប្រើចរិតខ្លាចាំសីលធ្វើជាអ្នកត្រឹមត្រូវដឹងគុណណាស់ លោកសុំសីលធ្វើទាន ក៏ខំធ្វើដូចលោក និងខំបម្រើផ្គត់ផ្គង់បាយទឹកនំចំណី គក់ប្រាប់ក្រាបសំពះថ្វាយបង្គំរាល់ពេលវេលា ធ្វើឱ្យម៉ែឪភ្លក់ភ្លើកចិត្ត ដរាបដល់លោកប្រមូលមរតកប្រគល់ឱ្យអស់គ្មានសល់មួយសេន ក៏តាំងប្រែក្រឡាស់ពាក់មុខខ្លាបន្តិចម្តងៗ ដរាបលោកខ្លាចទ្រាំនៅជាមួយផងមិនបាន ឬក៏ដេញលោកឱ្យចុះចេញពីផ្ទះ ដូចគោចាស់ដែលគេហូតកន្ទុះលែងចោលអញ្ចឹង (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៣២) ។

គន្លឹះ ដំណោះស្រាយខាងលើនេះ ជាវិធានការដែលអ្នកទី ៣ ត្រូវច្បិចយកចំណុចណាដែលមានផលប្រយោជន៍ប្រើប្រាស់ ពញ្ញាក់ស្មារតីជនល្មើសដើម្បីឱ្យពួកគេវិលត្រឡប់ទៅផ្ទះវិញធ្វើការពិចារណារយៈពេលយូរឺឆាប់ អាស្រ័យលើអ្នកទី ៣ យល់ឃើញ ។ ការដោះស្រាយក្រៅប្រព័ន្ធតុលាការ យើងត្រូវបានខិតខំពន្យល់ភាគីទាំងពីរឱ្យយល់ពីផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារតាមប្រភេទអំពើហិង្សា ។ ហើយយើងមានវិធីច្រើនទៀត ដូចជាពន្យល់ថា កាលណាមានអំពើហិង្សាក្នុងគ្រួសារ មានការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ បាត់បង់ថវិកា បាត់បង់កិត្តិយស កូនបាត់បង់ការសិក្សា នៅឯកោ ខ្មាស់គេ បាត់បង់ភាពសុខសាន្ត បាត់បង់អនាគតល្អ ឈឺចាប់ផ្លូវកាយ និងផ្លូវចិត្ត វប្បធម៌ជាតិធ្លាក់ចុះ ជះឥទ្ធិពលមិនល្អដល់កុមារ មានការរើសអើងក្នុងសហគមន៍ មានមនុស្សមិនល្អ គ្មានយុត្តិធម៌ក្នុងគ្រួសារ សេដ្ឋកិច្ចគ្រួសារធ្លាក់ចុះកេរ្តិ៍ឈ្មោះគ្រួសារអោប់ឱនមានភាពអាម៉ាស់ក្នុងភូមិ ក្នុងសហគមន៍អ្នកជិតខាងមិនរាប់អានធុញទ្រាន់ដល់ការរំខាន មានទុក្ខព្រួយ និងអស់សង្ឃឹម កូនក្លាយជាមនុស្សដែលប្រើហិង្សាបន្តរៀនខ្សោយ បោះបង់ចោលការសិក្សាក្លាយជាក្មេងអនាថា ប្រទេសជាតិបាត់បង់ធនធានមនុស្ស ។ ពួកគេងាយស្រួលបាត់បង់សេចក្តីក្លាហានហើយទំនុកចិត្តលើខ្លួនឯងបានធ្លាក់ចុះ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៣២) ។

**– សង្ស្សិត្តិករនៃប្រព័ន្ធច្បាប់**

សង្ឍត្តិករនៃប្រព័ន្ធច្បាប់ គឺជាការដោះស្រាយតាមច្បាប់ ឬតាមផ្លូវតុលាការ ។ និយាយឱ្យងាយយល់ការដោះស្រាយបែបពាហិរនៃប្រព័ន្ធច្បាប់ ភាគីមួយចំនួនពេញចិត្ត ប៉ុន្តែភាគីមួយចំនួនទៀតយល់ព្រមតាមដំណោះស្រាយចាស់ទុំ និងអាជ្ញាធរមូលដ្ឋាន ដោយអារម្មណ៍មួម៉ៅមិនសុខចិត្តឡិតគេថាមិនយុត្តិធម៌ ហើយគេក៏រកផ្លូវទៅតុលាការឱ្យច្បាប់វិនិច្ឆ័យវិញ ។ អំពើហិង្សាជាបទល្មើសព្រហ្មទណ្ឌ ដែលច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើសចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថា អ្នកត្រូវទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនោះ ។ នៅក្នុងករណីចាំបាច់

បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុ ដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៣៤) ។

តាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ បានចែងយ៉ាងច្បាស់ថា ច្បាប់នេះមានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការការពារជនរងគ្រោះ និងពង្រឹងវប្បធម៌ហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារក្នុងសង្គមនៅព្រះរាជាណាចក្រកម្ពុជា (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៣៥) ។

## ខ. ប្រសិទ្ធិភាពទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៃសង្គមកម្ពុជា

### – ដំណោះស្រាយតាមពាហិរនៃប្រព័ន្ធច្បាប់

ដំណោះស្រាយតាមពាហិរនៃប្រព័ន្ធច្បាប់ ឬក្រៅប្រព័ន្ធច្បាប់ចំពោះអំពើហិង្សាក្នុងគ្រួសារនៅប្រទេសកម្ពុជា ជារឿងមួយស្មុគស្មាញ បង្កប់ដោយអាថ៌កំបាំង ខ្លះនិយាយថាជារឿងផ្ទាល់ក្នុងគ្រួសាររបស់គេ អ្នកក្រៅគ្មានសិទ្ធិលូកដៃចូលទេ ពីព្រោះពេលខ្លះថ្ងៃនេះគេទាស់ទែងគ្នាថ្ងៃស្អែកគេត្រូវរ៉ូវគ្នា ឯយើងជួយឈឺឆ្អាលត្រូវបានប្តីប្រពន្ធឱ្យខុសទៅវិញក៏មាន ។ ករណីនេះមានលោកអ្នកខ្លះផ្តាំកូនចៅថា «កុំធ្វើចេះដឹងរឿងផ្ទាល់គ្រួសាររបស់គេ ប្រយ័ត្នគ្រោះថ្នាក់» ។ ហេតុអ្វីបញ្ហានេះមានការស្មុគស្មាញយ៉ាងនេះ? ពីព្រោះគ្រួសារផ្សំឡើងដោយស្វាមី និងភរិយា និងកូនរបស់គេ ។ តាមទម្លាប់បើគ្រួសារណាមួយមានបញ្ហាអ្វី គេរត់រកចាស់ទុំព្រឹទ្ធាចារ្យដែលព្រហ្មវិហាធម៌មានបទពិសោធន៍ជួយគេ ហើយទម្លាប់នេះមានរហូតដល់សព្វថ្ងៃដូចជាដោះស្រាយអំពើហិង្សាក្នុងគ្រួសារជាដើម (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៣) ។

ដើម្បីដោះស្រាយអំពើហិង្សាក្នុងគ្រួសារបានជោគជ័យ យើងគប្បីយល់ពីមូលហេតុរបស់វាឱ្យបានច្បាស់លាស់សិន (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៣) ។ គ្រួសាររួមមាន ប្តីប្រពន្ធកូន និងមនុស្សដែលនៅក្នុងផ្ទះជាមួយផ្សេងទៀត ទោះជាសាច់ញាតិក្តី អ្នកបម្រើក្តី ។ ការរស់នៅជាក្រុមបែបនេះតែងតែមានទំនាស់ ប៉ុន្តែរបកគំហើញរបស់យើងគេច្រើនលើកតែពីទំនាស់ប្តីប្រពន្ធ ។ នៅក្នុងប្រទេសកម្ពុជាយើង ប្តីប្រពន្ធគឺជាសម្ព័ន្ធភាពបុរស និងស្ត្រីដែលទទួលដោយអាពាហ៍ពិពាហ៍ រៀបចំឡើងដោយឪពុកម្តាយ ឬអាណាព្យាបាល និងប្រថាប់ត្រាលើសំបុត្រអាពាហ៍ពិពាហ៍ដោយមន្ត្រីអត្រានុកូលដ្ឋានតាម ឃុំ/សង្កាត់ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៤) ។ គ្រួសារខ្មែរស្ថិតនៅក្នុងស្ថានភាព បុរាណផង ទំនើបផង ដូចនេះយើងរកឃើញដំណោះស្រាយទំនាស់គ្រួសារតាមពាហិរនៃប្រព័ន្ធច្បាប់មានបីប្រភេទគឺ ៖

#### ○ ដំណោះស្រាយទ្វេភាគី

តាមការរកឃើញ សង្គមខ្មែរដោះស្រាយជម្លោះក្នុងគ្រួសារតាមវិធីទ្វេភាគីប្រហែល ៨០% ។ នៅពេលប្តីប្រពន្ធទាស់ទែងគ្នា មិនស្របយោបល់គ្នា ប្តីប្រពន្ធខឹងគ្នា ពួកគេច្រើនសម្រុះសម្រួលគ្នាដោយម្នាក់ៗ ទទួលកំហុសរបស់ខ្លួន ហើយសន្យាមិនឱ្យមានកំហុសដូចនេះទៀត ។ ពួកគេគោរពគ្នាទៅវិញទៅមកហើយប្រុងប្រយ័ត្នមិនទាស់គ្នា និងមិនចង់ឱ្យមានការប្រកែកគ្នាផងដែរ ។ ករណីមួយទៀត ភាគីទាំងពីរអាចដោះស្រាយអំពើហិង្សាក្នុងគ្រួសារបាន លុះតែក្នុងចំណោមភាគីទាំងពីរម្នាក់សុខចិត្តចាញ់ ឬប្រកាន់យកមាគ៌ាឈ្នះទាំងអស់គ្នាត្រូវទាំងអស់គ្នា ឬខុសទាំងអស់គ្នា ដើម្បីសេចក្តីសុខនៅក្នុងគ្រួសារ ។ ពេលខ្លះ

ទៀត ខណៈដែលខឹងគ្នាដោយភាគីណាមួយស្របតាមការណែនាំ ឬយោបល់របស់ខ្លួនគេមិននិយាយរកគ្នាអស់រយៈពេលពីរ ឬបីថ្ងៃ បន្ទាប់មកភាគីដែលមានកំហុសច្រើនមកសារភាព ឬសុំទោស បន្ទាប់មកគេត្រូវរ៉ូវគ្នាវិញ ។ វិធីនេះ បើយើងសម្ភាសន៍ជាមួយមនុស្សដែលមានការយល់ដឹង និងមានជីវភាពមធ្យម និងខ្ពស់ ១០០ នាក់ នោះយើងទទួលបាន ៨០% ដែលអនុវត្តតាមរូបមន្តនេះ ដោយពួកគេគោរពតាមប្រពៃណីគោរពសិទ្ធិគ្នាទៅវិញទៅមក យល់អំពីផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារ និងស្គាល់តួនាទីម្នាក់ៗនៅក្នុងគ្រួសារ ព្រមទាំងយល់អំពីច្បាប់របស់រដ្ឋ និងអន្តរជាតិ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៤) ។

○ **ដំណោះស្រាយពហុភាគីដោយញាតិសន្តាន**

ពេលរកដំណោះស្រាយដោយទ្វេភាគីមិនបានសម្រេច ប្ដី ឬប្រពន្ធច្រើនទៅរកឪពុកម្ដាយ សាច់ញាតិ ឬមិត្តភក្តិឱ្យជួយរកច្រកចេញ ។ ពេលនោះអ្នកទីបីសួររកមូលហេតុឱ្យសាមីខ្លួនដែលទៅពឹងពាក់គេឱ្យនិយាយដោយស្មោះត្រង់ពីមូលហេតុពិតនៃទំនាស់ ។ បន្ទាប់មក អ្នកទីបីប្រាប់ពីផ្លូវដែលត្រូវដើរដោយប្រើចិត្តសាស្ត្របែបពិសោធន៍គ្រប់បែបយ៉ាង ។ បើមិនជោគជ័យទេ អ្នកទីបីសុំជួបភាគីម្ដងម្នាក់ៗសួរពីមូលហេតុដែលមានទំនាស់ ។ ជួនកាលក្រោយពីបានស្ដាប់ហើយ អ្នកទីបីប្រាប់ឱ្យទាំងពីរអ្នកប្ដីប្រពន្ធត្រលប់ទៅវិញហើយពិចារណាសារជាថ្មី បើពុំបានជោគជ័យឱ្យមកម្ដងទៀត (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៥) ។

ដំណោះស្រាយពហុភាគី ជួនកាលភាគីទីបីលើកយកដំបូន្មានអាពាហ៍ពិពាហ៍ ឬច្បាប់ប្រុសច្បាប់ស្រី ឬច្បាប់រដ្ឋ មកនិយាយដោយលើកយកផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារមកពន្យល់អប់រំគូភាគីទំនាស់ ។ វិធីនេះជួយឱ្យភាគីទំនាស់ចំណេញពេលវេលា និងថវិកា ប៉ុន្តែលទ្ធផលទាបជាងដំណោះស្រាយទី ១ និងបញ្ជាក់ថា កត្តាអត្តនោម័តកំណត់ជោគជ័យ និងកត្តាចម្បងក្នុងការសម្រេចរាល់គោលដៅ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៥) ។

○ **ដំណោះស្រាយពហុភាគីដោយមេភូមិ និងរដ្ឋអំណាចមូលដ្ឋាន**

ប្រជាពលរដ្ឋក្រីក្រ ឬល្មិតល្មង់នៅតាមទីជនបទច្រើនប្រើដំណោះស្រាយនេះ ។ ចំពោះប្រជាពលរដ្ឋដែលមានកម្រិតយល់ដឹងច្រើន និងដែលមានជីវភាពធូរធារបានពោលថា បើជ្រុលតែទៅដល់ភូមិ/ឃុំហើយគឺពួកគេសម្រេចចិត្តលែងលះគ្នាតែម្ដង ពីព្រោះគេពុះពារដោះស្រាយគ្នាជាទ្វេភាគីអស់លទ្ធភាពហើយគ្មាននរណាអាចដោះស្រាយបានល្អជាងនេះទៀតទេ ហើយគេយល់ថាបើមកដល់ភូមិ/ឃុំ ហើយភាគីនៃជម្លោះមិនកែកំហុសនោះប្រាកដជាមានគ្រោះថ្នាក់ ឬពុំបានសុខដដែល ។ ដូចច្នេះ គ្រួសារដែលមានកម្រិតជីវភាពធូរធារ ឬកម្រិតជីវភាពមធ្យម និងគ្រួសារដែលមានការយល់ចេះដឹងច្រើន គេមិនងាយនឹងឱ្យភូមិ/ឃុំដឹងអំពីទំនាស់របស់គ្រួសារគេណាស់ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៥) ។

ដំណោះស្រាយតាមរដ្ឋអំណាចមូលដ្ឋាននេះដែរ ភាគីរដ្ឋអំណាចប្រើប្រាស់វិធីសាស្ត្រស្រដៀងគ្នានិងដំណោះស្រាយរបស់ឪពុកម្ដាយ និងញាតិមិត្តដែរ ដោយគ្រាន់តែលើកពីផលវិបាកនៃជម្លោះ លើកពីច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ សិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ និងឃុំ/សង្កាត់ ប្រើប្រាស់វិធី

សាស្ត្ររដ្ឋបាលដូចជាប្ដីធ្វើខុសឱ្យទទួលពិន័យពីឃុំ ដូចជាពលកម្មស្រាលៗជាដើម (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៥) ។

ដំណោះស្រាយតាមពាហិរនៃច្បាប់ដែលហៅថា តាមក្រៅផ្លូវការមានចាស់ទុំ ព្រឹទ្ធាចារ្យ និងព្រះសង្ឃ នៅតាមភូមិឃុំ ច្រើនតែរើសអើងចំពោះស្ត្រីភេទ ឱ្យតម្លៃទាបលើភាគីខាងស្ត្រីផ្អែកលើទំនៀមទម្លាប់ប្រពៃណី ដែលហាក់ដូចជាចាត់ទុកស្ត្រីគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់បុរស ត្រូវតែគោរពតាមតួនាទីជាភរិយា និងស្វាមី (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៥) ។

ទោះបីយ៉ាងណា តាមព័ត៌មានផ្ដល់ដោយមេភូមិ និងអាជ្ញាធរមូលដ្ឋាននៅបណ្ដាភូមិភាគដែលបានចុះតាមខេត្តជាច្រើននៅទូទាំងប្រទេស និងព័ត៌មានផ្ដល់ដោយដៃគូអភិវឌ្ឍន៍ និងព័ត៌មានក្នុងតំបន់គោលដៅបានឱ្យដឹងថា ការដោះស្រាយក្រៅប្រព័ន្ធតុលាការដែលគេប្រើប្រាស់បានជោគជ័យ ៧០% (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៧) ។

– **ដំណោះស្រាយតាមសជ្ឈត្តិករនៃប្រព័ន្ធច្បាប់**

ច្បាប់ដាក់កំហិតដាច់ណាត់ចំពោះជនល្មើសគ្រប់រូបឱ្យទទួលទោស ឱ្យទទួលយកនូវការកំណត់ទោសតាមថៅក្រមដែលជាមន្ត្រីអនុវត្តច្បាប់ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៧) ។

ស្ថាប័នតុលាការមានសិទ្ធិចេញដីកាការពារ ហើយមានតែតុលាការខេត្ត/ក្រុងទេ ដែលមានសមត្ថកិច្ចចេញដីកាការពារ ដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារលើគ្រប់ករណីទាំងអស់ទោះជាអំពើហិង្សាក្នុងគ្រួសារនោះកើតឡើងស្ទួនគ្នា ជាផ្នែកស៊ីវិលក្ដី ជាផ្នែករដ្ឋបាលក្ដី និងជាផ្នែកព្រហ្មទណ្ឌក្ដី (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៨) ។

ពាក្យបណ្ដឹងសុំដីកាការពារពីតុលាការ (សាលាដំបូងខេត្ត/ក្រុង) អាចធ្វើឡើងដោយជនរងគ្រោះ ឬតំណាងជនរងគ្រោះ ឬមន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ដែលបំពេញការងារនៅកន្លែងកើតហេតុ ជនណាម្នាក់ដែលបានដឹងពីឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ ឬជនដែលតុលាការយល់ថា គ្មានលទ្ធភាពធ្វើពាក្យបណ្ដឹងដោយខ្លួនឯងបាន ។ ច្បាប់បើកសិទ្ធិឱ្យអ្នកខាងក្រៅចូលរួមក្នុងរឿងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលផ្ទុយអំពីទំនៀមទម្លាប់មិនឱ្យយកចិត្តទុកដាក់រឿងគ្រួសាររបស់អ្នកដទៃ ។ ជាមួយគ្នានេះ ការមិនសូវយកចិត្តទុកដាក់ក្នុងការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឱ្យបានត្រឹមត្រូវ បានធ្វើឱ្យជនរងគ្រោះមួយចំនួនមិនហ៊ានប្ដឹងទៅសមត្ថកិច្ច បើទោះបីជាករណីរបស់គេអាចបញ្ចប់តាមច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារក៏ដោយចុះ (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៨) ។

ដូច្នេះ ដំណោះស្រាយតាមពាហិរនៃច្បាប់ ឬហៅថាដោះស្រាយតាមក្រៅប្រព័ន្ធច្បាប់ ហាក់ដូចជាមានប្រសិទ្ធិភាពជាង ពីព្រោះជនរងគ្រោះមិនសូវចូលចិត្តទៅតុលាការ បើគេយកប្ដីទៅដាក់គុក ពីរបីថ្ងៃក្រោយមក គេនាំគ្នាទាំងកូនទាំងចៅទៅសុំអង្វរករឱ្យតុលាការដោះលែងស្វាមី ឬឪពុកគេមករួមរស់ជាមួយគ្រួសារវិញ ។ ចំណែកនៅក្នុងច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ មានជំពូកមួយចំនួននៅទូលាយងាយស្រួលជនខិលខូចឆ្លៀតឱកាស (អ៊ុក គង់ ឆ្នាំ ២០១០ ទំព័រទី ១៤៨) ។

# ជំពូកទី ៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១- ទីកន្លែង ឬ អង្គភាព

សមាគមអាដហុក សាខាខេត្តសៀមរាប មានទីតាំងស្ថិតនៅភូមិ សាលាកន្សែង សង្កាត់ ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។ សមាគមអាដហុក សាខាខេត្តសៀមរាប មានវិសាលភាពគ្របដណ្តប់ទូទាំងខេត្តសៀមរាប ហើយនៅជុំវិញសមាគមនេះ គឺមានផ្ទះប្រជាពលរដ្ឋជាច្រើន ។

- ទូរស័ព្ទទំនាក់ទំនងបន្ទាន់ ៖ ០១៧ ៩៤ ៩៥ ១៦/០៨៦ ៤៥ ៧៦ ៦៦
- គេហទំព័រ : adhoccambodia.org
- អ៊ីម៉ែល : info@adhoccambodia.org

រូបភាពទី១ ៖ ទីកន្លែង ឬអង្គភាពស្រាវជ្រាវ




## ៣.២- ប្រភេទនៃការស្រាវជ្រាវ

ចំពោះប្រភេទនៃការស្រាវជ្រាវ យើងបានប្រើប្រាស់វិធីសាស្ត្របែបពិពណ៌នា ដោយផ្អែកលើទិន្នន័យពីរគឺ ទិន្នន័យចម្បង ឬទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ ឬទិន្នន័យដែលមានស្រាប់។

## ៣.៣- ប្រភេទ និងប្រភពទិន្នន័យ

ចំពោះទិន្ន័យដែលក្រុមយើងខ្ញុំបានលើកយកមកប្រើប្រាស់សម្រាប់ការស្រាវជ្រាវលើប្រធានបទនេះ មានពីរប្រភេទគឺ ៖

- ទិន្នន័យចម្បង ៖ គឺជាប្រភេទទិន្នន័យដែលមិនទាន់មានការស្រាវ ឬចងក្រងទុកជាឯកសារនៅឡើយទេ ហើយទិន្នន័យទាំងនេះក្រុមយើងខ្ញុំទទួលបានតាមរយៈការរៀបជាកម្រងសំណួរ និងសម្ភាសន៍ទៅកាន់បុគ្គលិកដែលកាន់តួនាទីខាងគាំពារសិទ្ធិស្ត្រីផ្ទាល់របស់សមាគមអាដហុក សាខាខេត្តសៀមរាប ។
- ទិន្នន័យបន្ទាប់បន្សំ ៖ គឺជាប្រភេទនិន្នន័យដែលមានស្រាប់ ដែលក្រុមយើងខ្ញុំបានធ្វើការប្រមូលដោយការទាញយកឯកសារពីសៀវភៅបោះពុម្ពផ្សាយ ដោយការសិក្សារៀនសូត្រនៅសាកលវិទ្យាល័យ ឯកសាររបស់សាស្ត្រាចារ្យ ព្រមទាំងឯកសារដែលក្រុមយើងខ្ញុំទទួលបានពីការផ្តល់ពីសមាគមអាដហុក សាខាខេត្តសៀមរាប និងការប្រមូលឯកសារដែលមានពាក់ព័ន្ធមួយចំនួនទៀតដូចជា រដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ព្រមទាំងការស្រាជ្រាវតាមរយៈអ៊ីនធឺណែតផងដែរ ។

## ៣.៤- ការកំណត់ទំហំ និងការជ្រើសរើសសំណាក

ការកំណត់ទំហំសំណាក និងការជ្រើសរើសសំណាកនៅសមាគមអាដហុក សាខាខេត្តសៀមរាប មានដូចខាងក្រោម ៖

### ៣.៤.១- ការកំណត់ទំហំសំណាក

ក្នុងការប្រមូលទិន្នន័យ និងប្រភពព័ត៌មានឱ្យបានច្បាស់លាស់ទៅលើប្រធានបទ ក្រុមយើងខ្ញុំបានសម្រេចធ្វើការកំណត់ទំហំសំណាក ដើម្បីយកមកធ្វើការសម្ភាសន៍ ដូចខាងក្រោម ៖

- ប្រធានសមាគមអាដហុក សាខាខេត្តសៀមរាប ចំនួន ១ នាក់
- ប្រធានផ្នែកស្ត្រី និងកុមាររបស់សមាគមអាដហុក សាខាខេត្តសៀមរាប ចំនួន ២ នាក់ ។

### ៣.៤.២- ការជ្រើសរើសសំណាក

ការជ្រើសរើសសំណាក ក្រុមរបស់យើងខ្ញុំបានធ្វើការសម្ភាសន៍ដោយផ្ទាល់មាត់ ជាមួយនឹងប្រធានផ្នែកស្ត្រី និងប្រធាននៃសមាគមអាដហុក សាខាខេត្តសៀមរាប និងបុគ្គលិកទទួលបន្ទុកផ្នែកផ្សេងៗទៀតនៅក្នុងសមាគមនេះ ដើម្បីទទួលបាននូវទិន្នន័យក្នុងការសាកសួរ ។

## ៣.៥- ឧបករណ៍ និងសម្ភារនៃការស្រាវជ្រាវ

ដើម្បីធ្វើឱ្យការស្រាវជ្រាវនេះ មានដំណើរការល្អ មានភាពងាយស្រួលដោយរលូន ក្រុមរបស់យើងខ្ញុំបានធ្វើការប្រើប្រាស់នូវឧបករណ៍ និងសម្ភារនៃការស្រាវជ្រាវមួយចំនួនដូចខាងក្រោម ៖

### ៣.៥.១- ឧបករណ៍នៃការស្រាវជ្រាវ

ចំពោះឧបករណ៍នៃការស្រាវជ្រាវ ក្រុមយើងខ្ញុំបានបង្កើតជាកម្រងសំណួរដើម្បីធ្វើការស្រាវជ្រាវ ពីព្រោះថាកម្រងសំណួរ គឺជាឧបករណ៍នៃការស្រាវជ្រាវដ៏ចាំចាច់បំផុត ដែលសម្រាប់យកមកប្រើប្រាស់នៅក្នុងការស្រាវជ្រាវ និងប្រមូលយកទិន្នន័យ ។

### ៣.៥.២- សម្ភារនៃការស្រាវជ្រាវ

ចំពោះសម្ភារនៃការស្រាវជ្រាវ ក្រុមរបស់យើងខ្ញុំមានជាអាទិ៍:

- កម្រងសំណួរ
- សៀវភៅកត់ត្រា និងប៊ិច ក្រដាសរាម
- កុំព្យូទ័រ
- ម៉ាស៊ីនថតរូប
- ប្រព័ន្ធអ៊ីនធឺណែត
- ទូរស័ព្ទ
- មធ្យោបាយធ្វើដំណើរ(ម៉ូតូ) ។

## ៣.៦- វិធីសាស្ត្រប្រមូលទិន្នន័យ

ដើម្បីប្រមូលទិន្នន័យដែលទាក់ទងទៅនឹងប្រធានបទនៃការស្រាវជ្រាវ ក្រុមយើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម ៖

- **វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យចម្បង** គឺជាទិន្នន័យដែលទទួលបានតាមរយៈ ការចុះធ្វើកម្មសិក្សានៅសមាគមអាដហុក សាខាខេត្តសៀមរាប ដោយបានធ្វើបទសម្ភាសន៍ជាមួយលោកប្រធាន និងប្រធានផ្នែកការិយាល័យស្ត្រី នៃសមាគមអាដហុក សាខាខេត្តសៀមរាប និងសមាជិកដែលទទួលបន្ទុកផ្នែកផ្សេងៗទៀត ។
- **វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យបន្ទាប់បន្សំ** គឺជាទិន្នន័យដែលក្រុមស្រាវជ្រាវរបស់យើងខ្ញុំបានធ្វើការប្រមូលតាមរយៈ គេហទំព័ររបស់សមាគមផ្ទាល់ ឯកសារដែលមានពីរមុនៗ និងឯកសារមួយចំនួនដែលអង្គភាពមានស្រាប់ ។

## ៣.៧- វិធីសាស្ត្រវិភាគ និងបកស្រាយទិន្នន័យ

ដើម្បីទទួលបាននូវទិន្នន័យដែលមានខ្លឹមសារស្របតាមទិន្នន័យចម្បង និងមានអត្ថន័យត្រឹមត្រូវទៅតាមទិន្នន័យបន្ទាប់បន្សំមួយចំនួននោះ ក្រុមយើងខ្ញុំបានប្រើវិធីសាស្ត្រវិភាគ និងបកស្រាយទិន្នន័យ ដោយលើកយកទិន្នន័យដែលប្រមូលបាន យកមកធ្វើការពិភាក្សាគ្នាវែកញែករកចំណុចសំខាន់ៗនៃប្រធានបទរបស់ក្រុមសារណាយើងខ្ញុំ ។

### ៣.៧.១- វិធីសាស្ត្រវិភាគទិន្នន័យ

ក្រោយពីសមាជិកនីមួយៗក្នុងក្រុមសារណារបស់យើងខ្ញុំ បានធ្វើការប្រមូលទិន្នន័យពីសំណាកបានរួចរាល់ហើយនោះ ក្រុមយើងខ្ញុំបានយកទិន្នន័យទាំងអស់នោះមកធ្វើការវិភាគដោយជ្រើសរើសយកវិធីសាស្ត្រវិភាគទិន្នន័យបែបគុណវិស័យមកធ្វើការវិភាគ ដែលជាការវិភាគដោយប្រើប្រាស់នូវទិន្នន័យ ឬព័ត៌មានទាំងឡាយណាដែលបានមកពីការសម្ភាសន៍ផ្ទាល់មាត់ ។

### ៣.៧.២- វិធីសាស្ត្របកស្រាយទិន្នន័យ

ក្រោយពីបានធ្វើការប្រមូលទិន្នន័យ ដោយសម្ភាសន៍ និងធ្វើការស្រាវជ្រាវរួចមក ក្រុមរបស់យើងខ្ញុំបានជ្រើសយកនូវវិធីសាស្ត្រក្នុងការបកស្រាយទិន្នន័យ គឺវិធីសាស្ត្របកស្រាយបែបពិពណ៌នា ដែលជាការបកស្រាយដោយពិពណ៌នា ពន្យល់ និងបកស្រាយព្រឹត្តិការណ៍ដែលកំពុងកើតមានឡើងក្នុងជីវភាពរស់នៅរបស់មនុស្សក្នុងពេលបច្ចុប្បន្ន ឯកសារ និងនៅតាមច្បាប់ផ្សេងៗ ។

# ជំពូកទី ៤
# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

## ៤.១- ស្ថានភាពទូទៅរបស់ស្ថាប័ន

ក្រុមយើងខ្ញុំនឹងធ្វើការបង្ហាញអំពី ប្រវត្តិ និមិត្តសញ្ញា ពានរង្វាន់ និងជ័យលាភីដែលទទួលបាន ទស្សនៈវិស័យ បេសកកម្ម គោលដៅ គុណតម្លៃ រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច និងសមត្ថកិច្ចរបស់សមាគមអាដហុកជាដើម ។

រូបភាពទី២ ៖ ស្លាកឈ្មោះរបស់សមាគមអាដហុក ខេត្តសៀមរាប




រូបភាពទី៣ ៖ អគាររបស់សមាគមអាដហុក ខេត្តសៀមរាប



## ៤.១.១- ប្រវត្តិរបស់សមាគមអាដហុក

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា មានឈ្មោះហៅថា "សមាគមអាដហុក" សរសេរអក្សរកាត់ជាភាសាខ្មែរ "អាដហុក" និងសរសេរជាភាសាឡាតាំង "ADHOC" ។ ហើយសមាគមអាដហុក គឺជាអង្គការខ្មែរដំបូងគេបង្អស់ ដែលបានបង្កើតឡើងដោយអតីតអ្នកទោសនយោបាយមួយក្រុម នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៩១ ។ ក្រោយពេលដែលមានសន្ធិសញ្ញា និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលចុះហត្ថលេខាដោយភាគីខ្មែរទាំងបួនបក្ស នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ ស្តីពី "ដំណោះស្រាយនយោបាយរួមមួយនៃជម្លោះនៅកម្ពុជា" នាទីក្រុងប៉ារីស ប្រទេសបារាំង។

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយ ឯករាជ្យ អព្យាក្រឹត មិនរកផលចំណេញ និងមិនស្ថិតក្រោមការឃុំគ្រងរបស់គណបក្សនយោបាយណាមួយទេ ។ មួយវិញទៀត សមាគមអាដហុកត្រូវបានទទួលស្គាល់ និងយល់ព្រមឱ្យបង្កើតឡើងដោយ **សម្តេចព្រះបាទនរោត្តម សីហនុ** កាលពីថ្ងៃទី ១០ ខែមីនា ឆ្នាំ ១៩៩២ នៅពេលដែលព្រះអង្គមានព្រះរាជតួនាទីជាព្រះប្រមុខរដ្ឋ និងជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា និងដោយ **សម្តេច ហ៊ុនសែន** កាលពីថ្ងៃទី ១៩ ខែមីនា ឆ្នាំ ១៩៩២ ដែលនៅពេលនោះលោកមានតួនាទីជា ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី នៃរដ្ឋកម្ពុជា ព្រមទាំងទទួលស្គាល់ជាផ្លូវការណ៍ដោយក្រសួងមហាផ្ទៃ តាម សជណ លេខ ២៧៨ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០០០ ។

គោលបំណងចម្បងរបស់សមាគមអាដហុក គឺដើម្បីជួយជនរងគ្រោះពីការរំលោភបំពានក្នុងការស្វែងរកយុត្តិធម៌ ការពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋនៅក្នុងការទាមទារសិទ្ធិរបស់ពួកគេ និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យបញ្ចុះបញ្ចូល និងតស៊ូមតិ ដើម្បីកែលម្អច្បាប់ គោលនយោបាយ ស្ថាប័ននានា និងការអនុវត្តច្បាប់ ។

### ក. អត្ថន័យនៃរូបនិមិត្តសញ្ញា

រូបភាពទី៤ ៖ និមិត្តសញ្ញារបស់សមាគមអាដហុក



និមិត្តសញ្ញារបស់សមាគមអាដហុក គឺជាតំណាងដោយរូបព្រហ្មមុខបួន និងដៃទ្រពីក្រោមព្រហ្មមុខបួនមានបីពណ៌ ។ រូបសញ្ញានេះមានអត្ថន័យសម្គាល់ដូចតទៅ ៖

- រូបព្រហ្មមុខបួន តំណាងឱ្យព្រហ្មវិហារធម៌ទាំង ៤ គឺ ៖
  - មេត្តា (សេចក្តីប្រណី និងរាប់អានគ្នា)
  - ករុណា (ការអាណិត អាសូរ)
  - មុទិតា (ទឹកចិត្តត្រេកអរ)
  - ឧបេក្ខា (ការតាំងចិត្តជាកណ្តាល) ។
- ដៃទ្រពីក្រោមព្រហ្មមុខបួនមានបីពណ៌ រួមមាន ពណ៌ស ពណ៌លឿង និងពណ៌ខ្មៅ តំណាងឱ្យពណ៌សម្បុរនៃមនុស្សជាតិមិនរើសអើង និងមិនប្រកាន់ជាតិសាសន៍នៅលើពិភពលោក ។

### ខ. ពានរង្វាន់ និងជ័យលាភីដែលទទួលបាន

- រង្វាន់មូនិធិសិទ្ធិមនុស្សរបស់ប្រទេសបារាំង ដែលផ្តល់ដោយលោក **ដានីញ៉ែល មីតេរ៉ង់** នៅថ្ងៃទី ២៩ ខែវិច្ឆកា ឆ្នាំ ១៩៩៣ ។
- រង្វាន់មូនិធិសិទ្ធិមនុស្សប្រចាំអាស៊ីលើកទី ៣ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន នៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៩៩៨ ។
- រង្វាន់ដែលផ្តល់ដោយក្រុមអ្នកច្បាប់ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក នៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ ១៩៩៩ ។
- រង្វាន់សិទ្ធិមនុស្សនៃសាធារណៈរដ្ឋបារាំង ដែលផ្តល់ដោយលោកនាយករដ្ឋមន្ត្រី **លីយ៉ូណែល ហ្សូសប៉ុង**(Lionel Jospin) នៅរដ្ឋាភិបាលបារាំង នាឆ្នាំ ១៩៩៩ ។
- រង្វាន់មានទឹកប្រាក់ចំនួន ១២០,០០០ ហ្វ្រង់ នៅសារៈមន្ទីរ លូហ្វ្រឺ(LouVre) ក្រុងប៉ារីស នៅថ្ងៃទី ៩ ខែធ្នូ ឆ្នាំ១៩៩៩ ។
- រង្វាន់ (MARTIN ENNALS AWARD) ជារង្វាន់ណូបែល សម្រាប់អ្នកការពារសិទ្ធិមនុស្ស ឆ្នាំ ២០១៧ ដែលផ្តល់ដោយអង្គការអន្តរជាតិធំៗចំនួន ១០ នៅទីក្រុង GENEVE ប្រទេសស្វីស នៅថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៧ ។

## ៤.១.២- ទស្សនវិស័យ បេសកកម្ម គោលដៅ និង គុណតម្លៃរបស់សមាគមអាដហុក

### ក. ទស្សនវិស័យ

សង្គមមួយដែលគោរពសិទ្ធិមនុស្ស និងច្បាប់ ។

### ខ. បេសកកម្ម

អប់រំ និងផ្តល់អំណាចជូនប្រជាពលរដ្ឋដើម្បីឱ្យបានដឹង និងចេះការពារសិទ្ធិរបស់ខ្លួនដោយខ្លួនឯង និងដើម្បីធ្វើការតស៊ូមតិ និងផ្តល់ការគាំទ្រដល់អ្នកកាន់អំណាចរដ្ឋឱ្យមានការកែប្រែឥរិយាបទ ឆ្ពោះទៅរកអភិបាលកិច្ចល្អ និងការគោរពសិទ្ធិមនុស្ស ។

**គ. គោលដៅ**

ជំរុញឱ្យមានការផ្លាស់ប្តូរ ខាងគោលនយោបាយ និងការអនុវត្តជាក់ស្តែងរបស់ស្ថាប័នលទ្ធិប្រជាធិបតេយ្យ ជាពិសេសប្រព័ន្ធតុលាការ និងធ្វើការពង្រឹងសង្គមស៊ីវិល ។

**ឃ. គុណតម្លៃ**

ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនប្រកាន់បក្សនយោបាយ និងមិនរកប្រាក់ចំណេញ ។

### ៤.១.៣- រចនាសម្ព័ន្ធ

សមាគមអាដហុក សាខាខេត្តសៀមរាប មានរចនាសម្ព័ន្ធដូចតទៅ ៖

- អ្នកសម្របសម្រួល ០១រូប
- អ្នកជំនាញអង្កេតស្ត្រី និងកុមារ ០១រូប
- អ្នកជំនាញស៊ូមតិ ០២រូប
- អ្នកជំនាញអង្កេត ០២រូប

តារាងទី១ ៖ រចនាសម្ព័ន្ធរបស់សមាគមអាដហុក សាខាខេត្តសៀមរាប




### ៤.១.៤- តួនាទី និងភារកិច្ច

សមាគមអាដហុក គឺជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលមានតួនាទីនៅក្នុងការជួយសង្គមជាតិពីការរំលោភបំពានសិទ្ធិមនុស្ស ដែលសមាគមនេះធ្វើការទៅលើ ៖

- សិទ្ធិមនុស្ស និងដីធ្លី
- និងសិទ្ធិស្ត្រី និងកុមារ ។

**ក. សកម្មភាពនៃផ្នែកនីមួយៗរបស់សមាគមអាដហុក សាខាខេត្តសៀមរាប**

សមាគមអាដហុក បានធ្វើការទៅលើរឿងពីរផ្នែកធំៗ គឺផ្នែកគាំពារសិទ្ធិមនុស្ស និងដីធ្លី ហើយនិងសិទ្ធិស្ត្រី និងកុមារ ដែលមានសកម្មភាពសំខាន់ៗ ៣ គឺ ៖

- **សកម្មភាពឃ្លាំមើល និងអន្តរាគមន៍ ៖** ជាការសិក្សាស្វែងរកការពិតទៅតាមករណីនីមួយៗ ការផ្ដល់ដំបូន្មានផ្នែកច្បាប់ និងការផ្ដល់សម្ភារ ថ្លៃធ្វើដំណើរ ជំនួយផ្នែកសុខភាព និងការធ្វើមាតុភូមិនិវត្តន៍ដល់ជនរងគ្រោះដោយការជួញដូរកម្លាំងពលកម្ម និងពលករចំណាកស្រុក ។
- **សកម្មភាពពង្រឹងសិទ្ធិអំណាច ៖** ជាការផ្ដល់វគ្គបណ្ដុះបណ្ដាល ដើម្បីកសាងសមត្ថភាព ការរៀបចំសិក្ខាសាលា កិច្ចប្រជុំ ឬការកសាងបណ្ដាញ ។
- **ការតស៊ូមតិ ៖** ជាការធ្វើសន្និសីទការសែត ធ្វើសេចក្ដីថ្លែងការណ៍ របាយការណ៍តាមវិស័យផ្សេងៗ ឬសិក្ខាសាលា កិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍ និងជនរងគ្រោះ ដើម្បីលើកទឹកចិត្តឱ្យពួកគេចែករំលែកនូវព័ត៌មាន និងស្វែងរកដំណោះស្រាយរួមចំពោះជម្លោះ និងបញ្ហាប្រឈមនានា ។

## ខ. សមត្ថកិច្ចរបស់សមាគមអាដហុក សាខាខេត្តសៀមរាប

សមាគមអាដហុក នៅខេត្តសៀមរាប ត្រូវបានបែងចែកសមត្ថកិច្ចជាពីរគឺ ៖

- **សមត្ថកិច្ចតាមមុខងារ ៖** សមាគមអាដហុក ខេត្តសៀមរាប គឺធ្វើការទៅលើការរំលោភបំពានសិទ្ធិមនុស្ស ដែលសមាគមផ្ដោតសំខាន់ទៅលើពីរចំណុចសំខាន់ៗដូចជា ៖
    - សិទ្ធិមនុស្ស និងដីធ្លី
    - និងសិទ្ធិស្ត្រី និងកុមារ ។

សមាគមនេះ ធ្វើការសម្រេចដោយឯកច្ឆ័នដោយលោកប្រធាន ១រូប ចំពោះរឿងសិទ្ធិមនុស្ស និងដីធ្លី និងសិទ្ធិស្ត្រី និងកុមារ ។

មួយវិញទៀត សមាគមអាដហុក ខេត្តសៀមរាប ក៏មិនខុសពីសមាគមអាដហុកនៅតាមបណ្ដាខេត្តដទៃទៀតដែរ ពោលគឺមានសិទ្ធិធ្វើទៅលើរឿង ៖

- សិទ្ធិមនុស្ស និងដីធ្លី
- និងសិទ្ធិស្ត្រី និងកុមារ ។

- **សមត្ថកិច្ចតាមដែនដី**

សមាគមអាដហុក ខេត្តសៀមរាប មានសមត្ថកិច្ចលាតសន្ធឹងតែក្នុងរង្វង់ដែនដីនៃខេត្តសៀមរាបតែប៉ុណ្ណោះ ។ ដូច្នេះ សមគមអាដហុក ខេត្តសៀមរាប ត្រូវបានគ្របដណ្ដប់ទៅលើក្រុងចំនួន ១ (មួយ) និងស្រុកចំនួន ១១ (ដប់មួយ) ដែលរួមមាន ក្រុងសៀមរាប ស្រុកពួក ស្រុកក្រឡាញ់ ស្រុកស្រីស្នំ ស្រុកវ៉ារិន ស្រុកអង្គរជុំ ស្រុកបន្ទាយស្រី ស្រុកអង្គរធំ ស្រុកប្រាសាទបាគង ស្រុកស្វាយលើ ស្រុកសូទ្រនិគម និងស្រុកជីក្រែង ។

## ៤.១.៥- ដៃគូសហប្រតិបត្តិការរបស់សមគមអាដហុក សាខាខេត្តសៀមរាប

សមាគមអាដហុក គឺជាអង្គការក្រៅរដ្ឋាភិបាលមួយដែលជួយដល់ប្រទេសកម្ពុជា ។ ក្នុងនោះដែរ សមាគមអាដហុក ក៏បានធ្វើការសហប្រតិបត្តិការជាមួយ ៖

- លីកាដូ( licadho )
- តុលាការ
- នគរបាលយុត្តិធម៌
- ស្ថាប័នរដ្ឋមួយចំនួនដូចជា ក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារី ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ
- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ
- អង្គការរចនាស្ត្រី
- និងអង្គការបន្ទាយស្រី ។

## ៤.២- លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងផ្នែកនៃលទ្ធផលស្រាវជ្រាវនេះ ក្រុមយើងខ្ញុំនឹងធ្វើការលើកឡើងអំពីចំណុចសំខាន់ៗដែលមានដូចជា ៖ កត្តាដែលបណ្តាលឱ្យកើតមានឡើងនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ នីតិវិធី ឬដំណើរការនៃការអនុវត្តការការពារសិទ្ធិស្ត្រីដោយផ្តោតសំខាន់ទៅលើការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ និងបញ្ហាប្រឈមរបស់អង្គភាពក្នុងការអនុវត្តនូវសកម្មភាពនានា ។

ដោយយោងទៅតាមការធ្វើបទសម្ភាសន៍ផ្ទាល់ជាមួយនឹងមន្ត្រីគម្រោងការពារសិទ្ធិស្ត្រី និងកុមារ ក្រុមយើងខ្ញុំបានទទួលនូវសំណុំរឿងចំនួន ២០ ករណី ដែលក្នុងនោះមាន ៨ សំណុំរឿងទាក់ទងនឹងករណីការរំលោភសេពសន្ថវៈ និង ១២ ករណី ទាក់ទងទៅនឹងករណីអំពើហិង្សាក្នុងគ្រួសារ ។ នៅក្នុងនោះដែរក្រុមយើងខ្ញុំបានពិនិត្យមើលឃើញថាសំណុំរឿងទាំង ២០ ករណី គឺជាបទល្មើសព្រហ្មទណ្ឌ ដោយនៅក្នុងករណីទាំង ២០ នោះ គឺមានបណ្តឹងរដ្ឋប្បវេណីចំនួន ២ ដែលជនរងគ្រោះស្នើសុំលែងលះប្តីរបស់ខ្លួន ។

### ៤.២.១- ប្រភេទនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ

### ក. ការរំលោភសេពសន្ថវៈ

ករណីរំលោភសេពសន្ថវៈទាំង ៨ ករណី ត្រូវបានអន្តរាគមន៍ដោយអង្គការអាដហុកដែលក្រុមយើងខ្ញុំអាចបែងចែកជាប្រភេទនៃបទល្មើសដែលបានកើតឡើងដូចជា ៖

- ករណីរំលោភសេពសន្ថវៈ ៨ ករណី គឺជាបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរដែលក្នុងនោះដែរមាន
    - ឪពុកបង្កើត រំលោភកូនខ្លួនឯងចំនួន ២ ករណី
    - ឪពុកចុង រំលោភកូន (កូនចុង) ចំនួន ១ ករណី
    - បងជីដូនមួយ រំលោភប្អូនស្រី ចំនួន ១ ករណី
    - ជនប្រព្រឹត្តជាអ្នកដទៃ ចំនួន ៤ ករណី ។

ក្រាហ្វិកទី ១ ៖ សំណុំរឿងទាក់ទងនឹងបទល្មើសរំលោភសេពសន្ថវៈ




## ខ. អំពើហិង្សាក្នុងគ្រួសារ

ករណីអំពើហិង្សាទាំង ១២ ករណីគឺជាបទល្មើសព្រហ្មទណ្ឌ ហើយក្រុមយើងខ្ញុំអាចបែងចែកជាប្រភេទអំពើហិង្សាដូចខាងក្រោម ៖

- ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធរហូតដល់ស្លាប់ចំនួន ៤ ករណី
- ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធរហូតដល់ពិការចំនួន ១ ករណី
- ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធឱ្យមានរបួសស្នាមកម្រិតមធ្យមមានចំនួន ៤ ករណី
- ករណីអំពើហិង្សាលើផ្លូវចិត្តចំនួន ២ ករណី
- ករណីអំពើហិង្សាលើផ្លូវភេទចំនួន ១ ករណី ។

ក្រាហ្វិកទី ២ ៖ សំណុំរឿងទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ



### ៤.២.២- មូលហេតុដែលនាំឱ្យមានការរំលោភបំពានទៅលើសិទ្ធិស្ត្រី

#### ក. ករណីរំលោភសេពសន្ថវៈ

ដោយយោងទៅតាមទិន្នន័យដែលក្រុមយើងខ្ញុំទទួលបាន និងការសម្ភាសន៍ផ្ទាល់ជាមួយនឹងមន្ត្រីរបស់អង្គការអាដហុករួចមក គឺក្រុមយើងខ្ញុំទទួលបាននូវទិន្នន័យនៅក្នុងឆ្នាំ ២០១៩ ចំនួន ៨ ករណីដែលទាក់ទងទៅនឹងមូលហេតុចម្បងៗនៃការរំលោភសេពសន្ថវៈទៅលើស្ត្រី គឺមានដូចតទៅ ៖

តារាងទី២ ៖ មូលហេតុសំខាន់ៗនៃការរំលោភសេពសន្ថវៈ

| ល.រ | ប្រភេទនៃការរំលោភសេពសន្ថវៈដែលបានអន្តរាគមន៍ | មូលហេតុសំខាន់ៗ |
|---|---|---|
| ១ | ឪពុកបង្កើតរំលោភកូនខ្លួនឯងបង្កើតចំនួន ២ ករណី | – ឪពុកជាមនុស្សមនុស្សញៀនស្រា កាចសាហាវប្រើអំពើហិង្សាក្នុងគ្រួសាររ៉ាំរ៉ៃ(ញៀនស្រា) ។<br>– ឪពុកស្រវឹងស្រាហើយចាប់រំលោភកូនស្រីតែម្តង(ញៀនស្រា) ។<br>– ដោយសារម្តាយរបស់ជនរងគ្រោះទៅធ្វើការនៅភ្នំពេញ ទុកកូនស្រី ៣នាក់ឱ្យនៅជាមួយឪពុក ដែលធ្វើឱ្យឪពុកមានឱកាសធ្វើបាបកូនស្រីច្បងពីរលើក ប៉ុន្តែបានសម្រេចតែម្តង ។ |
| ២ | ឪពុកចុងរំលោភកូនចុងចំនួន ១ ករណី | – ឪពុកចុងគ្មានមនុស្សសញ្ចេតនាជាមួយនឹងកូនដើម ដោយមានចេតនាធ្វើបាបកូនចុងតែម្តង(មានចំណង់ផ្លូវភេទ) ។<br>– ម្តាយដែលជាប្រពន្ធចុងរបស់ជនប្រព្រឹត្ត និងជាម្តាយរបស់ជនរងគ្រោះទៅធ្វើការ ដែលជាឱកាសឱ្យជនប្រព្រឹត្តអាចធ្វើសកម្មភាពបាន ។ |
| ៣ | បងជីដូនមួយរំលោភប្អូនស្រីជីដូនមួយចំនួន ១ ករណី | – ដោយសារម្តាយរបស់ជនរងគ្រោះទៅធ្វើការនៅខេត្តសៀមរាប ទុកឱ្យកូនស្រីនៅជាមួយម្តាយមីង ដែលជាឱកាសឱ្យបងជីដូនមួយចាប់រំលោភទៅលើក្មេងស្រីរងគ្រោះបាន(មានចំណង់ផ្លូវភេទ) ។<br>– ជនប្រព្រឹត្តជាមនុស្សល្មោភកាម ។ |
| ៤ | ជនប្រព្រឹត្តជាអ្នកជទៃចំនួន ៤ ករណី | – ជនរងគ្រោះមកពីរៀនគួរតែម្នាក់ឯងនៅម៉ោង ៧ យប់ ហើយជិះកង់តាមផ្លូវស្ងាត់គ្មានមនុស្ស ហើយងងឹតទៀត ។<br>– ជនប្រព្រឹត្តលបចាំធ្វើសកម្មភាពចាប់នៅកន្លែងស្ងាត់(មាន |

| | | |
|---|---|---|
| | | ចំណង់ផ្លូវភេទ ) ។<br>– ជនរងគ្រោះជាមនុស្សមានសតិមិនគ្រប់គ្រាន់ ហើយដើរសុំលុយគេក្នុងពេងការ ដែលជាឱកាសឱ្យជនប្រព្រឹត្តដឹកដៃល្បួងទៅរំលោភតែម្តង(មានចំណង់ផ្លូវភេទ) ។<br>– ជនប្រព្រឹត្តជាគ្រូ ហើយបានដឹងថាជនរងគ្រោះនៅម្នាក់ឯងយូរមកហើយ ក៏បានឆ្លៀតឱកាសចាប់ជនរងគ្រោះរំលោភតែម្តង(មានចំណង់ផ្លូវភេទ) ។<br>– ជនប្រព្រឹត្តធ្វើជាបបួលជនរងគ្រោះទៅបេះឪឡឹកនៅចំការក្បែរផ្ទះ ហើយល្បួងទៅក្នុងព្រៃដោយកហុក់ថាកុំស្រែកខ្លាចឃុំទិច រួចក៏ធ្វើសកម្មភាពរំលោភតែម្តង( មានចំណង់ផ្លូវភេទ ) ។ |

## ខ. អំពើហិង្សាក្នុងគ្រួសារ

ដោយឡែកចំពោះករណីអំពើហិង្សាក្នុងគ្រួសារលើស្ត្រីវិញ ក្រុមយើងខ្ញុំទទួលបានពីការសម្ភាសន៍ផ្ទាល់ជាមួយនឹងមន្ត្រីរបស់អង្គការអាដហុក និងប្រមូលនូវទិន្នន័យពីសំណុំរឿងដែលទទួលបាន គឺនៅក្នុងឆ្នាំ ២០១៩ មានចំនួន ១២ ករណីដែលមានមូលហេតុចម្បងៗដែលធ្វើឱ្យមានអំពើហិង្សាលើស្ត្រី គឺមានដូចតទៅ ៖

តារាងទី៣ ៖ មូលហេតុសំខាន់ៗនៃអំពើហិង្សាក្នុងគ្រួសារ

| ល.រ | ប្រភេទនៃការប្រើអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី | មូលហេតុសំខាន់ៗ |
|---|---|---|
| ១ | ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធរហូតដល់ស្លាប់ចំនួន ៤ ករណី | – ទំនាស់រឿងពាក្យសម្តីរវាងប្អូនប្រុសធ្វើបង្កន់លើដីបងស្រី ហើយបងស្រីនិយាយស្តីថាគ្នាទៅវិញទៅមក ធ្វើឱ្យប្អូនប្រុសទ្រាំមិនបានក៏ទាញកាំបិតកាប់ទៅលើក្បាលតែម្តង ។<br>– ប្អូនស្រីទៅជួយបងស្រីនៅពេលដែលបងប្រុសកាប់ទៅលើបងស្រីខ្លួនឯង ហើយបងប្រុសក៏ចាប់ប្អូនស្រីកាប់ស្លាប់នៅនឹងមុខផ្ទះតែម្តង ។<br>– ប្តីជាមនុស្សញៀនស្រាជារៀងរាល់ថ្ងៃ ហើយលុះដល់ថ្ងៃកើតហេតុក៏ឈានទៅដល់ការកាប់សម្លាប់ប្រពន្ធខ្លួនឯងតែម្តង ។<br>– កើតឡើងពីការប្រចណ្ឌរបស់ប្តីទៅលើប្រពន្ធ ថាលួចមានប្រុសថ្មី ។<br>– ប្រពន្ធសុំលែងច្រើនដងពេកទ្រាំមិនបាន ក៏ចាក់សាំងដុតប្រពន្ធ និង |

| | | |
|---|---|---|
| | | កូន និងខ្លួនឯង ។<br>– ប្ដីប្រពន្ធឈ្លោះគ្នាទាស់ទែងពាក្យសម្ដីគ្នារៀងរាល់ថ្ងៃ ដែលបង្កើតជាចិត្តសាហាវក្នុងខ្លួន ។ |
| ២ | ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធរហូតដល់ពិការចំនួន ១ ករណី | – ប្ដីចោទប្រពន្ធថាមានសាហាយស្មន់ជាមួយប្រុសផ្សេង ។<br>– ប្រពន្ធបដិសេធថាមិនមានសាហាយស្មន់ជាមួយអ្នកណាក៏ទាស់ពាក្យសម្ដីគ្នារហូតប្ដីទាញខ្ញែវកាប់ដាច់រលាក្បាលបន្តិច ។ |
| ៣ | ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធឱ្យមានរបួសស្នាមកម្រិតមធ្យមមានចំនួន ៤ ករណី | – ប្ដីមានស្រីថ្មីទៀតធ្វើឱ្យប្រពន្ធមានសំពាធផ្លូវចិត្ត ។<br>– ប្រពន្ធជេរប្ដីធ្វើឱ្យប្ដីខឹង ហើយប្ដីក៏បានវាយទៅលើប្រពន្ធតែម្ដង ។<br>– ប៉ុនប៉ងសម្លាប់ តែប្រពន្ធអាចរត់រួចខ្លួនបានដោយបានត្រឹមតែវាយធ្វើបាបលើរូបរាងកាយ ។<br>– ប្រើប្រពន្ធឱ្យដាន់ចង្កេះឱ្យមិនបាន ក៏ទាញពូថៅវាយត្រូវក្បាលបែក ៤ ថ្នេរ ។<br>– ទារលុយបងថ្លៃមិនបាន ហើយខឹងត្រង់ប្រពន្ធជាអ្នកដែលឱ្យខ្ចី ក៏វាយធ្វើបាបប្រពន្ធ និងដុតផ្ទះចោលតែម្ដង ។<br>– ជនប្រព្រឹត្តផឹកស្រាស្រវឹង ហើយយកដែកកេះដុតផ្ទះចោល ។<br>– ប្ដីជាមនុស្សញៀនស្រារាល់ថ្ងៃ ។ |
| ៤ | ករណីអំពើហិង្សាលើផ្លូវចិត្តចំនួន ២ ករណី | – ប្ដីមានប្រពន្ធមួយទៀត ហើយយកមកឌឺប្រពន្ធដើម ។<br>– ប្ដីប្រចណ្ឌខ្លាំងពេកជាមួយនឹងអ្នកជិតខាង ។<br>– ប្ដីយកកូនរត់ទៅណាមិនដឹង ធ្វើឱ្យប្រពន្ធនឹកកូនរបស់ខ្លួនជាខ្លាំង ។ |
| ៥ | ករណីអំពើហិង្សាលើផ្លូវភេទចំនួន ១ ករណី | – ប្ដីប្រចណ្ឌប្រពន្ធជាមួយនឹងប្អូនប្រុសរបស់ខ្លួនឯង ។<br>– ចាប់ប្រពន្ធបង្ខំឱ្យរួមភេទជាមួយនិងអ្នកដទៃ ។<br>– យកវត្ថុរឹងស៊កចូលប្រដាប់ភេទរបស់ប្រពន្ធ ។ |

### ៤.២.៣- ចំណុចស្នើសុំរបស់ជនរងគ្រោះ និងអ្នកតំណាងរបស់ជនរងគ្រោះ

### ក. ការរំលោភសេពសន្ថវៈ

ទន្ទឹមនឹងការដាក់ពាក្យបណ្ដឹងដែលជនរងគ្រោះ ឬអ្នកជិតខាងរបស់ជនរងគ្រោះ ឬសាច់ញាតិរបស់ជនរងគ្រោះ ដែលបានមករកសមាគមអាដហុកឱ្យជួយធ្វើអន្តរាគមន៍ទៅលើការលោភសេពសន្ថវៈដែលត្រូវបានរៀបរាប់ដូចខាងក្រោម ៖

តារាងទី៤ ៖ ការទាមទារបស់ជនរងគ្រោះនៃបទល្មើសរំលោភសេពសន្ថវៈ

| ល.រ | ប្រភេទនៃការរំលោភសេពសន្ថវៈដែលបានអន្តរាគមន៍ | ការទាមទាររបស់ជនរងគ្រោះ |
|---|---|---|
| ១ | ការរំលោភសេពសន្ថវៈមានចំនួន ៨ករណី | ទាមទារសុំឱ្យសមាគមអាដហុកជួយធ្វើអន្តរាគមន៍ស្វែងរកយុត្តិធម៌ និងផ្តន្ទាទោសជនប្រព្រឹត្តទៅតាមផ្លូវច្បាប់ ។ |

**ខ. អំពើហិង្សានៅក្នុងគ្រួសារ**

នៅក្នុងចំណុចនៃអំពើហិង្សានេះដែរឃើញថា អ្នកដែលដាក់ពាក្យបណ្តឹងមកសមាគមអាដហុក មានជនរងគ្រោះ សាច់ញាតិ និងអ្នកជិតខាង ដោយមានការស្នើមកកាន់អង្គការអាដហុកនូវចំណុចទាមទារផ្សេងៗមួយចំនួនដូចដែលបានបែងចែកនៅក្នុងតារាងខាងក្រោម ។ ម្យ៉ាងវិញទៀតនៅក្នុងចំណុចទាមទារនេះដែរ ក្រុមយើងខ្ញុំក៏នឹងលើកឡើងអំពីចំណុចទាមទារដែលអាជ្ញាធរមានសមត្ថកិច្ច និងសាលាដំបូងខេត្តសៀមរាប មកបញ្ចូលផងដែរ ។

តារាងទី៥ ៖ ការទាមរបស់ជនរងគ្រោះនៃបទល្មើសអំពើហិង្សាក្នុងគ្រួសារ

| ល.រ | ប្រភេទនៃការប្រើអំពើហិង្សាក្នុងគ្រួសារនៅលើស្ត្រី | ចំណុចចម្បងនៃការស្នើសុំរបស់ជនរងគ្រោះនិងអ្នកតំណាង |
|---|---|---|
| ១ | ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធរហូតដល់ស្លាប់ចំនួន ៤ ករណី | – ម្តាយរបស់ជនរងគ្រោះសុំឱ្យអង្គការអាដហុករកយុត្តិធម៌ និងតាមដាននីតិវិធីរបស់តុលាការនៃការអនុវត្តសំណុំរឿងទៅលើប្អូនថ្លៃរបស់ខ្លួន ។<br>– ជួយអន្តរាគមន៍ទៅសមត្ថកិច្ចឱ្យមានចំណាត់ការឱ្យបានលឿនទៅលើកូនប្រសាររបស់ខ្លួន ។<br>– តុលាការសុំជំនួយមេធាវីឱ្យអ្នកតំណាងជនរងគ្រោះ ព្រោះជនរងគ្រោះជាអ្នកមានជីវភាពលំបាក ។<br>– សុំជំនួយប្រឹក្សាផ្នែកច្បាប់ដល់អ្នកតំណាងជនរងគ្រោះ ។ |
| ២ | ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធរហូតដល់ពិការចំនួន ១ ករណី | – ជនរងគ្រោះស្នើសុំជំនួយប្រឹក្សាផ្នែកច្បាប់ ។<br>– ជួយរកយុត្តិធម៌ឱ្យជនរងគ្រោះ ។<br>– សាលាដំបូងខេត្ត បានស្នើសុំជំនួយផ្នែកមេធាវីដល់ជនរងគ្រោះ ។ |

| | | |
|---|---|---|
| | | – សាលាដំបូងខេត្តស្នើសុំជំនួយផ្នែកអាហាររូបត្ថម្ភដល់កូនៗរបស់ជនរងគ្រោះ ព្រោះពួកគេនៅតូច ហើយជនរងគ្រោះត្រូវពិការមួយចំហៀងខ្លួន ។ |
| ៣ | ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធឱ្យមានរបួសស្នាមកម្រិតមធ្យម មានចំនួន ៤ ករណី | – ជនរងគ្រោះស្នើសុំឱ្យអង្គការអាដហុកជួយរកយុត្តិធម៌ ។<br>– ជនរងគ្រោះសុំឱ្យអង្គការអាដហុកជួយសរសេរពាក្យបណ្ដឹងដើម្បីឱ្យខ្លួនដាក់ទៅតុលាការ ។<br>– ប្រពន្ធស្នើសុំមិនឱ្យសមត្ថកិច្ចដាក់ពាក្យបណ្ដឹងទៅតុលារ ។<br>– ជនរងគ្រោះស្នើសុំលែងលះជាមួយប្ដីនៅត្រឹមថ្នាក់ស្រុក ។<br>– ជនរងគ្រោះស្នើសុំឱ្យអង្គការអាដហុកជួយអន្ដរាគមន៍ទៅសមត្ថកិច្ចដែលទុករឿងឥតចាត់ការ ឱ្យពន្លឿនដំណើរនីតិវិធី ។<br>– ជនរងគ្រោះស្នើសុំឱ្យសមត្ថកិច្ចជួយតាមរកកូនស្រីរបស់ខ្លួន ។ |
| ៤ | ករណីអំពើហិង្សាលើផ្លូវចិត្ត ចំនួន ២ ករណី | – ជនរងគ្រោះស្នើសុំឱ្យអង្គការអាដហុកជួយអន្ដរាគមន៍ទៅសមត្ថកិច្ចដើម្បីពន្លឿន និងមានចំណាត់ការលើសំណុំរឿង ។<br>– សុំជំនួយផ្នែកប្រឹក្សាច្បាប់ ។<br>– ជនរងគ្រោះស្នើសុំឱ្យអង្គការអាដហុកជួយរកយុត្តិធម៌ ។<br>– ជនរងគ្រោះស្នើសុំលែងលះជាមួយនឹងប្ដីរបស់ខ្លួន ។<br>– ជងរងគ្រោះសុំបែងចែកទ្រព្យសម្បត្តិ និងសុំយកកូន ។ |
| ៥ | ករណីអំពើហិង្សាលើផ្លូវភេទ ចំនួន ១ ករណី | – សុំឱ្យអង្គការអាដហុកជួយរៀបចំដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីមានចំណាត់ការផ្លូវច្បាប់ ។<br>– ជនរងគ្រោះសុំលែងលះជាមួយនឹងប្ដី ហើយលែងរស់នៅជាមួយគ្នាទៀត ។ |

## ៤.២.៤- លទ្ធផលនៃការអន្តរាគមន៍អំពីការរំលោភបំពានទៅលើសិទ្ធិស្ត្រី

### ក. លទ្ធផលនៃការអន្ដរាគមន៍នៃការរំលោភសេពសន្ថវៈ

តាមរយៈការស្នើសុំឱ្យសមាគមអាដហុកជួយអន្ដរាគមន៍ទៅលើករណីរំលោភសេពសន្ថវៈដែលបានកើតឡើងចំពោះជនរងគ្រោះ តាមការទាមទាររបស់ជនរងគ្រោះផ្ទាល់ និងអ្នកតំណាងជនរងគ្រោះ ។ ដូច្នេះ ដោយយោងទៅតាមការចុះកម្មសិក្សា និងការស្រង់ទិន្នន័យផ្ទាល់ ក្រុមយើងខ្ញុំបានរកឃើញនូវលទ្ធផលនៃការស្នើសុំដែលមានបែងចែកដូចខាងក្រោម ៖

តារាងទី៦ ៖ លទ្ធផលនៃការអន្តរាគមន៍អំពីការរំលោភសេពសន្ថវៈ

| ល.រ | ប្រភេទនៃការរំលោភសេពសន្ថវៈដែលបានអន្តរាគមន៍ | លទ្ធផលនៃការអន្តរាគមន៍ |
|---|---|---|
| ១ | ឪពុកបង្កើតរំលោភកូនខ្លួនឯងបង្កើតចំនួន ២ ករណី | – សំណុំរឿងត្រូវបានបញ្ជូនដល់ចៅក្រមស៊ើបសួរ ហើយជនប្រព្រឹត្តនៅក្នុងពន្ធនាគារ ។<br>– ចៅក្រមស៊ើបសួរបានចេញដីកាកោះហៅក្មេងរងគ្រោះ និងក្រុមគ្រួសារទៅបំភ្លឺ ។<br>– ត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាបរួចរាល់ ។<br>– ត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តសៀមរាប ហើយចៅក្រមស៊ើបសួរបានហៅក្មេង និងម្តាយឪពុកក្មេងរងគ្រោះទៅសាកសួរ ។<br>– ត្រូវបានស្នងការបញ្ជូនទៅសាលាដំបូងខេត្តសៀមរាប រីឯបណ្តឹងរដ្ឋប្បវេណីត្រូវបានបញ្ចប់ ដោយម្តាយឪពុកជនរងគ្រោះទទួលសំណងពីក្រុមគ្រួសារជនប្រព្រឹត្តចំនួន ៦០០០ ដុល្លារ ។<br>– ចៅក្រមស៊ើបសួរបានចេញដីកាអញ្ជើញឱ្យក្រុមគ្រួសារជនរងគ្រោះ យកជនរងគ្រោះមកសួរ ។<br>– ករណីនេះ សំណុំរឿងបានបញ្ជូនទៅដល់ព្រះរាជអាជ្ញា ត្រៀម RI ទៅចៅក្រមស៊ើបសួរ ។ |
| ២ | ឪពុកចុងរំលោភកូនចុងចំនួន ១ ករណី | – សំណុំរឿងត្រូវបានបញ្ជូនទៅដល់ព្រះរាជអាជ្ញា និងត្រៀម RI ទៅចៅក្រមស៊ើបបន្តទៀត ។ |
| ៣ | បងជីដូនមួយរំលោភប្អូនស្រីជីដូនមួយចំនួន ១ ករណី | – សំណុំរឿងបានបញ្ជូនទៅដល់តុលាការ ។<br>– ជនប្រព្រឹត្តត្រូវបានជាប់ពន្ធនាគារ ។ |
| ៤ | ជនប្រព្រឹត្តជាអ្នកដទៃចំនួន ៤ ករណី | – សំណុំរឿងត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញា ហើយក្មេងប្រព្រឹត្តទៅក្នុងពន្ធនាគារ ចំណែកជនរងគ្រោះត្រូវបានម្តាយយកទៅផ្ញើរម្តាយមីងឱ្យជួយមើលថែ ។<br>– ជនប្រព្រឹត្តត្រូវបានជាប់ពន្ធនាគារ ។<br>– តុលាការបានកោះហៅគ្រួសារជនរងគ្រោះ និងជនរងគ្រោះ |

| | | |
|---|---|---|
| | | ចូលមកបំភ្លឺ ។<br>– សំណុំរឿងបានឈានទៅដល់ថៅក្រមស៊ើសួរ ហើយនិងកំពុងដំណើរការស៊ើបសួរជនរងគ្រោះ ។<br>– គ្រួសារជនរងគ្រោះទទួលបានសំណងផ្នែករដ្ឋប្បវេណីពីជនប្រព្រឹត្ត ។ |

## ខ. លទ្ធផលនៃការអន្តរាគមន៍អំពើហិង្សាក្នុងគ្រួសារ

នៅខាងក្រោមនេះ គឺជាលទ្ធផលដែលទទួលបានក្រោយពីទទួលបានការអន្តរាគមន៍ពីអង្គការអាដហុកទៅលើការប្រើអំពើហិង្សាទៅលើស្ត្រី ដែលត្រូវបានបែងចែក និងរៀបរាប់ដូចខាងក្រោម ៖

តារាងទី៧ ៖ លទ្ធផលអន្តរាគមន៍នៃអំពើហិង្សាក្នុងគ្រួសារ

| ល.រ | ប្រភេទនៃការប្រើអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី | លទ្ធផលនៃការអន្តរាគមន៍ |
|---|---|---|
| ១ | ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធរហូតដល់ស្លាប់ចំនួន ៤ ករណី | – ជនប្រព្រឹត្តបានសម្លាប់ខ្លួនឯងបន្ទាប់ពីធ្វើសកម្មភាពហើយចំនួន ២ ករណី ។<br>– ជនត្រូវចោទត្រូវបានជាប់ពន្ធនាគារចំនួន ១ ករណី ។<br>– អង្គការអាដហុកផ្តល់ជូននូវមេធាវីសម្រាប់អ្នកតំណាងជនរងគ្រោះចំនួន ១ ករណី ។<br>– សំណុំរឿងត្រូវបានបញ្ជូនទៅដល់តុលាការទាំងអស់ ។<br>– សម្របសម្រួលសរសេរពាក្យបណ្តឹងជូនជនរងគ្រោះ ។<br>– សំណុំរឿងបានបញ្ជូនទៅដល់ព្រះរាជអាជ្ញា ។ |
| ២ | ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធរហូតដល់ពិការចំនួន ១ ករណី | – ផ្តល់ប្រឹក្សាជំនួយផ្នែកច្បាប់ឱ្យជនរងគ្រោះ ។<br>– បានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។<br>– ជនប្រព្រឹត្តត្រូវបានជាប់ពន្ធនាគារ ។ |
| ៣ | ករណីអំពើហិង្សាលើសហព័ទ្ធដែលជាប្រពន្ធឱ្យមានរបួសស្នាមកម្រិតមធ្យមមានចំនួន ៤ ករណី | – សមត្ថកិច្ចបើកកិច្ចនីតិវិធីបន្ត ដោយបានបញ្ជូនរឿងទៅអធិការដ្ឋានក្រុងសៀមរាប ព្រោះបានទុករឿងឥតចាត់ការមួយរយៈចំនួន ២ ករណី ។<br>– សំណុំរឿងបានបញ្ជូនទៅព្រះរាជអាជ្ញា ហើយជនប្រព្រឹត្តបានជាប់ពន្ធនាគារ ។<br>– សម្របសម្រួលដាក់ពាក្យបណ្តឹងលែងលះត្រឹមស្រុក ។ |
| ៤ | ករណីអំពើហិង្សាលើផ្លូវចិត្ត | – នគរបាលបានអញ្ជើញភាគីទាំងពីរមកសម្របសម្រួល |

| | | |
|---|---|---|
| | ចំនួន ២ ករណី | ហើយប្រសិនបើនៅតែមិនចុះសម្រុងនឹងបញ្ជូនទៅអធិការដ្ឋានបន្តទៀត (នគរបាលពន្យាពេលនៃការដោះស្រាយរឿងក្ដីយូរពេក) ។<br>– នគរបាលបានអញ្ជើញភាគីខាងប្រពន្ធមកធ្វើការរៀបចំសំណុំរឿងដាក់ពាក្យបណ្ដឹងទៅតុលារ (នគរបាលផ្អាកដំណើរការសំណុំរឿងយូរពេក) ។ |
| ៥ | ករណីអំពើហិង្សាលើផ្លូវភេទ ចំនួន ១ ករណី | – សុំឱ្យអង្គការអាដហុកជួយរៀបចំពាក្យបណ្ដឹងទៅតុលាការដើម្បីមានចំណាត់ការផ្លូវច្បាប់ ។<br>– ជនរងគ្រោះសុំលែងលះជាមួយនឹងប្ដី លែងរស់នៅជាមួយគ្នា ។ |

## ៤.៣- នីតិវិធីនៃការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុក

ដោយផ្អែកទៅតាមការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ នៅក្នុងផ្នែកនេះក្រុមយើងខ្ញុំនឹងធ្វើការលើកឡើងអំពីនីតិវិធី ឬដំណើរការនៃការអនុវត្តសកម្មភាពចំពោះការការពារសិទ្ធិរបស់សមាគមអាដហុក សាខាខេត្តសៀមរាប ទៅលើចំណុចសំខាន់ៗចំនួន ២ ដែលមានដូចជា ៖ ការអន្តរាគមន៍របស់សមាគម និងយន្តការនៃការការពារទៅលើសិទ្ធិស្ត្រី ដែលត្រូវបានគេបំពានទៅលើរូបរាងកាយ ។

### ក. ការអន្តរាគមន៍របស់សមាគមអាដហុក

– **ចំពោះករណីរំលោភសេពសន្ថវៈ**

ចំពោះចំណុចនៃការអន្តរាគមន៍នេះ គឺជានីតិវិធីដំបូងដែលសមាគមអាដហុកប្រើប្រាស់ក្នុងការទទួលបានព័ត៌មាន និងនីតិវិធីបឋមមុននឹងឈានដល់ការអនុវត្តនូវយន្តការផ្នែកច្បាប់ ។

○ **ប្រភពនៃការទទួលបានព័ត៌មាន**

ប្រភពនៃការទទួលបានព័ត៌មានដែលទាក់ទងទៅនឹងការរំលោភបំពានសិទ្ធិស្ត្រី ទាក់ទងទៅនឹងអំពើហិង្សា គឺទទួលបានតាមរយៈបុគ្គលផ្សេងៗដូចជា ៖

- **ជនរងគ្រោះផ្ទាល់** ៖ ជនរងគ្រោះអាចមកសុំជំនួយដោយខ្លួនឯងប្រសិនបើជនរងគ្រោះមានភាពក្លាហានក្នុងការប្រាប់នូវរឿងរ៉ាវ ហេតុការណ៍ដោយខ្លួនឯង ។ ក្នុងករណីដែលជនរងគ្រោះពុំហ៊ានធ្វើការដាក់ពាក្យបណ្ដឹង ឬសុំជំនួយដោយខ្លួនឯងទេនោះ សមាគមអាចទទួលបានដំណឹងពីបុគ្គលផ្សេងៗទៀត ដែលមានដូចខាងក្រោម ។
- **អ្នកជិតខាងរបស់ជនរងគ្រោះ** ៖ នៅក្នុងករណីដែលមានអ្នកជិតខាងជនរងបានឃើញករណីរំលោភសេពសន្ថវៈទៅលើជនរងគ្រោះ ហើយអ្នកជិតខាងជនរងគ្រោះមកដល់ទីស្នាក់ការរបស់សមាគម ហើយផ្ដល់ដំណឹង ឬដាក់ពាក្យបណ្ដឹងជូនជនរង

គ្រោះ ។ ករណីសមាគមក៏ទទួលបានច្រើនផងដែរ ហើយក៏ត្រូវបានរាប់បញ្ចូលនៅក្នុងផ្នែកព័ត៌មាននេះដែរ ។

- **បណ្ដាញគាំពារស្ត្រីរបស់សមាគមអាដហុក និងអង្គការដៃគូ ៖** បណ្ដាញគាំពារស្ត្រីរបស់សមាគមអាដហុក គឺមាននៅប្រចាំនៅតាមស្រុកនីមួយៗ ហើយនៅក្នុងចំណុចនេះផងដែរ សមាគមអាដហុក គឺមានបណ្ដាញសម្រាប់ឃ្លាំមើលទៅលើសិទ្ធិមនុស្ស និងសម្រាប់រាយការណ៍អំពីបញ្ហាទាក់ទងទៅលើការរំលោភសេពសន្ថវៈស្ត្រីជូនមកប្រធានសម្របសម្រួលរបស់សមាគមអាដហុក ដើម្បីធ្វើការចុះទៅដោះស្រាយ និងធ្វើការអន្តរាគមន៍ទៅលើបញ្ហាទាំងអស់នោះ ។

ចំពោះប្រភពដែលទទួលបានព័ត៌មាន នៃការរំលោភសេពសន្ថវៈទាំង ៨ ករណីខាងលើ គឺមានដូចតទៅ ៖

តារាងទី៨ ៖ ប្រភពព័ត៌មានដែលទទួលបាន

| ល.រ | ប្រភេទនៃការរំលោភបំពាន | ប្រភពព័ត៌មានដែលទទួលបាន |
|---|---|---|
| ១ | ការរំលោភសេពសន្ថវៈមានចំនួន ៨ ករណី | – បុគ្គលិកនៃសមាគមអាដហុកចំនួន ១ ករណី ។<br>– អនុប្រធានការិយាល័យការពារផ្លូវច្បាប់(មន្ទីរកិច្ចការនារី)ចំនួន ២ ករណី ។<br>– អង្គការដៃគូចំនួន ៣ ករណី ។<br>– សាច់ញាតិជនរងគ្រោះចំនួន ១ ករណី ។<br>– ម្ដាយរបស់ក្មេងស្រីរងគ្រោះចំនួន ១ ករណី ។ |
| ២ | អំពើហិង្សាក្នុងគ្រួសារចំនួន ១២ ករណី | – ទទួលបានព័ត៌មានពីបណ្ដាញសង្គមហ្វេសបុក Facebook ចំនួន ២ ករណី ។<br>– ប្រភពពីបុគ្គលិក និងអង្គការដៃគូចំនួន ៤ ករណី ។<br>– ប្រភពពីជនរងគ្រោះចំនួន ៣ ករណី ។<br>– ប្រភពពីបុគ្គលិករបស់សមាគមអាដហុកចំនួន ១ ករណី ។<br>– សកម្មភាពភូមិចំនួន ១ ករណី ។<br>– ប៉ុស្តិ៍នគរបាលចំនួន ១ ករណី ។ |

- **នីតិវិធីបឋមមុននឹងឈានដល់ការអនុវត្តយន្តការផ្លូវច្បាប់**
    - **ការចុះអង្កេតផ្ទាល់**

ដូចគ្នាទៅនឹងនីតិវិធីបឋមនៃការប្រើប្រាស់អំហិង្សាក្នុងគ្រួសារទៅលើស្ត្រីផងដែរ ចំពោះបទរំលោភសេពសន្ថវៈ គឺក្រោយពីបានទទួលដំណឹងអំពីអង្គហេតុថា មានការរំលោភបំពានលើស្ត្រី សមាគម

អាដហុក សាខាខេត្តសៀមរាប បានចាត់តាំងភ្នាក់ងាររបស់ខ្លួនចុះទៅសិក្សាស្រាវជ្រាវដល់កន្លែងកើតហេតុតែម្តង ។ ដែលការចុះសិក្សាស្រាវជ្រាវនេះ ត្រូវធ្វើឡើងនៅកន្លែងកើតហេតុផ្ទាល់ ដោយធ្វើការសាកសួរអ្នកដែលបានដឹង ឬជាប់ពាក់ព័ន្ធនៅក្នុងរឿងហេតុដែលបានកើតមានឡើងនោះ ។ ការចុះអង្កេតនេះដែរ ចាំបាច់ត្រូវផ្តល់ដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីឱ្យសម្មភាពចុះអង្កេតកាន់តែមានប្រសិទ្ធភាព ។ មិនត្រឹមតែប៉ុណ្ណោះ ប្រសិនបើសមាគមអាដហុក សាខាខេត្តសៀមរាប រកឃើញថាអាជ្ញាធរមានសមត្ថកិច្ច មិនអើពើចំពោះ ការរំលោភបំពានសិទ្ធិស្ត្រីដែលបានកើតមាននៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួននោះទេ សមាគមនឹងធ្វើការអន្តរាគមន៍ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចតែម្តង ។ សមាគមនេះ បានយកចិត្តទុកដាក់ជាខ្លាំងចំពោះការចុះអង្កេត ព្រោះថាវាអាចមានបញ្ហាប្រឈមជាច្រើនចំពោះការបំពេញសកម្មភាពរបស់ខ្លួន ។ ក្នុងការចុះអង្កេតផ្ទាល់នេះផងដែរ គឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះការចុះអង្កេតនេះគឺអាចធ្វើការភ្នាក់ងារអង្កេត រកឃើញថាករណីនោះជាបទល្មើសកើតឡើងពីការរំលោភបំពានពិតមែន ឬក៏ជាការយល់ព្រម ដោយហេតុថាប្រសិនបើវាជាករណីព្រមព្រៀងគ្នានោះ សមាគមគ្មានសមត្ថកិច្ចដោះស្រាយឡើយ ។

– **ចំពោះករណីអំពើហិង្សាក្នុងគ្រួសារលើស្ត្រី**

ចំពោះចំណុចនៃការអន្តរាគមន៍នេះ គឺជានីតិវិធីដំបូងដែលសមាគមអាដហុកប្រើប្រាស់ក្នុងការទទួលបានព័ត៌មាន និងនីតិវិធីបឋមមុននឹងឈានដល់ការអនុវត្តនូវយន្តការផ្នែកច្បាប់ ។

○ **ប្រភពនៃការទទួលបានព័ត៌មាន**

ប្រភពនៃការទទួលបានព័ត៌មានទាក់ទាងទៅនឹងការរំលោភបំពានសិទ្ធិស្ត្រី ដែលទាក់ទងទៅនឹងអំពើហិង្សា គឺទទួលបានតាមរយៈបុគ្គលផ្សេងៗដូចជា ៖

- **ជនរងគ្រោះផ្ទាល់** ចំពោះចំណុចនៃជនរងគ្រោះផ្ទាល់ គឺជនរងគ្រោះផ្ទាល់គាត់អាចទៅទីស្នាក់ការរបស់មាគមអាដហុកផ្ទាល់តែម្តងបាន ដើម្បីផ្តល់នូវព័ត៌មានជូនភ្នាក់ងាររបស់សមាគមអាដហុក ក្នុងការរកដំណោះស្រាយជូនគាត់វិញប្រកបដោយប្រសិទ្ធភាព ។
- **អ្នកជិតខាងរបស់ជនរងគ្រោះ ៖** នៅក្នុងចំណុចនេះ អ្នកជិតខាងរបស់ជនរងគ្រោះគាត់អាចមកទីស្នាក់ការរបស់សមាគមអាដហុក ដើម្បីរាយការណ៍អំពីអង្គហេតុដែលបានកើតឡើងទៅលើជនរងគ្រោះ ជូនទៅភ្នាក់ងាររបស់សមាគមអាដហុក ដើម្បីទទួលបាននូវព័ត៌មាន ។ ម្យ៉ាងវិញទៀត ដើម្បីឱ្យភ្នាក់ងាររបស់សមាគមអាដហុកចុះទៅធ្វើការអន្តរាគមន៍ និងរកនីតិវិធីដោះស្រាយជូនជនរងគ្រោះផងដែរ ។
- **បណ្តាញគាំពារស្ត្រីរបស់សមាគមអាដហុក ៖** បណ្តាញគាំពារស្ត្រីរបស់សមាគមអាដហុក គឺមាននៅប្រចាំនៅតាមស្រុកនីមួយៗ ហើយនៅក្នុងចំណុចនេះផងដែរ សមាគមអាដហុក គឺមានបណ្តាញសម្រាប់ឃ្លាំមើលទៅលើសិទ្ធិមនុស្ស និងសម្រាប់រាយការណ៍អំពីបញ្ហាទាក់ទងទៅលើ ទំនាស់ក្នុងគ្រួសារ និងការរំលោភបំពាន

ផ្លូវភេទស្ត្រី ជូនមកប្រធានសម្របសម្រួលរបស់សមាគមអាដហុក ដើម្បីធ្វើការចុះទៅដោះស្រាយ និងធ្វើការអន្តរាគមន៍ទៅលើបញ្ហាទាំងអស់នោះ ។

- **អាជ្ញាធរមានសត្ថកិច្ច ៖** អាជ្ញាធរមានសមត្ថកិច្ច ពេលដែលដឹងថាមានការកើតឡើងនៃករណីអំពើហិង្សា និងការរំលោភសេពសន្ថវៈហើយ សមត្ថកិច្ច ឬមន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែហៅជនរងគ្រោះ ឬសាក្សីដែលបានឃើញសកម្មភាព ឬហេតុការណ៍ដែលបានកើតឡើង ដើម្បីសាកសួរអំពីអង្គហេតុទាំងអស់នោះ ។ ហើយនឹងធ្វើការកសាងសំណុំរឿង ដើម្បីបន្តនីតិវិធីតទៅទៀតតាមផ្លូវច្បាប់ ក្នុងការរកយុត្តិធម៌ជូនជនរងគ្រោះវិញផងដែរ ។

- **នីតិវិធីបឋមមុននឹងឈានដល់ការអនុវត្តយន្តការផ្លូវច្បាប់**
  - **ការចុះអង្កេតផ្ទាល់**

ក្រោយពីបានទទួលដំណឹងអំពីអង្គហេតុថាមានការរំលោភបំពានលើស្ត្រី សមាគមអាដហុក សាខាខេត្តសៀមរាប បានចាត់តាំងភ្នាក់ងាររបស់ខ្លួនចុះទៅសិក្សាស្រាវជ្រាវដល់កន្លែងកើតហេតុតែម្តង ។ ដែលការចុះសិក្សាស្រាវជ្រាវនេះ ត្រូវធ្វើឡើងនៅនឹងកន្លែងកើតហេតុផ្ទាល់ ដោយធ្វើការសាកសួរអ្នកដែលបានដឹង ឬជាប់ពាក់ព័ន្ធនៅក្នុងរឿងហេតុដែលបានកើតមានឡើងនោះ ។ ការចុះអង្កេតនេះដែរ ចាំបាច់ត្រូវផ្តល់ដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីឱ្យសកម្មភាពចុះអង្កេតកាន់តែមានប្រសិទ្ធភាព ។ មិនត្រឹមតែប៉ុណ្ណោះ ប្រសិនបើសមាគមនេះ រកឃើញថាអាជ្ញាធរមានសមត្ថកិច្ច មិនអើពើចំពោះការរំលោភបំពានសិទ្ធិស្ត្រីដែលបានកើតមាននៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួននោះ សមាគមនឹងធ្វើការអន្តរាគមន៍ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចតែម្តង ។ សមាគមអាដហុក សាខាខេត្តសៀមរាប បានយកចិត្តទុកដាក់ជាខ្លាំងចំពោះការចុះអង្កេត ព្រោះថាវាអាចមានបញ្ហាប្រឈមជាច្រើនចំពោះការបំពេញសម្មភាពរបស់ខ្លួន ។

- **ការសម្រុះសម្រួលទៅលើទំនាស់ដែលបានកើតឡើង**

នៅក្នុងដំណាក់កាលបឋមនេះ មន្ត្រីដែលចុះទៅអង្កេតនៅក្នុងស្ថានភាពវិវាទផ្ទាល់ ដែលទាក់ទងទៅនឹងករណីអំពើហិង្សាកម្រិតស្រាល គឺមានន័យថា ក្នុងករណីដែលមិនមានការប្រើប្រាស់អំពើហិង្សាដែលអាចរាប់ជាបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបាន នោះមន្ត្រីដែលចុះអង្កេតផ្ទាល់នោះ នឹងធ្វើការសម្រុះសម្រួលដល់ភាគីទំនាស់ទាំងសងខាងជាមុនសិន ។ ក្នុងន័យនេះ សមាគមមានគោលបំណងផ្សះផ្សាភាគីទាំងពីរឱ្យចុះសម្រុងនឹងគ្នាវិញ ជៀសវាងការកើតឡើង និងបង្កអំពើហិង្សាធ្ងន់ធ្ងរហូតដល់ក្លាយទៅជាបទល្មើសព្រហ្មទណ្ឌ និងធ្វើឱ្យមានការបែកបាក់គ្នាក្នុងគ្រួសារ ។

គួរបញ្ជាក់ម្តងទៀតផងដែរថា ចំពោះករណីអំពើហិង្សាដែលរាប់បានថាជាបទល្មើសព្រហ្មទណ្ឌកម្រិតធ្ងន់នោះ គឺសមាគមនមិនមានវិធានការនូវក្នុងការសម្របសម្រួលដល់ភាគីទំនាស់នោះទេ ។ ក្នុងន័យនេះ សមាគមនឹងធ្វើការជំរុញដល់អាជ្ញាមានសមត្ថកិច្ច ឱ្យធ្វើការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ក៏ប៉ុន្តែប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចពុំមានចំណាត់ការទៅលើរឿងនេះទេ នោះសមាគមនឹងធ្វើការដាក់ពាក្យបណ្តឹងបរិហាទៅព្រះរាជអាជ្ញាដោយខ្លួនឯងផ្ទាល់តែម្តង ។

## ខ. យន្តការរបស់សមាគមអាដហុក

ចំពោះអត្ថន័យនៃពាក្យថាយន្តការរបស់សមាគមនៅទីនេះ គឺមានន័យថា ជាការអនុវត្តទៅតាមនីតិវិធីច្បាប់ ចាប់តាំងពីដំណាក់កាលនៃការដាក់ពាក្យបណ្តឹង រហូតដល់ការអនុវត្តនីតិវិធីនៅក្នុងប្រព័ន្ធតុលាការ ។

- **ការរំលោភសេពសន្ថវៈ ៖** ករណីនេះ សមាគមត្រូវជំរុញឱ្យមន្ត្រីនគរបាលមានសមត្ថកិច្ច ធ្វើការបញ្ជូនសំណុំរឿងដែលកើតមានឡើងនោះ ទៅព្រះរាជអាជ្ញាឱ្យបានឆាប់បំផុត ហើយប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចពុំមាននូវចំណាត់ការអ្វីទាំងអស់ តាមរយៈការជំរុញម្តងហើយម្តងទៀតទេនោះ ខាងសមាគមនឹងធ្វើការជួយដាក់ពាក្យបណ្តឹងទៅព្រះរាជអាជ្ញាដោយខ្លួនឯងតែម្តង ។
- **អំពើហិង្សាក្នុងគ្រួសារ ៖** ចំពោះបទល្មើសដែលកើតឡើងហើយក្នុងទម្រង់ជាអំពើហិង្សានោះ សមាគមនឹងមានយន្តដូចជា ៖
  - **ករណីជាបទល្មើសស្រាល ៖** ចំពោះករណីបទល្មើសស្រាល គឺត្រូវបានបែងចែកជា ២ បន្តទៀតគឺ ៖
    - **ក្នុងករណីទី ១** គឺសមាគមនឹងស្នើទៅដល់មន្ត្រីនគរបាលយុត្តិធម៌ឱ្យធ្វើការសម្របសម្រួលដោះស្រាយវិវាទ បើសិនជាស្ត្រីជាជនរងគ្រោះយល់ព្រម ។ ត្រង់ចំណុចនេះ គឺមានន័យថា ប្រសិនបើជនរងគ្រោះយល់ព្រមថាមន្ត្រីនគរបាលយុត្តិធម៌អាចជួយដោះស្រាយបាន ហើយយល់ព្រមទៅតាមលក្ខខណ្ឌដែលនគរបាលបានដាក់ឱ្យនោះគឺជារឿងល្អ ហើយសមាគមនឹងនៅតែជួយគាំទ្រពីក្រោយដដែល ។
    - **ក្នុងករណីទី ២** ប្រសិនបើស្ត្រីរងគ្រោះមិនយល់ព្រមនោះទេ មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការសម្របសម្រួលបាននោះទេ មន្ត្រីនគរបាលត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ឬខាងសមាគមជួយរៀបចំដាក់ពាក្យបណ្តឹងទៅព្រះរាជអាជ្ញា ដោយឱ្យជនរងគ្រោះជាអ្នកធ្វើឡើង ហើយប្រសិនបើជនរងគ្រោះនោះជាអ្នកដែលមិនចេះអក្សរទេនោះ ខាងមន្ត្រីសមាគមនឹងជួយធ្វើឡើង ដោយនៅតែដាក់ឈ្មោះជនរងគ្រោះជាដើមចោទដដែល ។
  - **ករណីជាបទល្មើសធ្ងន់ធ្ងរ ឬបទល្មើសជាក់ស្តែង ៖** ករណីនេះក៏ដូចជាករណីបទល្មើសរំលោភសេពសន្ថវៈដូចគ្នា គឺសមាគមនឹងធ្វើការជំរុញឱ្យមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាឱ្យបានលឿនបំផុត ហើយបើសិនជាមន្ត្រីនគរបាលយុត្តិធម៌មិនមានចំណាត់ការទេនោះ ខាងសមាគមនឹងជួយដាក់ពាក្យបណ្តឹងទៅព្រះរាជអាជ្ញាតែម្តង ។ ត្រង់ចំណុចនេះ ក្រុមយើងខ្ញុំ ក៏ដូចជាមន្ត្រីខាងសិទ្ធិស្ត្រី និងកុមារ របស់សមាគមអាដហុកចង់បញ្ជាក់ថា កាលណាវាជាបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ ឬបទល្មើសជាក់ស្តែងនោះ នឹងមិនមានការសម្របសម្រួលនោះទេ គឺត្រូវដាក់ពាក្យបណ្តឹងទៅតុលាការតែម្តង ។

– **ជំនួយផ្នែកច្បាប់**

ដោយឆ្លងកាត់តាមរយៈការធ្វើបទសម្ភាសន៍ជាមួយនឹងកញ្ញាដែលធ្វើការជាមន្ត្រីខាងគម្រោងសិទ្ធិស្ត្រី និងកុមារ បានលើកឡើងយ៉ាងដូច្នេះថា ចំពោះជំនួយផ្នែកច្បាប់ គឺសមាគមធ្វើឡើងក្នុងរូបភាព ៣ យ៉ាងគឺ ១. ការប្រឹក្សាយោបល់ផ្នែកច្បាប់ ២. ការផ្តល់ជំនួយជាមេធាវី និង ៣. ការផ្តល់ជាថវិកាក្នុងករណីពិសេស ។

- **ការប្រឹក្សាយោបល់ផ្នែកច្បាប់ ៖** គឺកាលណាដែលជនរងមានបញ្ហា ហើយមកត្រូវការជំនួយពីសមាគម នោះសមាគមនឹងត្រូវផ្តល់ឱ្យនូវជំនួយជាការប្រឹក្សាយោបល់ទៅកាន់ជនរងគ្រោះភ្លាម ។ ក្នុងនោះដែរ ជំនួយខាងប្រឹក្សាយោបល់ផ្នែកច្បាប់នេះ មានន័យថា សមាគមប្រឹក្សាយោបល់លើករណីដែលកើតឡើងនោះវាស្ថិតក្រោមបទល្មើសអ្វី ហើយនឹងគួរដោះស្រាយដោយរបៀបណា ។ម្យ៉ាងវិញទៀត មន្ត្រីដែលធ្វើការផ្នែកនេះក៏បានផ្តល់នូវការលើកទឹកចិត្តផងដែរដើម្បីកុំឱ្យជនរងគ្រោះមានការភ័យបារម្ភ ថាខ្លួននឹងមិនអាចដោះស្រាយនូវបញ្ហាទាំងអស់នោះបាន ។
- **ការផ្តល់ជំនួយជាមេធាវី ៖** គឺមានន័យថាប្រសិនបើជនរងគ្រោះជាអ្នកដែលគ្មានលទ្ធភាពនៅក្នុងការជួលមេធាវីដោយខ្លួនឯងនោះទេ ហើយករណីនោះជនរងគ្រោះត្រូវតែមានមេធាវីដើម្បីជួយដំណើរការតតាំងក្តី នោះសមាគមគឺមានមេធាវីរបស់ខ្លួនដើម្បីផ្តល់ឱ្យជនរងគ្រោះ ដោយពុំមានការគិតថវិកាអ្វីឡើយ ។
- **ការផ្តល់ជាថវិកាក្នុងករណីពិសេស ៖** គឺដោយហេតុថាករណីនេះ ជនរងគ្រោះជាជនដែលមានជីវភាពក្រីក្រខ្លាំង នោះខាងសមាគមនក៏មានជាកញ្ចប់ថវិកាសម្រាប់ជនរងគ្រោះដើម្បីធ្វើដំណើរមកកាន់សមាគម ឬទៅតុលាការ ថវិកាសម្រាប់ថែទាំសុខភាពរបស់ជនរងគ្រោះ និងអាហារហូបចុកជាដើម ។

## ៤.៣.១- គុណសម្បត្តិ និងគុណវិបត្តិ

តាមរយៈការជួយការពារសិទ្ធិជូនប្រជាពលរដ្ឋរបស់សមាគមអាដហុកនេះដែរ ក៏មាននូវគុណសម្បត្តិ និងគុណវិប្បត្តមួយចំនួនដូចជា ៖

### ក. គុណសម្បត្តិ

- ជួយឱ្យប្រជាពលរដ្ឋទទួលបាននូវសិទ្ធិរបស់ខ្លួនពីការរំលោភបំពានផ្សេងៗដែលកើតមានឡើងចំពោះខ្លួន
- ជួយពន្លឿននូវនីតិវិធីនៃដំណើរការសំណុំរឿង ចាប់ពីដំណាក់កាលនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលនីតិវិធីតុលាការ
- ជាជំនួយនៅក្នុងការដាស់តឿនអាជ្ញាធរមានសមត្ថកិច្ច ឱ្យដោះស្រាយបញ្ហាជូនប្រជាជនដោយមិនទុករឿងចោលឥតចាត់ការ

- ធ្វើឱ្យប្រជាពលរដ្ឋ ជាពិសេសស្ត្រីរងគ្រោះ ឱ្យទទួលបាននូវយុត្តិធម៌ក្នុងករណីមានអំពើរំលោភបំពានផ្សេងៗ
- មិនបណ្តោយឱ្យជនដែលប្រព្រឹត្តអំពើអាក្រក់រួចខ្លួន
- ប្រឹក្សាអំពីបញ្ហានានាដល់ពលរដ្ឋ ជាពិសេសស្ត្រីដែលបានជួបនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃឱ្យទទួលបាននូវវិធាន និងមាគ៌ាក្នុងការដើរទៅមុខទៀត
- ការរក្សាការសម្ងាត់ជូនជនរងគ្រោះដែលមានការរំលោភបំពាន ដែលនេះជាការដែលអាចរក្សាតម្លៃថ្លៃថ្នូរក្នុងភាពជាមនុស្សជាតិ
- ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានដឹងអំពីសិទ្ធិរបស់ខ្លួន វិធីការពារ និងការស្វែងរកអង្គការ ឬសមាគមដែលអាចជួយដោះស្រាយបញ្ហាទាំងនោះបាន
- ធ្វើឱ្យប្រជាពលរដ្ឋទទួលបាននូវការប្រឹក្សាផ្នែកច្បាប់មួយដ៏ត្រឹមត្រូវ
- ផ្តល់ជាជំនួយមេធាវី ជំនួយហិរញ្ញវត្ថុ ទៅលើផ្នែកមួយចំនួនចំពោះជនរងគ្រោះដែលមានជីវភាពខ្វះខាត ។

## ខ. គុណវិបត្តិ

- ករណីអំពើហិង្សាដែលចូលក្នុងករណីព្រហ្មទណ្ឌ មន្ត្រីរបស់សមាគមអាដហុកបានព្យាយាមឱ្យជនរងគ្រោះដាក់ពាក្យបណ្តឹង ក៏ប៉ុន្តែជនរងគ្រោះមិនព្រម គឺសុំត្រឹមបណ្តឹងលែងលះ
- អាជ្ញាធរមានសមត្ថកិច្ចមួយចំនួនមិនព្រមដោះស្រាយបញ្ហាជូនប្រជាជន ដោយសំណុំរឿងឥតចាត់ការ ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋមានផលលំបាក
- មន្ត្រីទទួលបន្ទុកផ្នែកសិទ្ធិនារីគឺជាស្ត្រីតែម្នាក់ឯង ដែលពេលខ្លះធ្វើឱ្យមានការព្រួយបារម្ភចំពោះសុវត្ថិភាពដូចគ្នា
- ជនល្មើសបានរត់គេចខ្លួនបាត់ ដោយធ្វើឱ្យមានការពិបាកនៅក្នុងការស្វែងរក ដែលជាពិសេសធ្វើឱ្យសំណុំរឿងកាន់តែអូសបន្លាយ
- គ្មានអ្នកទទួលខុសត្រូវចំពោះជនរងគ្រោះ ព្រោះជនប្រព្រឹត្តបានសម្លាប់ខ្លួនឯងដូចគ្នា
- ជនរងគ្រោះមិនព្រមសហការជាមួយនឹងមន្ត្រីទទួលផ្ទុកផ្នែកសិទ្ធិស្ត្រី និងអាជ្ញាធរដើម្បីបំភ្លឺការពិត
- មន្ត្រីអនុវត្តសកម្មភាពមានគ្នាតិច ធ្វើឱ្យការធ្វើការមិនសូវលឿនខ្លាំង ។

## ៤.៣.២- បញ្ហាប្រឈមរបស់សមាគមអាដហុក ក្នុងការអនុវត្តនូវការការពារសិទ្ធិស្ត្រី

ចំពោះផ្នែកនៃបញ្ហាប្រឈមនេះ ក្រុមយើងខ្ញុំនឹងធ្វើការលើកឡើងនូវចំណុចសំខាន់ៗចំនួន ២ ដែលទាក់ទងទៅនឹងបញ្ហានេះដូចជា ៖ បញ្ហាប្រឈមរបស់មន្ត្រីដែលបានចុះអនុវត្តផ្ទាល់ និងបញ្ហាប្រឈមរបស់អង្គភាពផ្ទាល់ ដែលមានរៀបរាប់ដូចខាងក្រោម ៖

**ក. បញ្ហាប្រឈមរបស់មន្ត្រីដែលចុះអនុវត្តផ្ទាល់**

ដោយផ្អែកទៅលើការសម្ភាសន៍ផ្ទាល់ជាមួយនឹងប្រធានផ្នែកសិទ្ធិស្ត្រី និងកុមារ បានឱ្យដឹងថា ពួកគាត់មានបញ្ហាប្រឈមជាច្រើនដូចជា ៖

- ស្ថានភាពផ្លូវឆ្ងាយ ស្ងាត់ អសន្តិសុខ
- ប្រឈមជាមួយនឹងភាគីខាងប្រព្រឹត្ត
- ពេលខ្លះ ជនរងគ្រោះខ្វះការសហការ

**ខ. បញ្ហាប្រឈមរបស់សមាគមផ្ទាល់**

ដោយផ្អែកទៅលើការសម្ភាសន៍ផ្ទាល់ជាមួយនឹងមន្ត្រីគម្រោងការពារសិទ្ធិស្ត្រី និងកុមារ បានឱ្យដឹងថា ពួកគាត់មានបញ្ហាប្រឈមជាច្រើនដូចជា ៖

- ករណីមួយចំនួននៅពេលមានករណីរំលោភបំពានកើតឡើង អាជ្ញាធរនៅក្នុងតំបន់មួយចំនួនហាក់ដូចជាមានការសហការជាមួយសមាគមនៅមានកម្រិត ដែលជាហេតុធ្វើឱ្យល្បឿននៃការដំណើរការនីតិវិធីរកយុត្តិធម៌ជូនជនរងគ្រោះ ក៏មានភាពយឺតយ៉ាវផងដែរ
- ករណីការរំលោភបំពានសេពសន្ថវៈ នៅពេលដែលគាត់ទទួលបានសំណងពីភាគីបង្កហើយ ជនរងគ្រោះក៏បានដកពាក្យបណ្តឹងវិញ ដូច្នេះហើយ ក្នុងករណីនេះសមាគមក៏ពិបាកនូវក្នុងការដំណើរក្តីរកយុត្តិធម៌ផងដែរ ហើយក៏មានការលំបាកខ្លះៗក្នុងការស្វែងរកជំនួយ ។

**គ. ដំណោះស្រាយនៃបញ្ហាប្រឈម**

- មន្ត្រីអនុវត្ត
  - ស្ថានភាពផ្លូវឆ្ងាយ ស្ងាត់ អសន្តិសុខ ៖ ដោយជាដំណោះសម្រាប់មន្ត្រីអនុវត្ត គឺព្យាយាមគៀងគរអង្គការដៃគូរដែលមានមន្ត្រីអនុវត្តដូចគ្នា ដើម្បីចុះធ្វើកិច្ចការជាមួយឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ ដោយជាក់ស្តែងនៅពេលមានករណីរំលោភបំពានកើតឡើងនោះនឹងមានផ្នែកផ្សេងៗគ្នា ដែលតម្រូវឱ្យអង្គការដៃគូរត្រូវចុះអនុវត្តផងដែរ ។
  - ប្រឈមជាមួយនឹងភាគីខាងប្រព្រឹត្ត ៖ មន្ត្រីអនុវត្តធ្វើការទំនាក់ទំនង និងសហការជាមួយសមត្ថកិច្ច និងអាជ្ញាធរកន្លែងកើតហេតុ ឬកន្លែងគោលដៅដែលនឹងទៅអនុវត្តផ្ទាល់ ។
  - ពេលខ្លះ ជនរងគ្រោះខ្វះការសហការ ៖ អ្វីដែលជាដំណោះស្រាយរបស់មន្ត្រីអនុវត្ត គឺព្យាយាមបញ្ចុះបញ្ចូលជនរងគ្រោះអំពីផលវិបាកនៃការមិនដាក់ពាក្យបណ្តឹង និងផលវិបាកនៃការមិនសហការជាមួយ NGO សមត្ថកិច្ច និងអាជ្ញាធរ ដើម្បីឱ្យជនរងគ្រោះយល់អំពីអត្ថប្រយោជន៍នៃការអន្តរាគមន៍នេះ ។
- អង្គភាព
  - ករណីមួយចំនួននៅពេលមានករណីរំលោភបំពានកើតឡើង អាជ្ញាធរនៅក្នុងតំបន់មួយចំនួនហាក់ដូចជាមានការសហការជាមួយសមាគមនៅមានកម្រិត ដែលជាហេតុធ្វើឱ្យល្បឿននៃការដំណើរការនីតិវិធីរកយុត្តិធម៌ជូនជនរងគ្រោះ ក៏មានភាពយឺតយ៉ាវផងដែរ ។

ហើយជាអ្វីដែលអង្គភាពអាចជួយជម្រុញនីតិវិធីនេះបាន គឺការអន្តរាគមន៍ទៅអាជ្ញាធរ ឬសមត្ថកិច្ចថ្នាក់លើបន្ថែមទៀត ដូចជា អធិការស្រុក ស្នងការខេត្ត តុលាការជាដើម ។

- ករណីការរំលោភបំពានសេពសន្ថវៈ នៅពេលដែលគាត់ទទួលបានសំណងពីភាគីបង្ក ហើយ ជនរងគ្រោះក៏បានដកពាក្យបណ្តឹងវិញ ដូច្នេះហើយ ក្នុងករណីនេះសមាគមក៏ពិបាកនូវក្នុងការដំណើរក្តីរកយុត្តិធម៌ផងដែរ ហើយក៏មានការលំបាកខ្លះៗក្នុងការស្វែងរកជំនួយ ។ នៅក្នុងករណីបែបនេះ សមាគមនឹងធ្វើការអន្តរាគមន៍ទៅលោកព្រះរាជអាជ្ញា ដើម្បីឱ្យដំណើរការតាមនីតិវិធីច្បាប់តែម្តង ។

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១- សេចក្តីសន្និដ្ឋាន

យោងទៅតាមការសិក្សាស្រាវជ្រាវ ឯកសារស្រាវជ្រាវ និងរំលឹកទ្រឹស្តី ធ្វើឱ្យយើងដឹងកាន់តែច្បាស់បន្ថែមទៀតទៅលើប្រធានបទស្តីអំពី ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុកសាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ។ ទោះបីជាការសិក្សាស្រាវជ្រាវនេះនៅមានកម្រិត ហើយទិន្នន័យទាំងអស់នៅមិនទាន់គ្រប់ជ្រុងជ្រោយក៏ដោយ ក៏ទិន្នន័យទាំងអស់នេះបានឆ្លុះបញ្ចាំងអំពីទិដ្ឋភាពនៃការអនុវត្ត និងការការពារសិទ្ធិស្ត្រីអំពីការរំលោភបំពានផ្សេងៗ របស់សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ឬអាដហុកបានដែរ ។ ចំពោះការអនុវត្តការការពារសិទ្ធិស្ត្រីរបស់សមាគមបានល្អ នោះប្រជាពលរដ្ឋ ជាពិសេសស្ត្រីរងគ្រោះក៏នឹងទទួលបាននូវយុត្តិធម៌នៃសិទ្ធិរបស់ខ្លួនផងដែរ ។ ហើយប្រសិនបើសមាគមអនុវត្តនូវការការពារសិទ្ធិចំពោះស្ត្រី ឬប្រជាពលរដ្ឋមិនបានល្អ នោះប្រជាពលរដ្ឋក៏នឹងពុំទទួលបាននូវសិទ្ធិ ឬយុត្តិធម៌របស់ខ្លួនបាន ដែលវានឹងអាចមានជាផលអវិជ្ជមានដល់សមាគមដូចគ្នាដែរ ។

ឆ្លងតាមរយៈការចុះកម្មសិក្សាស្រាវជ្រាវដោយយកចិត្តទុកដាក់ក្រោមប្រធានបទ ការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុក សាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ បានធ្វើឱ្យក្រុមរបស់យើងខ្ញុំទទួលបាននូវចំណេះដឹងថ្មីៗជាច្រើន ដែលទាក់ទងទៅនឹងការអនុវត្តការងារការពារសិទ្ធិស្ត្រីរបស់សមាគម ការតាមដានលើការអនុវត្តនីតិវិធីរបស់តុលាការនៅពេលមានរឿងក្តីឈានទៅដល់នីតិវិធីតុលាការ និងទំហំនៃការកើតមានឡើងនូវករណីរំលោភបំពានលើសិទ្ធិស្ត្រី ។

នៅក្នុងនោះផងដែរ ក្រុមរបស់យើងខ្ញុំក៏បានយល់ដឹងបន្ថែមទៀតអំពីចំណុចមួយចំនួនដូចជា ៖

- ប្រភពនៃការកើតមានឡើងនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី
- យន្តការនៃការអនុវត្តសិទ្ធិជូនប្រជាពលរដ្ឋរបស់សមាគមអាដហុក
- បញ្ហាប្រឈមរបស់ភ្នាក់ងារអនុវត្ត និងអង្គភាពផ្ទាល់
- ផលវិបាកដែលអង្គភាព និងមន្ត្រីអនុវត្តជួបប្រទះ
- ទិដ្ឋភាពនៃសង្គម ដែលក្រុមយើងខ្ញុំបានមើលឃើញថាបញ្ហារំលោភបំពាន គឺនៅតែមានការកើតមានឡើងនៅឡើយ ដោយគ្រាន់តែមានភាពប្រសើរឡើងច្រើនជាងមុន
- ប្រសិទ្ធិភាពនៃការជួយអន្តរាគមន៍របស់អង្គការអាដហុក
- រាល់ការអនុវត្តនីតិវិធីរបស់តុលាការដែលទាក់ទងទៅនឹងករណីដែលសមាគមពាក់ព័ន្ធ គឺពិតជាមានការសង្កេតមើលបានយ៉ាងម៉ត់ចត់ពិតប្រាកដមែន ។

## ៥.២- ការផ្តល់អនុសាសន៍

ដោយផ្អែកទៅលើការសន្និដ្ឋាន និងការចុះកម្មសិក្សាស្រាវជ្រាវរួចមក យើងសង្កេតឃើញថាការការពារសិទ្ធិស្ត្រីរបស់សមាគមអាដហុក សាខាខេត្តសៀមរាប ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ពិតជាមានប្រសិទ្ធិភាពខ្ពស់ និងទទួលបាននូវយុត្តិធម៌ជាច្រើនទៅលើការអនុវត្តការងារជាក់ស្តែង ។ ជាមួយគ្នានោះដែរ យើងក៏បានមើលឃើញនូវចំណុចមួយចំនួនដែលគួរតែពង្រឹងបន្ថែមទៀត ហើយក្រុមយើងខ្ញុំសូមចូលរួមបញ្ចេញនូវមតិយោបល់ ដើម្បីពង្រឹងនូវចំណុចទាំងអស់នោះដូចខាងក្រោមនេះ ៖

- សមាគមគួរធ្វើយ៉ាងណាឱ្យមានការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចឱ្យបានកាន់តែល្អជាងនេះទៀត
- ក្នុងក្រុមរបស់យើងសូមស្នើ សូមឱ្យអង្គការអាដហុករាយការណ៍ទៅថ្នាក់លើនៃនគរបាលណាដែលមិនព្រមធ្វើការដោះស្រាយជូនប្រជាជន ព្រោះនេះនឹងអាចជួយឱ្យដំណើរការរឿងក្តីមិនមានការផ្អាក ឬពន្យាពេលនៃការដោះស្រាយ
- សមាគមគួរជ្រើសរើសមន្ត្រី ឬបុគ្គលិកបន្ថែមទៀត ព្រោះវិសាលភាពនៃការអនុវត្តរបស់សមាគមមានទំហំទូទាំងខេត្តសៀមរាបនេះ ដែលវាជាវិសាលភាពមួយដែលធំ ក៏ប៉ុន្តែមន្ត្រី ឬបុគ្គលិកដែលអនុវត្តគឺមានចំនួនតិច
- សមាគមអាដហុកគួររៀបចំឱ្យមានប្រព័ន្ធបញ្ចូលនូវទន្និន័យមួយ ដែលអាចផ្ទុកនូវសំណុំរឿងដែលទទួលបាន និងរក្សាជាឯកសារភស្តុតាងបានល្អផងដែរ ហើយម្យ៉ាងវិញទៀតវានឹងអាចជួយសម្រួលដល់និស្សិតក្រោយៗទៀត ប្រសិនបើចង់ចុះកម្មសិក្សានៅក្នុងសមាគមពេលក្រោយទៀត
- ជាចុងក្រោយ ក្រុមយើងខ្ញុំចង់ឱ្យសមាគមអាដហុក សាខាខេត្តសៀមរាប បន្តយុទ្ធនាការផ្សព្វផ្សាយអំពីសិទ្ធិស្រីបន្ថែមទៀត តាមសំណូមពរខាងលើដែលគួរតែជ្រើសបុគ្គលិកបន្ថែមទៀត
- ដោយមើលឃើញថាសមាគមអាដហុកភាគច្រើន គឺចុះផ្សព្វផ្សាយទៅតាមសហគមផ្សេងៗ ហេតុដូច្នេះហើយ ក្រុមយើងខ្ញុំសូមឱ្យសមាគមអាដហុកគួរធ្វើការផ្សព្វផ្សាយនៅតាមសាលារៀនគ្រប់កម្រិតថ្នាក់ ដើម្បីឱ្យពួកគេបានយល់ដឹងកាន់តែច្បាស់អំពីវិធីការពារ និងផ្លូវសម្រាប់ដើរប្រសិនបើពួកគេត្រូវបានជួបរឿងនេះ សូមអរគុណ៕

# ឯកសារយោង

## ១. ខេមរភាសា

– *កិច្ចព្រមព្រៀងនៅទីក្រុងប៉ារីស អំពីបញ្ហានៅកម្ពុជា* ឆ្នាំ ១៩៩១ ។

– *ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា* ឆ្នាំ ២០០៩ ។

– **ច័ន្ទ ចំរើន** ៖ ***នីតិសេរីភាពសាធារណៈ*** បោះពុម្ពលើកទី ២ ឆ្នាំ ២០១៨ គណៈកម្មការអភិវឌ្ឍ កម្មវិធីសិក្សានៃសាកលវិទ្យាល័យ **សៅស៍អ៊ីសថ៍អេយសៀ** ក្រុងសៀមរាប ។

– *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ* ឆ្នាំ ២០០៥ ។

– ធនាគារពិភពលោក ៖ *ច្បាប់ស្តីពីការងារ* ឆ្នាំ ១៩៩៧ ។

– *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* ឆ្នាំ ១៩៩៣ ។

– WWW.RHAC.ORG.KH

– Goran, Gudmundur និង Leif ៖ *ការចងក្រងលិខិតតុបករណ៍សិទ្ធិមនុស្សរបស់វិទ្យាស្ថានរ៉ាអុលវ៉ាលេនប៊ឺក* កែសម្រួល និងបោះពុម្ពលើកទី ៣ នៅភ្នំពេញ ឆ្នាំ ២០១២។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ " ១ "

# គម្រូងសំណួរស្រាវជ្រាវ

១. តើសមាគមអាដហុក បង្កើតឡើងតាំងពីពេលណា? ក្នុងគោលបំណងអ្វី?
២. តើសមាគមអាដហុក មានប្រវត្តិយ៉ាងដូចម្តេច?
៣. តើនិមិតសញ្ញារបស់សមាគមអាដហុក មានអត្ថន័យដូចម្តេចខ្លះ?
៤. តើសមាគមអាដហុក មានដៃគូប្រតិបត្តិការអ្វីខ្លះ?
៥. តើសមាគមអាដហុក មានរចនាសម្ព័នដូចម្តេចខ្លះ?
៦. តើចក្ខុវិស័យចម្បងរបស់សមាគមអាដហុក ផ្តោតទៅលើអ្វីខ្លះ?
៧. តើសមាគមអាដហុក មានដែនសមត្ថកិច្ចដូចម្តេចខ្លះ លើការការពារសិទ្ធិស្ត្រី?
៨. តើសមាគមអាហុក មានយន្តការអ្វីខ្លះដើម្បីការពារសិទ្ធិស្ត្រី?
៩. តើកត្តាអ្វីខ្លះដែលនាំឱ្យមានការរំលោភបំពានលើសិទ្ធិស្ត្រី?
១០. តើសមាគមអាដហុកជួបប្រទះនឹងបញ្ហាអ្វីខ្លះ ក្នុងការការពារសិទ្ធិស្រី?
១១. តើយន្តគាំពារសិទ្ធិស្ត្រីរបស់សមាគមអាដហុក ត្រូវបានអនុវត្តដោយរបៀបណា?
១២. នៅពេលដែលទទួលបានសំណុំរឿង តើសមាគមអាដហុកមានវិធានការដូចម្តេចខ្លះ?
១៣. តើវិធានការទាំងនោះ មានប៉ុន្មានដំណាក់កាល?
១៤. តើក្នុងរយៈពេល ១ ឆ្នាំនៃឆ្នាំ ២០១៩ នេះអង្គការអាដហុកទទួលបានការណីដែលទាក់ទងទៅនឹងការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារចំនួនប៉ុន្មានករណី? ហើយក្រោមរូបភាព និងប្រភេទអ្វីខ្លះ?
១៥. តើលទ្ធដែលទទួលបានក្រោយពីមានការអន្តរាគមពីសមាគមអាដហុកដើម្បីជួយជនរងគ្រោះមានលទ្ធផលយ៉ាងដូចម្តេច ទៅលើករណីនីមួយៗ?
១៦. តើចំនុចជនរងគ្រោះបានស្នើរសុំអ្វីខ្លះនៅក្នុងករណីនីមួយៗ មកសមាគមនៅពេលចុះអន្តរាគមក៏ដូចជាមកផ្ទាល់នឹងអង្គភាព?
១៧. តើមានគុណសម្បត្តិ និងគុណវិប្បត្តិអ្វីខ្លះចំពោះការការពារសិទ្ធិស្ត្រីពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ
១៨. តើបញ្ហាប្រឈមអ្វីខ្លះដែលសមាគមជួបប្រទះទាំងបុគ្គលិក និងអង្គភាពផ្ទាល់?
១៩. តើប្រភពនៃការទទួលបានព័ត៌ពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារសមាគមទទួលបានដោយរបៀបណា?
២០. តើក្រៅពីការអន្តរាគមនៅពេលជនរងគ្រោះមកដាក់ពាក្យបណ្តឹង សមាគមន៍អាដហុកមានសេវាអ្វីខ្លះទៀតដែលផ្តល់ឱ្យអតិថិជន?

ឧបសម្ព័ន្ធ " ២ "

(រូបភាពស្លាកឈ្មោះរបស់សមាគមអាដហុក ខេត្តសៀមរាប)




(រូបភាពអគាររបស់សមាគមអាដហុក ខេត្តសៀមរាប)



ឧបសម្ព័ន្ធ " ៣ "

(រូបភាពប្រជុំពិភាក្សាគ្នាក្នុងក្រុម នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០)



(រូបភាពប្រជុំពិភាក្សាគ្នាក្នុងក្រុម នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០)



ឧបសម្ព័ន្ធ " ៤ "

(រូបភាពប្រជុំជាមួយសាស្ត្រាចារ្យដឹកនាំ នាថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៩)



(រូបភាពប្រជុំជាមួយសាស្ត្រាចារ្យដឹកនាំ នាថ្ងៃទី ០១ ខែមករា ឆ្នាំ ២០២០)



ឧបសម្ព័ន្ធ " ៥ "

(រូបភាពចុះស្រាវជ្រាវនៅក្នុងស្ថាប័ន ឬទីកន្លែងចុះស្រាវជ្រាវនាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩)




(រូបភាពចុះស្រាវជ្រាវនៅក្នុងស្ថាប័ន ឬទីកន្លែងចុះស្រាវជ្រាវនាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩)



ឧបសម្ព័ន្ធ "៦"

(រូបភាពចុះស្រាវជ្រាវនៅក្នុងស្ថាប័ន ឬទីកន្លែងចុះស្រាវជ្រាវនាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩)




(រូបភាពចុះស្រាវជ្រាវនៅក្នុងស្ថាប័ន ឬទីកន្លែងចុះស្រាវជ្រាវនាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០)



Address : Opposite Angkor High School, Siem Reap Municipality
Website : www.usea.edu.kh, Email: info@usea.edu.kh
Facebook : University of South-East Asia